ព្រះរាជាណាចក្រកម្ពុជា

# គោលនយោបាយ
# ការពារជាតិ

២០២២



ក្នុងគោលបំណងរក្សាការពារនូវសន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍ លើគ្រប់វិស័យ រាជរដ្ឋាភិបាលគាំទ្រយ៉ាងម៉ឺងម៉ាត់ ចំពោះគោលនយោបាយការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងក្នុងសៀវភៅសការពារជាតិឆ្នាំ២០២២។ គោលនយោបាយការពារជាតិនេះ គឺជាត្រីវិស័យ សម្រាប់ការអនុវត្តតួនាទី និងភារកិច្ចរបស់កងយោធពលខេមរភូមិន្ទ ដោយឈរលើមូលដ្ឋាននៃការគោរពច្បាប់រដ្ឋធម្មនុញ្ញ និងភក្តីភាពដ៏រឹងមាំ ចំពោះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីធានាដល់ចីរភាពនៃការអភិវឌ្ឍន៍លើវិស័យការពារជាតិ ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ចាំបាច់ត្រូវធ្វើកំណែទម្រង់ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ សំដៅធ្វើឱ្យកងទ័ពគ្រប់ប្រភេទក្លាយជាកម្លាំងការពារជាតិដ៏រឹងមាំ មានសមត្ថភាព និងគុណភាពគ្រប់គ្រាន់ មានវិន័យម៉ឺងម៉ាត់ ស្មោះត្រង់ចំពោះជាតិមាតុភូមិ មានការប្តេជ្ញាចិត្តខ្ពស់ ព្រមទាំងមានភាពបត់បែន និងត្រៀមខ្លួនជាប់ជានិច្ចក្នុងកិច្ចការពារសន្តិភាព សន្តិសុខ ស្ថិរភាព និងសុវត្ថិភាពសង្គមជាតិ ព្រម

ទាំងក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិ និងលើកតម្កើងកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ។

ខ្ញុំតែងតែរំលឹកជានិច្ចថា *"ការពារជាតិយើងទាំងអស់គ្នា យើងទាំងអស់គ្នាដើម្បីការពារជាតិ"*។ ដូច្នេះការពង្រឹងខឿនការពារជាតិគឺជាអាទិភាពចម្បង ដែលកងយោធពលខេមរភូមិន្ទចាំបាច់ត្រូវតែប្រកាន់យក ដើម្បីការពារឱ្យបានដាច់ខាតនូវឯករាជ្យភាព អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ កងទ័ពកើតចេញពីប្រជាជន ដូច្នេះការផ្សារភ្ជាប់រវាងកងទ័ព និងប្រជាជន គឺមិនអាចខ្វះបាន នៅក្នុងការពង្រឹងខឿនការពារជាតិរបស់យើង។

ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំនៃក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទ ដែលបានខិតខំកសាងឯកសារយុទ្ធសាស្ត្រការពារជាតិ តាមរយៈសៀវភៅសការពារជាតិឆ្នាំ២០២២ ដែលអនុលោមត្រឹមត្រូវទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ខ្ញុំជឿជាក់ថា ឯកសារនេះនឹងក្លាយជាមាគ៌ាយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់កងយោធពលខេមរភូមិន្ទ ក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ ក្នុងកិច្ចការពារជាតិ និងការអភិវឌ្ឍមាតុភូមិដ៏រុងរឿងនៃយើង។

ថ្ងៃព្រហស្បតិ ៧រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**



កងយោធពលខេមរភូមិន្ទមានកាតព្វកិច្ច ក្នុងការការពារឯករាជ្យភាព អធិបតេយ្យ និងបូរណភាពទឹកដី ហើយមានតួនាទីនិងភារកិច្ចសំខាន់ ក្នុងការថែរក្សាការពារសន្តិភាព សន្តិសុខ ស្ថិរភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំ នៃការអភិវឌ្ឍជាតិលើគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាការពិតណាស់ ស្ថិតក្រោមគោលនយោបាយឈ្នះ ឈ្នះ ដ៏បវររុងរឿង របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** កម្ពុជាទទួលបាននូវសន្តិភាពពេញលេញ មានស្ថិរភាពនយោបាយនិងសង្គម ហើយកំពុងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។ អនុលោមទៅតាមការវិវត្តន៍នៃសភាពការណ៍យោធា និងសន្តិសុខ ទាំងនៅក្នុងប្រទេស និងនៅក្នុងតំបន់ កងយោធពលខេមរភូមិន្ទប្តេជ្ញាអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យការពារជាតិ ពុះពារឧបសគ្គគ្រប់យ៉ាងទាំងអស់ ដើម្បីការពារសន្តិភាពដ៏មានតម្លៃ ការពារដាច់ខាតនូវរដ្ឋធម្មនុញ្ញនិងរាជរដ្ឋាភិបាល ព្រមទាំងរួមចំណែកយ៉ាងពេញទំហឹង នៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យបានចម្រើនរុងរឿង តទៅថ្ងៃអនាគត។

ទន្ទឹមនឹងការរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ កងយោធពលខេមរភូមិន្ទចាំបាច់ត្រូវបន្តធ្វើកំណែទម្រង់ ដើម្បីពង្រឹងនិងបង្កើនសមត្ថភាពរបស់ខ្លួន ក្នុងកិច្ចការពារជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់ និងលើកស្ទួយកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសតាមរយៈការបំពេញបេសកកម្មរក្សាសន្តិភាពក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ។

គោលការណ៍ចម្បងគឺការពង្រឹងខឿនការពារជាតិ តាមរយៈការផ្សារភ្ជាប់គ្រប់ពេលវេលា រវាងកងទ័ពនិងប្រជាជន ដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលា ទៅនឹងការគំរាមកំហែងគ្រប់រូបភាព ទាំងនៅក្នុងប្រទេស និងពីសំណាក់កម្លាំងអមិត្តខាងក្រៅ។

ដើម្បីសម្រេចបានរាល់គោលដៅយុទ្ធសាស្ត្រ ដែលបានកំណត់ក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យការពារជាតិ សៀវភៅសការពារជាតិឆ្នាំ ២០២២ គឺជាមាគ៌ា និងត្រីវិស័យសម្រាប់កងយោធពលខេមរភូមិន្ទ ប្រើប្រាស់ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងកិច្ចការពារជាតិដ៏ឧត្តុងឧត្តម។ ខ្ញុំក៏សូមយកឱកាសនេះ អំពាវនាវដល់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ព្រមទាំងយុទ្ធជន យុទ្ធនារី នៃកងយោធពលខេមរភូមិន្ទ យកចិត្តទុកដាក់ឲ្យបានជាអតិបរមា ចំពោះការប្រើប្រាស់សៀវភៅសការពារជាតិឆ្នាំ២០២២នេះ ជាត្រីវិស័យតម្រង់ទិស នៅក្នុងការអនុវត្តតួនាទីនិងភារកិច្ចរៀងៗខ្លួន ចាប់ពីពេលនេះ និងតទៅអនាគត។

ថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**



**សម្តេចពិជ័យសេនា ទៀ បាញ់**

# មាតិកា


អារម្ភកថា ទំព័រI

សេចក្តីសង្ខេប ទំព័រIII

សេចក្តីផ្តើម ទំព័រ១

**ផ្នែកទី១**: **ទស្សនៈចំពោះការអនុវត្តគោលនយោបាយការពារជាតិ** ទំព័រ៥

**ជំពូក១**: ការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រការពារជាតិ ទំព័រ៧

កិច្ចការពារព្រំដែន ទំព័រ៧

កំណែទម្រង់យោធា ទំព័រ៩

ការហ្វឹកហ្វឺននិងបណ្តុះបណ្តាល ទំព័រ១០

ប្រតិបត្តិការរក្សាសន្តិភាព ទំព័រ១២

ការប្រឆាំងអំពើភេរវកម្ម ទំព័រ១៣

សន្តិសុខលម្ហសមុទ្រ ទំព័រ១៤

ជំនួយមនុស្សធម៌និងសង្គ្រោះគ្រោះមហន្តរាយ ទំព័រ១៧

កិច្ចសហប្រតិបត្តិការអន្តរជាតិ ទំព័រ១៩

ការគ្រប់គ្រងធនធានការពារជាតិ ទំព័រ២២

ការចូលរួមចំណែកអភិវឌ្ឍជាតិនិងហេដ្ឋារចនាសម្ព័ន្ធ ទំព័រ២៣

**ជំពូក២**: ចក្ខុវិស័យយុទ្ធសាស្ត្រ ទំព័រ២៥

ការវិភាគស្ថានការណ៍សន្តិសុខ ទំព័រ២៥

ការវាយតម្លៃការគំរាមកំហែងមកលើសន្តិសុខជាតិ ទំព័រ២៩

**ជំពូក៣:** គោលនយោបាយការពារជាតិ ទំព័រ៣៧

ថែរក្សាសន្តិភាព ទំព័រ៣៧

ការពារផលប្រយោជន៍ជាតិ ទំព័រ៣៨

បង្កើននិងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទំព័រ៣៩

គុណតម្លៃនៃប្រវត្តិសាស្ត្រយោធានិងនយោបាយ ឈ្នះ ឈ្នះ ទំព័រ៣៩

**ផ្នែកទី២: យុទ្ធសាស្ត្រការពារជាតិ** ទំព័រ៤៣

**ជំពូក៤:** កិច្ចការពារព្រំដែន ទំព័រ៤៥

ព្រំដែនគោក ទំព័រ៤៥

ព្រំដែនទឹក ទំព័រ៤៦

ព្រំដែនអាកាស ទំព័រ៤៧

**ជំពូក៥:** កិច្ចការពារសន្តិសុខជាតិ ទំព័រ៤៨

ការប្រយុទ្ធនឹងបដិវត្តន៍ពណ៌ ទំព័រ៤៨

ការប្រឆាំងភេរវកម្ម ទំព័រ៤៩

ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ទំព័រ៥០

ជំនួយមនុស្សធម៌និងសង្គ្រោះគ្រោះមហន្តរាយ ទំព័រ៥០

ការឆ្លើយតបនឹងជំងឺឆ្លងរាតត្បាតក្នុងស្រុកនិងជាសកលទំព័រ៥១

សន្តិសុខបច្ចេកវិទ្យាព័ត៌មាន ទំព័រ៥៣

**ជំពូក៦:** កំណែទម្រង់យោធា ទំព័រ៥៨

កែសម្រួលរចនាសម្ព័ន្ធចាត់តាំងនិងប្រព័ន្ធដឹកនាំបញ្ជា ទំព័រ៥៨

ការងារបុគ្គលិក ទំព័រ ៥៨
ការគ្រប់គ្រងធនធានថវិកាការពារជាតិ ទំព័រ ៦០
ឧស្សាហកម្មយោធា ទំព័រ ៦០
វិស័យអប់រំបណ្តុះបណ្តាល ទំព័រ ៦១
**ជំពូក៧**: ការចូលរួមក្នុងវិស័យការពារជាតិ និងសន្តិសុខលើឆាកអន្តរជាតិ ទំព័រ ៦៣
គោលការណ៍នៃកិច្ចសហប្រតិបត្តិការទ្វេភាគីពហុភាគី ទំព័រ ៦៣
គោលនយោបាយទំនើបកម្មមូលដ្ឋានសមុទ្ររាម ទំព័រ ៦៤
កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌតំបន់ ទំព័រ ៦៥
បេសកកម្មរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ ទំព័រ ៦៩

**ផ្នែកទី៣: ការអនុវត្តផែនការយុទ្ធសាស្ត្រ** ទំព័រ៧៣
**ជំពូក៨**: ការគ្រប់គ្រងអាទិភាពនៃកិច្ចការពារជាតិ ទំព័រ៧៨
**ជំពូក៩**: បច្ចេកវិទ្យា និងនវានុវត្តន៍យោធា ទំព័រ ៨០
**ជំពូក១០**: ថវិកាការពារជាតិ ទំព័រ ៨២

# អារម្ភកថា

រំលឹកដល់ដំណាក់កាលដំបូង នៃការបង្កើតឯកសារគោលនយោបាយការពារជាតិ ឬហៅថាសៀវភៅសការពារជាតិ របស់ព្រះរាជាណាចក្រកម្ពុជា ឃើញថាមានការលំបាក និងប្រកបដោយការពុះពារយ៉ាងធំធេង។ នាចុងឆ្នាំ១៩៩៨ ដោយយល់ឃើញអំពីសារសំខាន់នៃការកសាងគោលនយោបាយ និងយុទ្ធសាស្ត្រការពារជាតិសម្រាប់រយៈពេលវែង គោលគំនិតនៃការចងក្រងសៀវភៅសការពារជាតិដំបូង នៅឆ្នាំ២០០០ ត្រូវបានផ្តួចផ្តើមដោយនាយកដ្ឋាននយោបាយផែនការ នៃក្រសួងការពារជាតិ។ ទោះបីជាមានការខ្វែងគំនិតគ្នាមួយចំនួន នៅក្នុងចំណោមថ្នាក់ដឹកនាំ នៅគ្រាដំបូងក៏ដោយ**ឯកឧត្តម ទៀ បាញ់** ដែលពេលនោះជាសហរដ្ឋមន្ត្រីក្រសួងការពារជាតិ បានយកចិត្តទុកដាក់ និងឲ្យតម្លៃខ្ពស់ចំពោះការងារនេះ ហើយពុះពារស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី**សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** រហូតទទួលបានការយល់ព្រមទាំងស្រុង។ បន្ទាប់មក ក្រុមការងារសៀវភៅសការពារជាតិមួយ ត្រូវបានបង្កើតឡើង។

សៀវភៅសការពារជាតិឆ្នាំ២០២២ គឺជាឯកសារយុទ្ធសាស្ត្រទី៣ បន្ទាប់ពីសៀវភៅសការពារជាតិឆ្នាំ២០០០ និងឆ្នាំ២០០៦។ ការកសាងឯកសារយុទ្ធសាស្ត្រទាំងនេះ ជួបប្រទះការលំបាកខ្លាំង ទាមទារនូវពេលវេលា ធ្វើការងារជាសមូហភាព ស្មារតីប្តេជ្ញាខ្ពស់របស់ក្រុមការងារ និងការគាំទ្រជាប់ជានិច្ចរបស់ថ្នាក់ដឹកនាំ។ ដើម្បីធានាដល់និរន្តរភាពនៃគោលនយោបាយការពារជាតិ ឯកសារវិវេចនាយុទ្ធសាស្ត្រការពារជាតិ (ឆ្នាំ២០០២ និងឆ្នាំ២០១៣) ត្រូវបានបង្កើតឡើងនៅចន្លោះសៀវភៅសការពារជាតិ។

ឯកសារគោលនយោបាយការពារជាតិ ផ្តល់សារប្រយោជន៍សម្រាប់វិស័យការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា និងសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ។ សម្រាប់កម្ពុជា ឯកសារនេះ គឺជាយុទ្ធសាស្ត្ររយៈពេលវែង នៅក្នុងកិច្ចការពារជាតិ និងសន្តិសុខ។ គោលនយោបាយនេះ ក៏ជំរុញឲ្យមានកិច្ចសហការ និងការគាំទ្រគ្នាទៅវិញទៅមក រវាងស្ថាប័ន និងក្រសួងពាក់ព័ន្ធ សំដៅពង្រឹងខឿនការពារជាតិ ធានា

ឲ្យបានដាច់ខាតនូវការការពារសន្តិភាព ស្ថិរភាពសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយទេព្យកោសល របស់ស្ថាបនិកសន្តិភាព និងបង្រួបបង្រួមជាតិ គឺ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះ សៀវភៅសការពារជាតិ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់កសាងតម្លាភាព នៅក្នុងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងសន្តិសុខ ជាមួយបណ្តាប្រទេសនៅក្នុងតំបន់ ផងដែរ។

សមិទ្ធិផលដ៏មានតម្លៃខ្ពង់ខ្ពស់នេះ គឺជាគុណបំណាច់យ៉ាងធំធេងរបស់**សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ នៃក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ដែលបានផ្តល់ទំនុកទុកចិត្ត ការគាំទ្រ និងឯកភាព ចំពោះខ្លឹមសារទាំងឡាយនៃសៀវភៅសការពារជាតិឆ្នាំ២០២២។ ការរួមចំណែកយ៉ាងផុលផុសពីសំណាក់ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ អគ្គស្នងការនគរបាលជាតិ អង្គការចក្ខុវិស័យអាស៊ី បានជួយឲ្យដំណើរការចងក្រងឯកសារយុទ្ធសាស្ត្រនេះ បានទទួលលទ្ធផលជាវិជ្ជមាន ប្រកបដោយផ្លែផ្កា និងសម្រេចគោលដៅជាស្ថាពរ។

ជោគជ័យនៃដំណើរការចងក្រងសៀវភៅសការពារជាតិឆ្នាំ២០២២ ក៏បានមកដោយការរួមចំណែកពីសំណាក់អគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច ក្រសួងការពារជាតិ ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិតសភាកម្ពុជា មហាវិទ្យាល័យសង្គមសង្គមសាស្ត្រ និងភាសា នៃសកលវិទ្យាល័យការពារជាតិ និងក្រសួងការពារជាតិនៃប្រទេសអូស្ត្រាលី ក្នុងការជួយស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ ការកែសម្រួលខ្លឹមសារ និងការប្រែសម្រួលភាសា។

# សេចក្តីសង្ខេប

ឯកសារគោលនយោបាយការពារជាតិឆ្នាំ២០២២ ចែកចេញជាបីផ្នែកធំៗ៖

ផ្នែកទីមួយ ពិនិត្យមើលឡើងវិញ និងវាយតម្លៃ លើការអនុវត្តវិធានការយុទ្ធសាស្ត្រនៃគោលនយោបាយការពារជាតិបច្ចុប្បន្ន នៅក្នុងវិស័យសំខាន់ៗមួយចំនួនរួមមាន កិច្ចការពារព្រំដែន កំណែទម្រង់យោធា ការហ្វឹកហ្វឺនបណ្តុះបណ្តាល ការប្រឆាំងអំពើភេរវកម្ម សន្តិសុខលម្ហសមុទ្រ ការសង្គ្រោះគ្រោះមហន្តរាយ ប្រតិបត្តិការរក្សាសន្តិភាព កិច្ចសហប្រតិបត្តិការអន្តរជាតិ ការគ្រប់គ្រងធនធានការពារជាតិ ការរួមចំណែកអភិវឌ្ឍជាតិ ។ល។ ផ្នែកនេះ ឆ្លុះបញ្ចាំងអំពីចក្ខុវិស័យ ផ្តោតលើការវិភាគ និងព្យាករណ៍ លើការគំរាមកំហែងផ្នែកសន្តិសុខ មកលើព្រះរាជាណាចក្រកម្ពុជារហូតដល់ឆ្នាំ២០៣០ ដែលមានជាអាទិ៍ សន្តិសុខព្រំដែនគោក ទឹក និងអាកាស សន្តិសុខផ្ទៃក្នុង អំពើភេរវកម្ម សន្តិសុខព័ត៌មានវិទ្យា គ្រោះមហន្តរាយ ជម្ងឺឆ្លងរាតត្បាតជាដើម។ ទន្ទឹមនឹងនេះ គោលនយោបាយការពារជាតិថ្មីមួយត្រូវបានកំណត់ឡើងដែលគោលដៅចម្បងគឺ "ថែរក្សាការពារសន្តិភាពឲ្យបានគង់វង្សស្ថិតស្ថេរ ការពារផលប្រយោជន៍ជាតិ និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ"។

ផ្នែកទីពីរ កំណត់ឡើងនូវអាទិភាពនៃកិច្ចការពារជាតិមួយចំនួន ដោយផ្អែកលើទស្សនៈនៃការសន្និដ្ឋានលើការគំរាមកំហែង និងភាពប្រឈមទាំងឡាយ។ វិធានការយុទ្ធសាស្ត្ររយៈពេលវែង ផ្តល់អាទិភាពទៅលើ៖

១. កិច្ចការពារព្រំដែន ដែលផ្តោតការយកចិត្តទុកដាក់លើគោលជំហរដោះស្រាយបញ្ហាតាមរយៈការទូត និងផ្លូវច្បាប់ ការពង្រឹងយន្តការទំនាក់ទំនងទ្វេភាគី និងត្រីភាគី ការរក្សាវត្តមានកងទ័ព និងគ្រប់គ្រងសភាពការណ៍ជាប់ជាប្រចាំតាមតំបន់ព្រំដែន ការជំរុញការអភិវឌ្ឍតាមព្រំដែន ។ល។

២. សន្តិសុខផ្ទៃក្នុង ផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្រ្ត និងវិធានការចាំបាច់មួយចំនួន ដើម្បីប្រឆាំងនឹងបដិវត្តន៍ពណ៌ អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្មព័ត៌មានវិទ្យា ជាដើម។

៣. កំណែទម្រង់យោធា កំណត់អំពីវិធានការមួយចំនួនក្នុងការកែសម្រួលរចនាសម្ព័ន្ធ ការគ្រប់គ្រងបុគ្គលិក បង្កើនគុណភាពវិស័យហ្វឹកហ្វឺនបណ្តុះបណ្តាលកម្លាំងបម្រុង ការគ្រប់គ្រងធនធានការពារជាតិ ។ល។

៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ កំណត់អំពីទិសដៅមួយចំនួន ដើម្បីពង្រីក និងពង្រឹងទំនាក់ទំនងទ្វេភាគី និងពហុភាគី ការចូលរួមនៅក្នុងយន្តការក្នុង និងក្រៅតំបន់ ការបង្កើនសមត្ថភាពក្នុងប្រតិបត្តិការរក្សាសន្តិភាព និងការបញ្ជាក់អំពីគោលជំហររឹងប៉ឹងរបស់កម្ពុជាលើការធ្វើទំនើបកម្មមូលដ្ឋានសមុទ្ររាម។

ផ្នែកទីបី ផ្តល់នូវអនុសាសន៍មួយចំនួន ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយការពារជាតិ ដែលមានជាអាទិ៍ ការយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំគ្រប់ឋានានុក្រម ស្មារតីទទួលខុសត្រូវខ្ពស់របស់ប្រតិបត្តិករ កិច្ចសហការ និងការគាំទ្រទៅវិញទៅមក រវាងក្រសួង និងស្ថាប័ន ដែលពាក់ព័ន្ធនឹងវិស័យការពារជាតិ និងការគិតគូអំពីកំណើនថវិកាការពារជាតិ ផ្អែកលើកំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)។

# សេចក្តីផ្តើម

កិច្ចការពារជាតិ គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពទាំងឡាយដែលរាជរដ្ឋាភិបាលតែងតែគិតគូរដោយយកចិត្តទុកដាក់ ដើម្បីធានាឱ្យបាននូវសន្តិភាព សន្តិសុខ ស្ថិរភាព និងលើកតម្កើងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ។ ស្ថានភាពសន្តិសុខសម្រាប់ព្រះរាជាណាចក្រកម្ពុជាមានការប្រែប្រួលជាបន្តបន្ទាប់ ដោយសារការផ្លាស់ប្តូរសភាពការណ៍នៅក្នុងស្រុកនិងការទទួលរងឥទ្ធិពលនៃការវិវត្តផ្នែកភូមិសាស្ត្រនយោបាយនិងសន្តិសុខ ព្រមទាំងកត្តាដទៃទៀតនៅក្នុងតំបន់និងសកលលោក។ ការប្រែប្រួលទាំងអស់នេះ ទាមទារឱ្យមានការចាប់អារម្មណ៍និងគិតគូរឱ្យបានហ្មត់ចត់ក្នុងការដាក់ចេញនូវគោលនយោបាយការពារជាតិនិងយុទ្ធសាស្ត្រការពារជាតិប្រកបដោយចក្ខុវិស័យច្បាស់លាស់ ដើម្បីឆ្លើយតបទៅនឹងកាលានុវត្តភាព ភាពប្រឈម និងការគំរាមកំហែងគ្រប់ប្រភេទមកលើសន្តិសុខជាតិនាពេលបច្ចុប្បន្ននិងទៅអនាគត។

កន្លងមកកងយោធពលខេមរភូមិន្ទបានការពារនិងទប់ស្កាត់ បានទាន់ពេលវេលានិងមានប្រសិទ្ធភាព លើការការប៉ុនប៉ងបង្កអស្ថិរភាពគ្រប់រូបភាព ចូលរួមប្រយុទ្ធយ៉ាងពេញទំហឹងទល់នឹងជំងឺរាតត្បាតកូវីដ១៩ រួមចំណែកក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបានចូលរួមយ៉ាងសកម្មក្នុងការងារជំនួយមនុស្សធម៌និងជួយសង្គ្រោះគ្រោះមហន្តរាយនានា។ ជាមួយគ្នានេះ កងយោធពលខេមរភូមិន្ទក៏បានបំពេញភារកិច្ចសំខាន់ៗជាច្រើនទៀត រួមទាំងការបំពេញបេសកកម្មប្រតិបត្តិការរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ និងការចូលរួមនៅក្នុងសកម្មភាពថ្នាក់អនុតំបន់ តំបន់ និងអន្តរជាតិផងដែរ។

កងយោធពលខេមរភូមិន្ទប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យការពារជាតិឱ្យបានជោគជ័យ ហើយនឹងបន្តដើរតួនាទីជាកងកម្លាំងស្នូលនិងឈានមុខក្នុងការថែរក្សាការពារសន្តិភាព សន្តិសុខ ស្ថិរភាព និងផលប្រយោជន៍ជាតិ ព្រមទាំងចូលរួមក្នុងបុព្វហេតុនានាសម្រាប់ផលប្រយោជន៍រួមក្នុងតំបន់និងសកលលោក។ ចក្ខុវិស័យសម្រាប់រយៈពេល១០ឆ្នាំខាងមុខលើវិស័យ

ការពារជាតិ គឺសំដៅសំខាន់លើកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងយោធិន ធ្វើទំនើបកម្មដល់គ្រប់ប្រភេទទ័ព និងទ័ពជំនាញ បង្កើននិងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសជាដៃគូ ព្រមទាំងបង្កើនការចូលរួមក្នុងសកម្មភាពនានាលើឆាកអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងកាលានុវត្តភាពភាពប្រឈម និងការគំរាមកំហែងដែលនឹងអាចកើតឡើងនាពេលអនាគត។

## ១- សន្តិភាពជាមូលដ្ឋានគ្រឹះនៃការកសាងនិងអភិវឌ្ឍន៍ជាតិ

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យប្រទេសមួយដែលធ្លាប់មានជម្លោះផ្ទៃក្នុងរ៉ាំរ៉ៃអស់ជាច្រើនទសវត្សរ៍មកហើយនោះ ក្លាយជាមានសន្តិភាពពេញលេញបរិបូណ៌។ ឯករាជ្យភាព អធិបតេយ្យ និងភាពជាម្ចាស់លើបូរណភាពទឹកដីជាកត្តាកំណត់ដ៏សំខាន់ក្នុងការសម្រេចបាននូវសន្តិភាពពេញលេញ ការកសាងនិងអភិវឌ្ឍជាតិ ទៅថ្ងៃអនាគត។

ក្រោយការបោះឆ្នោតជាសកលក្នុងឆ្នាំ១៩៩៣ ក្រោមការរៀបចំដោយអង្គការសហប្រជាជាតិ ប្រចាំនៅកម្ពុជា កម្ពុជានៅតែពុំទាន់ទទួលបានសន្តិភាពនៅឡើយរហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ក្រោមនយោបាយឈ្នះ ឈ្នះ របស់ **សម្តេចតេជោ ហ៊ុន សែន** ទើបប្រទេសជាតិមានសន្តិភាពពេញលេញរហូតដល់បច្ចុប្បន្ននេះ ដែលផ្តល់ឱកាស និងលទ្ធភាពគ្រប់គ្រាន់ដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយបរិយាបន្នចីរភាព ធ្វើឱ្យកម្ពុជាមានមោទនភាពនិងកិត្យានុភាពកាន់តែខ្ពស់ត្រដែតនៅលើឆាកអន្តរជាតិ។

នយោបាយឈ្នះ ឈ្នះ បានបញ្ចប់ទាំងស្រុងនូវជម្លោះប្រដាប់អាវុធនិងសង្គ្រាម នាំមកនូវការបង្រួបបង្រួមជាតិ ឯកភាពជាតិ និងសុខដុមនីយកម្មក្នុងសង្គមតាមរយៈការធ្វើសមាហរណកម្មដោយគ្មានការរើសអើង និងការបើកឱកាសដល់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ។ អតីតតំបន់សមរភូមិត្រូវបានប្រែក្លាយទៅជាតំបន់អភិវឌ្ឍន៍ ដែលជាកត្តាសំខាន់ជំរុញឱ្យកម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ហើយជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាមានភាពល្អប្រសើរឡើងជាលំដាប់។

កម្ពុជាប្តេជ្ញាថែរក្សានិងការពារសន្តិភាព ដែលបានមកដោយលំបាកនិងប្រកបដោយការលះបង់យ៉ាងធំធេង សម្រាប់ជាកេរដំណែលនិងឧត្តមប្រយោជន៍ដល់កូនចៅជំនាន់ក្រោយ។ នៅក្នុងមោទនភាពនេះ ថ្ងៃទី២៩ ខែធ្នូ ត្រូវបានរាជរដ្ឋាភិបាលកំណត់ជាទិវារំលឹកដល់គុណបំណាច់ដ៏ឧត្តុងឧត្តម នៃនយោបាយឈ្នះ ឈ្នះ (ដោយមិនឈប់សម្រាក) ជារៀងរាល់ឆ្នាំ។ "**អរគុណសន្តិភាព អរគុណនយោបាយឈ្នះ ឈ្នះ ដឹងគុណស្ថាបនិក មគ្គុទេសក៏ឯក និងប្រតិបត្តិករនយោបាយឈ្នះ ឈ្នះ ដែលនាំមកនូវសន្តិភាព និងការឯកភាពជាតិពេញលេញ**"។



វិមានឈ្នះ ឈ្នះ និមិត្តរូបនៃសន្តិភាព និងការបង្រួបបង្រួមជាតិ (រូបភាព: អង្គភាពសេនាតេជោ)

## ២- តើអ្វីជាសៀវភៅសការពារជាតិ?

សៀវភៅសការពារជាតិ គឺជាឯកសារថ្នាក់ជាតិ រៀបរៀងចងក្រងដោយក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ឯកសារនេះ ឆ្លុះបញ្ចាំងអំពីទស្សនវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើវិស័យការពារជាតិ

នាពេលបច្ចុប្បន្ននិងតទៅអនាគត ដោយផ្អែកលើការវិភាគនិងការគិតគូរយ៉ាងហ្មត់ចត់និងយកចិត្តទុកដាក់ជាទីបំផុត។ សៀវភៅសការពារជាតិ គឺជាឯកសារចំហបង្ហាញពីតម្លាភាពនៃគោលបំណង និងទិសដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការសម្រេចផែនការនាពេលអនាគតលើវិស័យការពារជាតិ សម្រាប់ជាប្រយោជន៍ដល់កងយោធពលខេមរភូមិន្ទ សាធារណជនទូទៅ មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

គោលបំណងសំខាន់ នៅក្នុងការចងក្រងសៀវភៅសការពារជាតិឆ្នាំ២០២២នេះឡើង គឺដើម្បីផ្សព្វផ្សាយអំពីការយកចិត្តទុកដាក់និងការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ជាពិសេសក្រសួងការពារជាតិលើការពង្រឹងនិងអភិវឌ្ឍន៍វិស័យការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ជាការពិតណាស់ សន្តិភាព សន្តិសុខ និងស្ថិរភាពជាតិ គឺជាកត្តាចាំបាច់ដែលត្រូវតែថែរក្សានិងការពារឱ្យបានជាដាច់ខាត ដើម្បីធានាដល់ការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ ឱ្យបានពេញលេញនិងគ្រប់ជ្រុងជ្រោយ។ ហេតុដូចនេះ ប្រជាពលរដ្ឋខ្មែរក្នុងនាមជាខឿនការពារជាតិដ៏រឹងមាំ និងជាកម្លាំងគាំទ្រនៅសមរភូមិក្រោយ ត្រូវតែបង្កើនការយកចិត្តទុកដាក់លើការសិក្សាស្វែងយល់អំពីកិច្ចការពារជាតិ ដើម្បីពង្រីកការយល់ដឹងនិងរួមចំណែកជាមួយរាជរដ្ឋាភិបាលនិងកងយោធពលខេមរភូមិន្ទ ក្នុងការថែរក្សាការពារសន្តិភាព សន្តិសុខ និងស្ថិរភាពប្រទេសជាតិឱ្យបានគង់វង្សតទៅអនាគត។

# ផ្នែកទី១

# ទស្សនៈ

# ចំពោះការអនុវត្តគោលនយោបាយការពារជាតិ

# ជំពូក១
# ការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រការពារជាតិ

សៀវភៅសការពារជាតិឆ្នាំ២០០៦ និងឯកសារវិវេចនាយុទ្ធសាស្ត្រការពារជាតិឆ្នាំ២០១៣ បានបង្ហាញអំពីយុទ្ធសាស្ត្រអាទិភាព និងវិធានការយុទ្ធសាស្ត្រក្នុងការធ្វើកំណែទម្រង់និងសកម្មភាពចម្បង របស់កងយោធពលខេមរភូមិន្ទដែលអនុវត្តន៍កន្លងមក មានកិច្ចការមួយចំនួនធំទទួលបានសមិទ្ធផលនិងលទ្ធផលជាវិជ្ជមាន។ ប៉ុន្តែនៅមានចំណុចដែលមិនទាន់បានអនុវត្ត និងចំណុចខ្វះចន្លោះដែលត្រូវការពិនិត្យ រៀបចំ កែសម្រួល និងបំពេញបន្ថែមឡើងវិញ។

## ១- កិច្ចការពារព្រំដែន

កងយោធពលខេមរភូមិន្ទបានអនុវត្តទៅតាមយុទ្ធសាស្ត្រ៣ នៃសកម្មភាពប្រតិបត្តិការ និងអភិវឌ្ឍ១០ ដែលរាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើកិច្ចការការពារបូរណភាពទឹកដី ដោយឈរលើការប្តេជ្ញាចិត្ត ស្មារតីទទួលខុសត្រូវ ឆន្ទៈមោះមុត ការគោរពវិន័យ និងភាពបត់បែនដើម្បីរក្សាសន្តិភាពនិងពង្រឹងសន្តិសុខនៅតាមព្រំដែន។ ជាមួយគ្នានេះ កងយោធពលខេមរភូមិន្ទបានអនុវត្តតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល កសាងព្រំដែនជាព្រំដែនសន្តិភាព មិត្តភាព សហការ និងការអភិវឌ្ឍ ព្រមទាំងប្រកាន់នូវភាពអត់ធ្មត់ខ្ពស់បំផុត ដោយប្រឹងប្រែងប្រើប្រាស់វិធានការផ្នែកការទូតនិងផ្លូវច្បាប់ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាកន្លងមក។ ឥរិយាបទនេះ បានធ្វើឱ្យមជ្ឈដ្ឋានក្នុងតំបន់និងអន្តរជាតិ យល់ច្បាស់អំពីនយោបាយកម្ពុជាដែលចង់រស់នៅដោយសន្តិភាព ស្វែងរកដំណោះស្រាយដោយសន្តិវិធី និងគោរពតាមច្បាប់អន្តរជាតិ។

ជាដរាបរៀងមក កម្ពុជាមានសុឆន្ទៈរក្សាទំនាក់ទំនងល្អជាមួយប្រទេសជិតខាងជាប់ជានិច្ច ដោយមិនមានចេតនាឱ្យមានការប៉ះទង្គិចគ្នានោះឡើយ។ តែទោះជាដូច្នេះក្តី ជម្លោះព្រំដែនជាមួយប្រទេសជិតខាងដែលចាប់ផ្តើមពីខែកក្កដា ឆ្នាំ២០០៨ បានឈានដល់ការប៉ះទង្គិចគ្នាដោយអាវុធ រហូតធ្វើឱ្យមានការខូចខាតទាំងសងខាង

ដោយជៀសមិនរួច។ ស្ថិតក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ព្រះរាជាណាចក្រកម្ពុជាបានប្រើប្រាស់យុទ្ធសាស្ត្រចម្រុះគ្នាក្នុងពេលតែមួយក្នុងការដោះស្រាយវិវាទ គឺវិធានការយោធា ការទូត និងផ្លូវច្បាប់ ដោយប្រកាន់គោលជំហរម៉ឺងម៉ាត់ មិនបណ្តោយឱ្យគេរំលោភបំពានមកលើកម្ពុជាសូម្បីមួយមីលីម៉ែត្រឡើយ។ នៅក្នុងវិធានការការទូតនិងផ្លូវច្បាប់ កម្ពុជាបានព្យាយាមដោះស្រាយតាមរូបភាពទ្វេភាគី ពហុភាគី តាមរយៈយន្តការអាស៊ាន និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ កម្ពុជាពុំមានបំណងឈ្លានពានប្រទេសណាឡើយ ប៉ុន្តែកម្ពុជាចាំបាច់ត្រូវតែប្រើកម្លាំងប្រដាប់អាវុធ ដើម្បីការពារខ្លួនពីការរំលោភបំពានមកលើដែនអធិបតេយ្យរបស់កម្ពុជា ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់បំផុត។

នៅក្នុងការអនុវត្តយុទ្ធសាស្ត្រយោធា កងយោធពលខេមរភូមិន្ទជួបប្រទះការលំបាកខ្លាំងនៅក្នុងគ្រាដំបូងនៃជម្លោះ ដោយសារការជឿជាក់លើស្មារតីសន្តិភាព និងមិត្តភាពនិយម។ តែទោះជាដូច្នេះក្តី ការដឹកនាំដ៏ឈ្លាសវៃនិងមុតស្រួចរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** កម្លាំងឯកភាពជាតិខ្ពស់ និងចរន្តសន្ទោសន្ទៅនៃការគាំទ្រពីសមរភូមិក្រោយ បានក្លាយជាខឿនការពារជាតិមួយយ៉ាងរឹងមាំ និងមានប្រសិទ្ធភាពក្នុងកិច្ចការពារបូរណភាពទឹកដី។

តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រចម្រុះ គឺយោធានិងការទូតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** សភាពការណ៍បានត្រឡប់មករកភាពប្រក្រតី ហើយស្មារតីកសាងទំនាក់ទំនងល្អរវាងប្រទេសជិតខាងគ្នា ត្រូវបានពង្រឹងជាលំដាប់ ហើយយន្តការទំនាក់ទំនងគ្នាគ្រប់ជាន់ថ្នាក់ក៏ត្រូវបានពង្រឹងឡើងវិញ។ កងយោធពលខេមរភូមិន្ទបាននិងកំពុងចូលរួមយ៉ាងសកម្មជាមួយយន្តការថ្នាក់ជាតិ នៅក្នុងបេសកកម្មបោះបង្គោលសីមា នៅតាមបណ្តោយព្រំដែន។

នៅក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ ភាពសុខសាន្តនិងការរីកចម្រើននៅតាមតំបន់ព្រំដែនបានជួបប្រទះនឹងការគំរាមកំហែងថ្មីមួយ គឺជំងឺរាតត្បាតកូវីដ១៩។ នៅក្នុងកាលៈទេសៈប្រកបដោយគ្រោះថ្នាក់នេះ កងយោធពលខេមរភូមិន្ទបានចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ១៩ នៅតាមតំបន់ព្រំដែនក៏

ដូចជានៅតាមទីប្រជុំជន និងទីជនបទទូទាំងប្រទេស។ ក្រោមការចង្អុលបង្ហាញរបស់ប្រមុខរាជរដ្ឋាភិបាល កងយោធពលខេមរភូមិន្ទបានក្លាយជាកម្លាំងនាំមុខនៅក្នុងការអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់ជំងឺកូវីដ១៩ និងសហការគ្រប់គ្រងចលនាឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋ ការគ្រប់គ្រងមណ្ឌលចត្តាឡីស័ក ការផ្តល់សេវាដឹកជញ្ជូន ជាពិសេសការចូលរួមចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ១៩ ជូនដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ក្រហមនិងតំបន់ដែលមានការឆ្លងរាលដាលខ្លាំង។

## ២- កំណែទម្រង់យោធា

កងយោធពលខេមរភូមិន្ទបានអនុវត្តផែនការកំណែទម្រង់យោធា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល យុទ្ធសាស្ត្រការពារជាតិ និងតម្រូវការចាំបាច់នានាដោយឈរលើមូលដ្ឋាននៃពិសោធន៍ បញ្ហាប្រឈម កាលានុវត្តភាព និងការផ្លាស់ប្តូរក្នុងបរិបទជាតិនិងអន្តរជាតិ។ យ៉ាងណាមិញ សភាពការណ៍នៅតាមព្រំដែនហាក់បានជំរុញកាន់តែច្រើនថែមទៀតដល់ដំណើរការកែទម្រង់កងទ័ព ជាពិសេសលើការកសាងសមត្ថភាពកងយោធា។

ការអនុវត្តកម្មវិធីកំណែទម្រង់យោធា ឈានទៅសម្រេចបានលទ្ធផលគួរឱ្យកត់សំគាល់ក្នុងកិច្ចការពារជាតិ សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ដោយបានផ្តោតលើការងារអាទិភាពមួយចំនួនរួមមាន ការរៀបចំកែសម្រួលរចនាសម្ព័ន្ធនិងទីតាំងឈរជើង ពង្រឹងប្រព័ន្ធគ្រប់គ្រង និងឋានានុក្រមដឹកនាំបញ្ជា កិច្ចការបទដ្ឋានបច្ចេកទេស កិច្ចការរដ្ឋបាល ពង្រឹងការងារនីតិកម្មក្នុងការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការអប់រំចិត្តសាស្ត្រ ផ្សព្វផ្សាយព័ត៌មាន ការងារនយោបាយការបរទេសយោធា និងការកែសម្រួលរចនាសម្ព័ន្ធចាត់តាំងក្នុងក្របខណ្ឌការងារដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងសភាពការណ៍បច្ចុប្បន្ន។

អនុលោមទៅតាមតម្រូវការជាក់ស្តែង កំណែទម្រង់យោធាផ្តោតការយកចិត្តទុកដាក់ទៅលើការកែសម្រួលរចនាសម្ព័ន្ធនៃបញ្ជាការដ្ឋានកងទ័ពជើងគោក ការផ្ទេរកងឯកភាពមួយចំនួនពីអគ្គបញ្ជាការដ្ឋាន ឱ្យទៅចំណុះកងទ័ពជើងគោកបន្ថែមទៀត ការធ្វើទំនើបកម្មកម្លាំងការពារព្រំដែន ការពង្រឹងសមត្ថភាពការពារអាកាស

ការបង្កើនសមត្ថភាពកងទ័ពជើងទឹក ការកសាងធនធានមនុស្ស និងការហ្វឹកហ្វឺន ជាដើម។ ការបង្កើនសមត្ថភាពជំនាញសង្គ្រោះគ្រោះមហន្តរាយត្រូវបានធ្វើឡើង ទាំងការបង្កើនលើជំនាញក៏ដូចជាការបំពាក់នូវសម្ភារៈ និងមធ្យោបាយបន្ថែមទៀត ព្រមជាមួយការធ្វើលំហាត់ហ្វឹកហ្វឺនលើការសង្គ្រោះគ្រោះមហន្តរាយនេះ ជាមួយប្រទេសជាដៃគូផងដែរ។

ទោះជាដូច្នេះក្តី ដំណើរការកំណែទម្រង់នេះ បានជួបប្រទះភាពប្រឈមមួយចំនួនដោយសារតែរចនាសម្ព័ន្ធការងារ នៅមានភាពស្មុគ្រស្មាញនិងមានភាពត្រួតគ្នារវាងក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន កងទ័ពទាំងបីប្រភេទ និងកងរាជអាវុធហត្ថ។ ទន្ទឹមនឹងនេះ ច្បាប់កាតព្វកិច្ចយោធាដែលបានចូលជាធរមានតាំងពីឆ្នាំ២០០៦ ក៏នៅតែពុំទាន់បានអនុវត្តនៅឡើយ។ ម៉្យាងវិញទៀត ជំងឺកូវីដ១៩ ក៏បានធ្វើឱ្យរាំងស្ទះដល់ការធ្វើកំណែទម្រង់យោធាផងដែរ។ ការប្រើប្រាស់ធនធានមួយចំនួនធំត្រូវបានផ្តល់អាទិភាពទៅឱ្យការប្រយុទ្ធជាមួយជំងឺកូវីដ១៩។

## ៣- ការហ្វឹកហ្វឺននិងបណ្តុះបណ្តាល

កងយោធពលខេមរភូមិន្ទបានពង្រឹងនិងពង្រីកការងារបណ្តុះបណ្តាល ហ្វឹកហ្វឺន និងកសាងហេដ្ឋារចនាសម្ព័ន្ធ ឧបទេសសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប និងបានកែសម្រួលរចនាសម្ព័ន្ធគ្រឹះស្ថានអប់រំយោធាផងដែរ។ ការប្រឹងប្រែងទាំងនេះ គឺសំដៅបង្កើតមូលដ្ឋានរឹងមាំសម្រាប់ការកសាងធនធានមនុស្ស លើកកម្ពស់សមត្ថភាពយោធិន និងលើកកម្ពស់អត្តសញ្ញាណស្ថាប័នអប់រំយោធិនអាជីពឱ្យស្របតាមប្រព័ន្ធអប់រំជាតិនិងបទដ្ឋានអន្តរជាតិ។

កងយោធពលខេមរភូមិន្ទក៏បានកំណត់ការបណ្តុះបណ្តាលនិងហ្វឹកហ្វឺន នៅក្នុងប្រទេស ជាយុទ្ធសាស្ត្រនៃការកសាងធនធានមនុស្សនិងកសាងសមត្ថភាពរបស់យោធិនគ្រប់ថ្នាក់ គ្រប់ជំនាញ ហេតុនេះការងារអាទិភាពមួយចំនួនត្រូវបានអនុវត្ត។ បណ្តាគ្រឹះស្ថានអប់រំយោធា នៅតែបន្តជំរុញរៀបចំចងក្រង និងធ្វើបច្ចុប្បន្នភាពឯកសារគោលគ្រប់កម្រិត បានយកចិត្តទុកដាក់ខ្ពស់ក្នុងការងារអភិវឌ្ឍន៍កម្មវិធីសិក្សា ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលនិងហ្វឹកហ្វឺន ឱ្យមានលក្ខណៈវិទ្យា

សាស្ត្រយោធាសមស្របតាមជំនាញនិងកម្រិតពុទ្ធិសម្រាប់ពលទាហាន នាយទាហានរង និងនាយទាហានទាំងថ្នាក់យុទ្ធវិធី យុទ្ធនាការ និងយុទ្ធសាស្ត្រ។ កងយោធពលខេមរភូមិន្ទបានគិតគូរលើការបណ្តុះបណ្តាលមុខវិជ្ជាជំនាញឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រ ព្រមទាំងបានយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញ ពង្រឹងគុណភាព និងសមត្ថភាពយោធាចារ្យ សាស្ត្រាចារ្យ តាមរយៈការបើកវគ្គបំប៉នគរុកោសល្យនិងវិក្រិត្យការ និងការធ្វើសិក្ខាសាលាផ្លាស់ប្តូរពិសោធន៍និងជំនាញទាំងនៅក្នុងនិងក្រៅប្រទេស។

ទន្ទឹមនឹងនេះ ក្រសួងការពារជាតិបានសម្រិតសម្រាំង ជ្រើសរើសយោធិនបន្តវេនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅហ្វឹកហ្វឺន បណ្តុះបណ្តាលរយៈពេលខ្លីនិងវែងនៅតាមបណ្តាគ្រឹះស្ថានអប់រំយោធាក្នុងស្រុកនិងក្រៅប្រទេស ថែមទាំងបានពង្រឹងទំនាក់ទំនងចងសម្ព័ន្ធមេត្រីភាពជាមួយបណ្តាប្រទេសជាដៃគូ ដើម្បីពង្រីកការផ្លាស់ប្តូរទស្សនកិច្ចសិក្សានិងសិក្ខាកាមយោធាទៅវិញទៅមក ក្នុងគោលដៅលើកកម្ពស់ចំណេះដឹងតាមជំនាញ ពិសោធន៍ និងការកសាងសមត្ថភាពកងទ័ពឱ្យសមស្របតាមបទដ្ឋានជាតិនិងអន្តរជាតិ។ ជាលទ្ធផល ប្រព័ន្ធអប់រំយោធាមានការរីកចម្រើនគួរឱ្យកត់សំគាល់ ដោយបានបណ្តុះបណ្តាលយោធិន និងលើកកម្ពស់សមត្ថភាពកងទ័ព ក្នុងការបំពេញកាតព្វកិច្ចនិងតួនាទីប្រកបដោយជំនាញវិជ្ជាជីវៈទាំងនៅក្នុងប្រទេសនិងលើឆាកអន្តរជាតិ។

ទោះបីជាការហ្វឹកហ្វឺន និងបណ្តុះបណ្តាលបានរីកលូតលាស់ជាលំដាប់នាប៉ុន្មានឆ្នាំកន្លងមក ប៉ុន្តែការរីករាលដាលនៃជំងឺកូវីដ១៩ បានធ្វើឱ្យផែនការហ្វឹកហ្វឺន និងបណ្តុះបណ្តាលមួយភាគធំរបស់កងយោធពលខេមរភូមិន្ទមានការរាំងស្ទះនិងមិនអាចអនុវត្តបាន ជាពិសេសការធ្វើលំហាត់ហ្វឹកហ្វឺនប្រចាំឆ្នាំ ដើម្បីលើកកម្ពស់សមត្ថភាពប្រតិបត្តិការរបស់យោធិនក៏ត្រូវបានពន្យារពេលផងដែរ។ ជាក់ស្តែងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ (២០២០-២០២១) ការជ្រើសរើសសិក្ខាកាមថ្មីឱ្យចូលរៀនតាមបណ្តាសាលានាយទាហានឬសាលាពលទាហាន ត្រូវបានផ្អាកជាបណ្តោះអាសន្ន។ ទន្ទឹមនឹងនេះ ទម្រង់និងវិធីសាស្ត្រនៃការហ្វឹកហ្វឺននិងបណ្តុះបណ្តាល ភាគច្រើនត្រូវបានផ្លាស់ប្តូរ។

## ៤- ប្រតិបត្តិការរក្សាសន្តិភាព

កម្ពុជាធ្លាប់បានទទួលយក អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ (UNTAC-United Nations Transitional Authority in Cambodia) ពីឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៣។ ភ្លើងសង្គ្រាមបានរលត់ក្រោមនយោបាយឈ្នះ ឈ្នះរបស់ **សម្តេចតេជោ ហ៊ុន សែន** ចាប់តាំងពីចុងឆ្នាំ១៩៩៨ ហើយកម្ពុជាទទួលបានសន្តិភាព និងឯកភាពជាតិពេញលេញ។ កម្ពុជាបានធ្វើសមាហរណកម្មចូលទៅក្នុងពិភពលោក តាមរយៈបេសកកម្មរក្សាសន្តិភាព បន្ទាប់ពី១៣ឆ្នាំ ដែលអាជ្ញាធរអ៊ុនតាក់បានចាកចេញពីកម្ពុជា។ ទំព័រប្រវត្តិសាស្ត្រថ្មីត្រូវបានបើកឡើង ហើយកងយោធពលខេមរភូមិន្ទ ទទួលភារកិច្ចដ៏ឧត្តុង្គឧត្តម ចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ (អ.ស.ប) ដោយបានធ្វើយុទ្ធដំណើរជាលើកដំបូងទៅកាន់ប្រទេសស៊ូដង់ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦ ក្នុងបុព្វហេតុរួមចំណែកកសាងសុខសន្តិភាពជូនពិភពលោក។




កម្លាំងរក្សាសន្តិភាពកម្ពុជា ក្រោមអង្គការសហប្រជាជាតិ នៅអាហ្វ្រិកកណ្តាល (រូបភាព: NPMEC)

ការចូលរួមបេសកកម្មរក្សាសន្តិភាពរបស់កងយោធពលខេមរភូមិន្ទ គិតមកទល់ពេលនេះ មានរយៈពេល១៦ឆ្នាំហើយ ដោយបានបញ្ជូនកងកម្លាំងសរុបចំនួន

៨.៣០២នាក់ (នារី ៥៨០នាក់) ទៅកាន់ប្រទេសចំនួន៩ និង១១បេសកកម្មរបស់ អ.ស.ប រួមមាន: សាធារណរដ្ឋស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ លីបង់ សាយប្រើស ស៊ីរី អាហ្វ្រិកកណ្ដាល ម៉ាលី និងយ៉េមែន ក្នុងនោះមានជំនាញសំខាន់ៗចំនួន៩ មានជាអាទិ៍៖ វិស្វកម្មសំណង់ផ្តេកនិងបញ្ឈរ វិស្វកម្មពហុជំនាញ វិស្វកម្មព្រលានយន្តហោះ បោសសំអាតមីន កំទេចគ្រឿងផ្ទុះ អាវុធហត្ថ មន្ទីរពេទ្យកម្រិត២ នាយទាហានសេនាធិការ និងសង្កេតការណ៍យោធា។ ព្រមជាមួយនោះ ទង់ជាតិកម្ពុជាបានបង្ហូតយ៉ាងខ្ពស់ត្រដែត នៅទីបញ្ជាការ អ.ស.ប និងក្នុងតំបន់បេសកកម្ម ស្មើមុខស្មើសិទ្ធិ ស្មើភាព ជាមួយនឹងបណ្តាប្រទេសដែលបានបរិច្ចាគកងកម្លាំង។ តាមការវាយតម្លៃរបស់ អ.ស.ប ក្នុងឆ្នាំ២០២១ កម្ពុជាជាប់លំដាប់លេខរៀងទី២៨ ក្នុងចំណោម១២២ប្រទេស យេនឌ័រជាប់លំដាប់ទី១៣ ក្នុងចំណោម១២២ប្រទេស។ ដោយឡែក នៅក្នុងសហគមន៍អាស៊ាន កម្ពុជាស្ថិតក្នុងលំដាប់លេខ៣ នៃកងកម្លាំងរួម និងលេខ២ នៃកម្លាំងនារី។

## ៥- ការប្រឆាំងអំពើភេរវកម្ម

ព្រះរាជាណាចក្រកម្ពុជា ចាត់ទុកអំពើភេរវកម្មនៅតែជាការគំរាមកំហែងមកលើសន្តិសុខជាតិ តំបន់ និងសកលលោក។ កងយោធពលខេមរភូមិន្ទបានបង្ហាញយ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តនិងការយកចិត្តទុកដាក់ខ្ពស់ លើការអភិវឌ្ឍកម្លាំងប្រឆាំងភេរវកម្មរបស់ខ្លួន តាមរយៈការបង្កើននិងពង្រឹងការហ្វឹកហ្វឺនទាំងនៅក្នុងប្រទេសនិងនៅក្រៅប្រទេសក្នុងគោលដៅពង្រឹងសមត្ថភាព ទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើភេរវកម្មគ្រប់រូបភាព ដើម្បីការពារនិងថែរក្សាឱ្យបានដាច់ខាតនូវសន្តិភាព សន្តិសុខ និងស្ថិរភាពជាតិ។

**សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ធ្លាប់បានផ្តល់អនុសាសន៍ថា ***"ត្រូវព្យាយាមបង្ការកុំឱ្យអំពើភេរវកម្មកើតឡើងជាជាងខំប្រឹងប្រយុទ្ធតតាំងជាមួយនឹងវាដោយផ្ទាល់។ មិនត្រូវបង្កើតភេរវកម្ម ឬទាញយកភេរវកម្មឲ្យមកជិតខ្លួន"***។ ក្នុងន័យនេះ កម្ពុជាយល់ច្បាស់ថា ការថែរក្សាបាននូវសុខសន្តិភាព ការអភិវឌ្ឍ និងការរីកចម្រើននៃកម្រិតជីវភាពប្រជាជន គឺជាកត្តា

សំខាន់បំផុតក្នុងការទប់ស្កាត់ការកើតឡើងនៃភេរវកម្មក្នុងប្រទេស ក៏ដូចជាទប់ស្កាត់ការអូសទាញប្រជាជនកម្ពុជាឱ្យធ្លាក់ចូលក្នុងក្រុមភេរវករជ្រុលនិយម។ មួយវិញទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់និងបើកចំហយ៉ាងទូលំទូលាយនូវសិទ្ធិសេរីភាពខាងសាសនា ការប្រកាន់យកនិន្នាការនយោបាយផ្សេងៗ ការគោរពប្រពៃណីជនជាតិដើមនីមួយៗដោយពុំមានការរើសអើង ថែមទាំងបានជំរុញនិងលើកទឹកចិត្តឱ្យមានការរស់នៅប្រកបដោយភាពសុខដុម រវាងជនជាតិខ្មែរនិងជនជាតិផ្សេងទៀតនៅកម្ពុជា។ សុខដុមនីយកម្មក្នុងសង្គមនេះហើយដែលធ្វើឱ្យប្រទេសកម្ពុជារួចផុតពីគោលដៅនៃភេរវកម្មអន្តរជាតិនាពេលកន្លងមក។

ទន្ទឹមនឹងនេះ កងយោធពលខេមរភូមិន្ទក៏បង្កើនកិច្ចសហប្រតិបត្តិការក្នុងប្រទេសជាមួយបណ្ដាអង្គភាពនិងស្ថាប័នស៊ីវិលពាក់ព័ន្ធ រួមជាមួយនឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសក្នុងតំបន់អាស៊ាននិងប្រទេសជាដៃគូអន្តរជាតិនានា ក្នុងគោលបំណងទប់ស្កាត់ភេរវកម្មក្នុងប្រទេស និងភេរវកម្មឆ្លងដែន ដោយផ្តោតសំខាន់លើការចែករំលែកព័ត៌មាន ការស្រាវជ្រាវ និងផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក។ កន្លងមក កម្លាំងប្រឆាំងភេរវកម្មនៃកងយោធពលខេមរភូមិន្ទបានបំពេញកិច្ចការជំនាញប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការបង្ការ និងទប់ស្កាត់អំពើភេរវកម្មគ្រប់រូបភាពមិនឱ្យកើតមានឡើងនៅក្នុងប្រទេសនិងបានបង្ក្រាបដល់ឫសគល់ នៃបណ្ដាញនិងក្រុមភេរវករក្នុងប្រទេសដើម្បីបំផ្លាញឱកាសនិងផែនការបង្កអសន្តិសុខ អស្ថិរភាព និងភាពភ័យខ្លាចដល់សង្គមជាតិនាពេលក្រោយទៀត។ ទាំងអស់នេះបង្ហាញឱ្យឃើញពីប្រសិទ្ធភាពនៃការហ្វឹកហ្វឺន និងការត្រៀមលក្ខណៈជាប្រចាំរបស់កម្លាំងប្រឆាំងភេរវកម្ម និងភាពជិតស្និទ្ធនៃកិច្ចសហប្រតិបត្តិការរវាងកងយោធពលខេមរភូមិន្ទជាមួយបណ្ដាស្ថាប័នពាក់ព័ន្ធនានាក្នុងប្រទេសនិងជាមួយបណ្ដាប្រទេសជាដៃគូទាំងក្នុងតំបន់និងសកលលោក។

## ៦- សន្តិសុខលម្ហសមុទ្រ

ស្របតាមទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងសមត្ថភាពគ្រប់គ្រងសមុទ្រកម្ពុជា គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ (គ.ជ.ស.ស.) ត្រូវបាន

បង្កើតឡើងក្នុងខែធ្នូ ឆ្នាំ២០០៩ ដោយផ្តោតភារកិច្ចចម្បងលើការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម អំពើប្លន់តាមសមុទ្រ ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន ឧក្រិដ្ឋកម្មឆ្លងដែន ការនេសាទខុសច្បាប់ ក៏ដូចជាលើការអភិរក្សធនធានធម្មជាតិ និងធ្វើការងារសង្គ្រោះបន្ទាន់នៅក្នុងលម្ហសមុទ្រកម្ពុជា។



ក្នុងសភាពតឹងតែងនៃជំងឺកូវីដ១៩ អ្នកទេសចរណ៍នៃនាវា Westerdam ត្រូវបានស្វាគមន៍ដោយក្តីសណ្តោសប្រកបដោយមនុស្សធម៌ ពីសំណាក់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** (រូបភាព: កងទ័ពជើងអាកាស)

ក្នុងក្របខណ្ឌជាតិ គ.ជ.ស.ស. បានពង្រឹងកិច្ចសហការនិងសហប្រតិបត្តិការជាមួយបណ្តាក្រសួងនិងស្ថាប័នដែលពាក់ព័ន្ធនឹងកិច្ចការសន្តិសុខលម្ហសមុទ្រ ដោយបានសម្របសម្រួលកម្លាំងនិងផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកក្នុងពេលប្រតិបត្តិការបានយ៉ាងមានប្រសិទ្ធភាព។ កន្លងមក គ.ជ.ស.ស. បានអនុវត្តតួនាទីស្នូលរបស់ខ្លួនក្នុងប្រតិបត្តិការដោយទទួលបានប្រសិទ្ធភាពខ្ពស់ ជាពិសេសក្នុងការអនុវត្តភារកិច្ចជាស្ថាប័នដឹកនាំ គ្រប់គ្រង បញ្ជា សម្របសម្រួល និងអនុវត្តច្បាប់ដើម្បីការពារ ទប់ស្កាត់ និងបង្ក្រាបរាល់ការគំរាមកំហែងផ្នែកសន្តិសុខនិងបទល្មើសគ្រប់ប្រភេទ ក៏

ដូចជាការចូលរួមបេសកកម្មមនុស្សធម៌នានាក្នុងដែនសមុទ្រកម្ពុជា។ គួរកត់សម្គាល់ថា តាមរយៈការសហការសម្របសម្រួលពីអន្តរក្រសួងនិងស្ថាប័ននានា កម្ពុជាបានបំពេញបេសកកម្មមនុស្សធម៌ជាប្រវត្តិសាស្ត្រមួយ ដោយបានអនុញ្ញាតិឱ្យនាវាទេសចរណ៍វេស្ទ័រដាម (Westerdam) ចូលចតនៅកំពង់ផែព្រះសីហនុ នាថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ខណៈដែលប្រទេសជាច្រើនបានបដិសេធនាវានេះចូលចត ដោយសារមូលហេតុព្រួយបារម្ភណ៍អំពីការរីករាលដាលនៃជំងឺកូវីដ១៩។ ការទទួលយកនាវាឱ្យចូលចតរបស់រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញពីសុឆន្ទៈយ៉ាងមោះមុតរបស់កម្ពុជាដែលជាប្រទេសតូចនិងធនធានមានកម្រិត ប៉ុន្តែអាចចូលរួមចំណែកយ៉ាងធំធេងសម្រាប់កិច្ចការមនុស្សធម៌អន្តរជាតិ ក៏ដូចជាបញ្ហាសុខុមាលភាពសកល ដោយបានទទួលការគាំទ្រនិងកោតសរសើរលើសលប់ ពីបណ្ដាប្រទេសលើសកលលោក ក៏ដូចជាមជ្ឈដ្ឋានជាតិនិងអន្តរជាតិនានាផងដែរ។

ក្នុងក្របខណ្ឌអន្តរជាតិ គ.ជ.ស.ស. ក៏បានបង្កើននិងលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយប្រទេសជាដៃគូក្នុងតំបន់និងសកលលោក ក្នុងគោលបំណងពង្រីក ពង្រឹងគុណភាព និងប្រសិទ្ធភាព សមត្ថភាពអន្តរប្រតិបត្តិការក្នុងការទប់ស្កាត់ បង្ក្រាប រុករក សង្គ្រោះ និងការអនុវត្តច្បាប់លើដែនសមុទ្រ។ ជាក់ស្តែង គ.ជ.ស.ស. បានចូលរួមយ៉ាងសកម្មជាមួយទីភ្នាក់ងារលម្ហសមុទ្រនៃបណ្តាប្រទេសផ្សេងៗក្នុងកិច្ចសហប្រតិបត្តិការតំបន់និងអនុតំបន់ ដូចជាក្នុងយន្តការក្រុមការងារជំនាញសន្តិសុខលម្ហសមុទ្រ នៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក (ADMM - Plus’s Expert Working Group on Maritime Security) គំនិតផ្តួចផ្តើមឈូងសមុទ្រថៃ (Gulf of Thailand Maritime Law Enforcement Initiative - GOTI) ដែលបច្ចុប្បន្ននេះ បានក្លាយទៅជាគំនិតផ្តួចផ្តើមអនុវត្តច្បាប់លម្ហសមុទ្រអាស៊ីអាគ្នេយ៍ (South-East Asia Maritime Law Enforcement Initiative - SEAMLEI) ជាដើម។ ក្រៅពីនេះ ដោយមានកិច្ចសហការជាមួយបណ្តាប្រទេសជាដៃគូ គ.ជ.ស.ស. បានរៀបរៀងចងក្រងឯកសារគោលមួយចំនួន រួមមានគោលនយោបាយជាតិស្តីពីសន្តិសុខលម្ហសមុទ្រ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខលម្ហសមុទ្រ និងគោលការណ៍អនុវត្តសម្រាប់កិច្ចសហប្រតិបត្តិការសន្តិសុខលម្ហសមុទ្រ។

ទន្ទឹមនឹងភាពរីកចម្រើនទាំងនេះ គ.ជ.ស.ស. ក៏នៅមានភាពប្រឈមមួយចំនួនដែលត្រូវការដោះស្រាយជាបន្ទាន់ ដូចជាប្រសិទ្ធភាពនៃការចែកចាយនិងផ្តល់ព័ត៌មានឱ្យទាន់ហេតុការណ៍ ទាន់ពេលវេលា និងធនធាន សម្ភារៈសម្រាប់ធានាដល់ការធ្វើប្រតិបត្តិការជាដើម ដែលភាពប្រឈមទាំងនេះអាចត្រូវបំពេញបន្ថែមតាមរយៈផែនការទំនើបកម្មកងយោធពលខេមរភូមិន្ទ និងជំនួយគាំទ្រពីបណ្តាប្រទេសជាមិត្ត។

## ៧- ជំនួយមនុស្សធម៌និងសង្គ្រោះគ្រោះមហន្តរាយ

កងយោធពលខេមរភូមិន្ទ មានតួនាទីសំខាន់ក្នុងការសង្គ្រោះពេលមានគ្រោះមហន្តរាយនៅក្នុងប្រទេស ជាពិសេសលើប្រតិបត្តិការស្វែងរកនិងជួយសង្គ្រោះ។ ក្នុងគ្រាមានគ្រោះមហន្តរាយ កងយោធពលខេមរភូមិន្ទមានកាតព្វកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងអស់ ជាពិសេសជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលជាស្ថាប័នសម្របសម្រួលថ្នាក់ជាតិក្នុងការងារសង្គ្រោះ។ កងរាជអាវុធហត្ថ គឺជាកងកម្លាំងនាំមុខក្នុងកិច្ចសហការជាមួយបណ្តាអង្គភាពផ្សេងទៀតក្នុងប្រតិបត្តិការស្វែងរកនិងជួយសង្គ្រោះក្នុងអំឡុងពេលគ្រោះរាំងស្ងួត ក្នុងឆ្នាំ ២០១៦ និងគ្រោះទឹកជំនន់ធ្ងន់ធ្ងរក្នុងឆ្នាំ២០២០។ កិច្ចការនេះបានប្រែក្លាយជាភារកិច្ចចំពោះមុខក្រៅពីភារកិច្ចស្នូលរបស់កងរាជអាវុធហត្ថ ក្នុងការចូលរួមថែរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ។

នៅក្នុងប្រតិបត្តិការប្រយុទ្ធនឹងជំងឺកូវីដ១៩ កងយោធពលខេមរភូមិន្ទបានផ្តល់ជំនួយផ្សេងៗជាច្រើន ដូចជាជំនួយផ្នែកសុខាភិបាល មធ្យោបាយដឹកជញ្ជូនពលករចំណាកស្រុកដែលធ្វើមាតុភូមិនិវត្តន៍ រៀបចំនិងផ្តល់កន្លែងស្នាក់នៅសម្រាប់ការធ្វើចត្តាឡីស័ក និងបានបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋកម្ពុជាដោយមិនប្រកាន់និន្នាការនយោបាយ រួមទាំងជនបរទេសដែលស្នាក់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសក្នុងតំបន់ក្រហមនិងតំបន់មានហានិភ័យខ្ពស់។ ក្នុងប្រតិបត្តិការទាំងនោះបានធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត

យោធិនមួយចំនួនដោយសារការឆ្លងជំងឺនេះ។ ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី កងយោធពលខេមរភូមិន្ទក៏បានចូលរួមជាមួយបណ្តាប្រទេសផ្សេងៗ ជាពិសេសជាមួយប្រទេសជាប់ព្រំដែននិងក្នុងតំបន់ក្នុងរូបភាពជាសមយុទ្ធ និងលំហាត់ហ្វឹកហ្វឺននានា ដែលទាក់ទងនឹងកិច្ចប្រតិបត្តិការសង្គ្រោះពេលមានគ្រោះមហន្តរាយនិងជំនួយមនុស្សធម៌។

នៅក្នុងកិច្ចប្រតិបត្តិការជួយសង្គ្រោះកន្លងមក កងយោធពលខេមរភូមិន្ទនៅមានកង្វះខាតលើផ្នែកមធ្យោបាយ សម្ភារៈ និងជំនាញឯកទេសក្នុងប្រតិបត្តិការមួយចំនួនដូចជា ប្រតិបត្តិការសង្គ្រោះ ការបាក់ស្រុតដួលរលំអគារ និងបាក់ដីជាដើម។ កង្វះខាតទាំងនេះទាមទារឱ្យមានការបំពេញបន្ថែមជាចាំបាច់ ដើម្បីធានាលើការពង្រឹងសមត្ថភាពក្នុងការបំពេញប្រតិបត្តិការនាពេលអនាគត។




ការជួយសង្គ្រោះនៅក្នុងឧប្បត្តិហេតុរលំអាគារ (រូបភាព: អគ្គនាយកដ្ឋានយោធសេវា)

វិវេចនាយុទ្ធសាស្ត្រការពារជាតិឆ្នាំ២០១៣ បានគូសបញ្ជាក់អំពីគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបញ្ជូនកងកម្លាំងចូលរួមប្រតិបត្តិការសង្គ្រោះនៅប្រទេសជិតខាងនិងតំបន់ទាំងមូល ប៉ុន្តែកង្វះខាតលើមធ្យោបាយដឹកជញ្ជូននិងបទពិសោធន៍ក្នុងការសម្របសម្រួល នៅតែជាឧបសគ្គរាំងដល់ការសម្រេចគោល

ដៅនេះ។ កត្តានេះតម្រូវឱ្យមានការកំណត់យុទ្ធសាស្ត្រច្បាស់លាស់ដែលអាចអនុវត្តបាន ដើម្បីឱ្យកងយោធពលខេមរភូមិន្ទអាចចូលរួមក្នុងកិច្ចការដ៏សំខាន់នេះបាន នាពេលអនាគតដ៏ខ្លី។

## ៨- កិច្ចសហប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការអន្តរជាតិ គឺជាវិស័យអាទិភាពសំខាន់មួយ ក្នុងចំណោមគោលដៅយុទ្ធសាស្ត្រនៃកិច្ចការពារជាតិ ដែលបានកំណត់យ៉ាងច្បាស់ក្នុងសៀវភៅសការពារជាតិឆ្នាំ២០០៦ និងវិវេចនាយុទ្ធសាស្ត្រការពារជាតិឆ្នាំ២០១៣ ដែលក្នុងនោះ កងយោធពលខេមរភូមិន្ទត្រូវពង្រីកកិច្ចសហប្រតិបត្តិការយោធាជាមួយបណ្តាប្រទេសជាមិត្ត ដោយផ្អែកលើគោលជំហរមិនប្រកាន់និន្នាការនយោបាយ ឬមនោគមន៍វិជ្ជា ឈរលើស្មារតីស្មើភាព ស្មើសិទ្ធិ និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។ អនុលោមតាមគោលដៅយុទ្ធសាស្ត្រដែលបានកំណត់ កងយោធពលខេមរភូមិន្ទ បានពង្រឹងនិងពង្រីកទំនាក់ទំនងការទូតយោធានិងកិច្ចសហប្រតិបត្តិការថ្មីៗជាមួយបណ្តាប្រទេសទាំងក្នុងតំបន់និងសកលលោកគួរឱ្យកត់សម្គាល់។

ចាប់ពីឆ្នាំ២០០៦ កិច្ចសហប្រតិបត្តិការយោធាជាមួយបរទេសមានការរីកចម្រើនជាលំដាប់ ជាពិសេសក្នុងវិស័យកសាងសមត្ថភាពយោធិននិងជំនួយផ្នែកបច្ចេកទេសផ្សេងៗក្នុងគោលដៅអភិវឌ្ឍន៍សមត្ថភាពការពារជាតិ ក៏ដូចជាសមត្ថភាពទប់ស្កាត់និងឆ្លើយតបបញ្ហាប្រឈមសន្តិសុខនានា។ ជាក់ស្តែងក្រសួងការពារជាតិបានបញ្ជូនយោធិនទាំងថ្នាក់យុទ្ធសាស្ត្រ និងថ្នាក់ប្រតិបត្តិការទៅចូលរួមវគ្គហ្វឹកហ្វឺននិងបណ្តុះបណ្តាលទាំងរយៈពេលខ្លីនិងវែងនៅក្រៅប្រទេស ហើយក៏មានការទទួលយកសិក្ខាកាមយោធាបរទេសមកសិក្សានៅកម្ពុជាផងដែរ។ ការផ្លាស់ប្តូរសិក្ខាកាមយោធា គឺក្នុងទិសដៅកសាងទំនាក់ទំនងស្និតល្មួតជាមួយបណ្តាប្រទេសជាមិត្តនិងដើម្បីផ្លាស់ប្តូរពិសោធន៍ ចំណេះដឹង និងជំនាញទៅវិញទៅមកលើវិស័យការពារជាតិនិងសន្តិសុខ។

សម្រាប់កិច្ចសហប្រតិបត្តិការយោធាទ្វេភាគី កងយោធពលខេមរភូមិន្ទអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវយន្តការនិងបទដ្ឋានគតិយុត្តដែលមានស្រាប់ មានជាអាទិ៍ កិច្ចព្រម

ព្រៀងប្រចាំឆ្នាំនៃសហប្រតិបត្តិការយោធាជាមួយប្រទេសចិន អនុសញ្ញាជាមួយប្រទេសបារាំង ពិធីសារប្រចាំឆ្នាំជាមួយប្រទេសវៀតណាម អនុស្សរណៈនៃការយោគយល់ជាមួយប្រទេសរុស្ស៊ី ជប៉ុន និងសាធារណរដ្ឋកូរ៉េ យន្តការកិច្ចសហប្រតិបត្តិការយោធាជាមួយប្រទេសអូស្ត្រាលីនិងអាមេរិក កិច្ចសហប្រតិបត្តិការយោធាតាមការជាក់ស្តែងជាមួយបណ្តាប្រទេសមួយចំនួនទៀត។ល។

ក្នុងកិច្ចសហប្រតិបត្តិការយោធាតំបន់និងអនុតំបន់ កងយោធពលខេមរភូមិន្ទបានចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការនានា ក្រោមក្របខណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM) កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក (ADMM-Plus) វេទិកាតំបន់អាស៊ាន (ARF)។ល។ ជាងនេះទៅទៀត កម្ពុជាគឺជាតួអង្គសកម្មក្នុងការជំរុញបង្កើតកិច្ចសហប្រតិបត្តិការជាក់ស្តែងនានា នៃក្រុមការងារជំនាញកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក (ADMM-Plus Expert Working Groups - EWGs) និងការបង្កើតយន្តការគំនិតផ្តួចផ្តើមឈូងសមុទ្រថៃ (Gulf of Thailand Maritime Law Enforcement Initiative - GOTI) ដែលបន្ទាប់មកបានក្លាយទៅជាគំនិតផ្តួចផ្តើមអនុវត្តច្បាប់សមុទ្រអាស៊ីអាគ្នេយ៍ (South-East Asia Maritime Law Enforcement Initiative SEAMLEI) ជាដើម។ ការចូលរួមបង្កើតយន្តការទាំងនេះ គឺក្នុងគោលដៅជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែង និងភាពជាដៃគូរឹងមាំជាមួយបណ្តាប្រទេសក្នុងតំបន់ ព្រមទាំងលើកកម្ពស់សមត្ថភាពអន្តរប្រតិបត្តិការ ដើម្បីឆ្លើយតបរួមគ្នាទៅនឹងបញ្ហាប្រឈមផ្នែកសន្តិសុខដែលកើតមាន ក្នុងពេលបច្ចុប្បន្ននិងអនាគត។ កិច្ចសហប្រតិបត្តិការយោធាជាមួយប្រទេសជាដៃគូកន្លងមក គឺស្ថិតក្នុងទិសដៅច្បាស់លាស់ ដើម្បីលើកកម្ពស់សមត្ថភាពរបស់កងយោធពលខេមរភូមិន្ទដោយផ្អែកលើគោលការណ៍ស្មើភាព គោរពឯករាជ្យ អធិប្បតេយ្យភាព និងផលប្រយោជន៍គ្នាទៅវិញទៅមក។

ថ្នាក់ដឹកនាំក្រសួងការពារជាតិនិងអគ្គបញ្ជាការដ្ឋាន តែងតែបានរួមចំណែកយ៉ាងសំខាន់ក្នុងការចែករំលែកទស្សនៈ ស្តីពីវិស័យការពារជាតិនិងសន្តិសុខក្នុងកិច្ចសន្ទនាការពារជាតិជាន់ខ្ពស់ទាំងថ្នាក់តំបន់និងអន្តរជាតិ ដូចជាកិច្ចសន្ទនាសាំងហ្គ្រីឡា (Shangri-La Dialogue) វេទិកាសន្តិសុខសៀងសាន (Beijing Xiangshan Forum)

កិច្ចសន្ទនាការពារជាតិក្រុងសេអ៊ូល (Seoul Defence Dialogue) វេទិកាការពារជាតិក្រុងតូក្យូ (Tokyo Defence Forum) ជាដើម។ ក្រៅពីនេះ កម្ពុជាបានចែករំលែកបទពិសោធន៍ និងឧត្តមានុវត្តន៍ពាក់ព័ន្ធនឹងការចូលរួមរបស់កងយោធពលខេមរភូមិន្ទក្នុងការអនុវត្តគោលនយោបាយឈ្នះ ឈ្នះ របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានបញ្ចប់សង្គ្រាមរ៉ាំរ៉ៃនិងនាំមកនូវសន្តិភាពពេញលេញនិងអភិវឌ្ឍន៍ជាតិ។




**សម្តេចពិជ័យសេនា ទៀ បាញ់** តំណាង **សម្តេចតេជោ ហ៊ុន សែន** នាំយកសម្ភារប្រឆាំងកូវីដ១៩ ជូនដល់សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ (រូបភាព: ពីប្រទេសឡាវ)

ទន្ទឹមនឹងការរីកចម្រើនលើវិស័យកិច្ចសហប្រតិបត្តិការយោធាកន្លងមក ការលេចឡើងនូវជំងឺកូវីដ១៩ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ បានក្លាយជាបញ្ហាប្រឈមចម្បងមួយដែលធ្វើឱ្យមានការរាំងស្ទះមួយចំនួនដល់ដំណើរការនេះ។ ជាក់ស្តែង កូវីដ១៩បានធ្វើឱ្យការផ្លាស់ប្តូរទស្សនកិច្ចយោធា ការធ្វើលំហាត់រួមគ្នា កិច្ចប្រជុំថ្នាក់តំបន់ និងអន្តរជាតិស្ទើរតែទាំងស្រុងត្រូវបានផ្អាក និងផ្លាស់ប្តូរទម្រង់ពីអន្តរកម្មដោយផ្ទាល់ទៅជាការចូលរួមតាមប្រព័ន្ធវីដេអូពីចម្ងាយ។ បញ្ហាប្រឈមនេះ បាន

ធ្វើឱ្យផែនការការងារនៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាដៃគូមួយចំនួន ត្រូវបានពន្យារពេលឬពុំអាចអនុវត្តបាន។

ទោះជាដូច្នេះក្តី កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កងយោធពលខេមរភូមិន្ទគ្រប់កម្រិតកន្លងមកបានលើកកម្ពស់ការកសាងទំនុកចិត្តក្នុងតំបន់ ក៏ដូចជាអភិវឌ្ឍសមត្ថភាពកងទ័ព និងសម្រេចបាននូវវិធីសាស្ត្ររួមក្នុងការរក្សាការពារសន្តិភាព សន្តិសុខ និងស្ថិរភាពនៅក្នុងតំបន់ទាំងមូល។ យើងជឿជាក់ថា ភាពប្រឈមនិងការគំរាមកំហែងរបស់ពិភពលោក ពិតជាមិនអាចដោះស្រាយបានដោយប្រទេសណាមួយតែឯងនោះទេ គឺតម្រូវឱ្យមានការសហការស៊ីជម្រៅក្នុងចំណោមបណ្តាប្រទេសជាដៃគូ។

## ៩- ការគ្រប់គ្រងធនធានការពារជាតិ

ធនធានការពារជាតិរបស់កងយោធពលខេមរភូមិន្ទ រួមមាន យុទ្ធោបករណ៍ សម្ភារៈសឹក សម្ភារៈសុខាភិបាល សម្ភារៈរដ្ឋបាល គ្រឿងចក្រ របបទ្រទ្រង់ភ័ស្តុភារ ហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀតដែលជាមូលដ្ឋានក្នុងការបំពេញកាតព្វកិច្ចរបស់កងយោធពលខេមរភូមិន្ទ ត្រូវបានគ្រប់គ្រង ថែទាំ បំពាក់ថ្មី និងប្រើប្រាស់បានចំគោលដៅនិងប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងធានាបានប្រៀបការពារជាតិ។

ទន្ទឹមនឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈដែលមានស្រាប់ កងយោធពលខេមរភូមិន្ទបានកសាងនូវសមិទ្ធផលថ្មីៗ ជាអាទិ៍ អាគារក្រសួងការពារជាតិ អាគារទីបញ្ជាការកងឯកភាពនានា ការពង្រីកប្រព័ន្ធស្ថានីយវិទ្យុទាក់ទងតាមភូមិភាគ និងការបង្កើនប្រព័ន្ធរ៉ាដាការពារអាកាស។ល។ លើសពីនេះទៀត យុទ្ធោបករណ៍មួយចំនួនដូចជា រថយន្តដឹកជញ្ជូននិងសម្ភារៈសុខាភិបាល សម្ភារៈបច្ចេកទេស យោធបរិក្ខារ សម្ភារៈសឹកមួយចំនួនត្រូវបានបំពាក់បន្ថែមដើម្បីបំពេញនូវតម្រូវការជាក់ស្តែងតាមរយៈការបញ្ជាទិញ ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្តល់ជំនួយជាបន្តបន្ទាប់ពីបណ្តាប្រទេសជាមិត្តនិងប្រទេសជាដៃគូ។

## ១០- ការចូលរួមចំណែកអភិវឌ្ឍជាតិ និងហេដ្ឋារចនាសម្ព័ន្ធ

កងយោធពលខេមរភូមិន្ទ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍជាតិនិងលើកកម្រិតជីវភាពប្រជាពលរដ្ឋ តាមរយៈការកសាងនិងស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ កងយោធពលខេមរភូមិន្ទ បានបំពេញកាតព្វកិច្ចដ៏ឧត្តុង្គឧត្តមរបស់ខ្លួន ក្នុងការចូលរួមចំណែកបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដោយរួមសហការជាមួយប្រតិបត្តិករជាតិនិងអន្តរជាតិ ក្នុងការរំដោះផ្ទៃដីដែលមានគ្រាប់មីនរយៈពេល ២៩ឆ្នាំ (គិតពីឆ្នាំ១៩៩២-២០២១) បានទំហំ ២.៣២៥គីឡូម៉ែត្រក្រឡា និងបានកាត់បន្ថយអត្រាជនរងគ្រោះថ្នាក់ដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបានជាអតិបរមា បានថយចុះពី៤.៣២០នាក់ ក្នុងឆ្នាំ១៩៩៣ មកនៅត្រឹម៤៤នាក់ ក្នុងឆ្នាំ២០២១។ កងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ គឺជាកម្លាំងស្នូលនិងនាំមុខ នៅក្នុងការកសាងផ្លូវគមនាគមន៍រាប់ពាន់គីឡូម៉ែត្រ តាមបណ្តាយព្រំដែន ដែលមានសារៈសំខាន់បំផុត សម្រាប់ការពង្រឹងប្រព័ន្ធការពារព្រំដែន និងការពង្រីកសហគមន៍ទំនាក់ទំនង និងការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅតំបន់ព្រំដែន។

ទន្ទឹមនឹងនេះ កងយោធពលខេមរភូមិន្ទក៏បានពង្រឹងនិងពង្រីកទំនាក់ទំនងយោធាជាមួយស្ថាប័នស៊ីវិល ដែលជាទំនាក់ទំនងមួយមិនអាចកាត់ផ្តាច់បានក្នុងការទ្រទ្រង់ធនធានការពារជាតិ ក៏ដូចជាការពង្រឹងការចូលរួមរបស់ស្ថាប័នស៊ីវិល និងប្រជាជនជាខឿនការពារជាតិទាំងមូល។ កាតព្វកិច្ចនេះ ជាសម្ព័ន្ធភាពការងារដែលត្រូវរក្សាឱ្យបានស្ថិតស្ថេរគ្រប់ពេលវេលា ដើម្បីជំរុញប្រសិទ្ធភាពនិងគុណភាពលើភាពជាដៃគូរវាងបណ្តាស្ថាប័នយោធានិងស្ថាប័នស៊ីវិលក្នុងកិច្ចការពារជាតិ ថែរក្សាសន្តិភាព សន្តិសុខ និងវិបុលភាពជាតិឱ្យបានស្ថិតស្ថេរ។




សមិ្ទផលថ្មីរបស់ក្រសួងការពារជាតិ (រូបភាព: ក្រុមហ្វេសប៊ុកសម្ដេចពិជ័យសេនា)

# ជំពូក២
# ចក្ខុវិស័យយុទ្ធសាស្ត្រ

វិស័យយោធាក្នុងតំបន់និងសកលលោក មានការវិវត្តស្មុគស្មាញឥតឈប់ឈរ ដែលអាចជះឥទ្ធិពលដល់វិស័យការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ការប្រែប្រួលទាំងនេះ តម្រូវមានការគិតគូរម៉ត់ចត់អំពីចក្ខុវិស័យយុទ្ធសាស្ត្រការពារជាតិ។ ចំពោះស្ថានភាពសន្តិសុខតំបន់និងសកលលោក នយោបាយអនុត្តរភាពនិងការប្រកួតប្រជែងភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ចរបស់មហាអំណាច នៅតែបន្តកើនឡើង ដែលជាទំនោរទៅរកការរីកសាយនៃបច្ចេកវិទ្យានុយក្លេអ៊ែរ ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ការធ្វើសង្គ្រាមពាណិជ្ជកម្ម ការលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ការប្រកួតប្រជែងឥទ្ធិពលយោធាក្នុងដែនសមុទ្រ ការបង្កើតសម្ព័ន្ធភាពយោធាថ្មីៗមួយចំនួន ការបង្កើនការចំណាយយោធា និងការបញ្ចូលបច្ចេកវិទ្យាថ្មីៗទៅក្នុងវិស័យការពារជាតិជាដើម។ លើសពីនេះទៀត ភាពប្រឈមជាសកលនៃសន្តិសុខបរិស្ថាននិងបម្រែបម្រួលអាកាសធាតុ ដែលបង្កឡើងដោយកត្តាមនុស្សនិងធម្មជាតិក៏ជាកង្វល់ដ៏ធំមួយផងដែរ។ កម្ពុជាកំពុងទទួលរងឥទ្ធិពលពីបរិបទសកលទាំងនេះ ដែលទាមទារឱ្យមានការដាក់ចេញនូវផែនការយុទ្ធសាស្ត្រឆ្លើយតប ដើម្បីរក្សាការពារសុខសន្តិភាព ផលប្រយោជន៍ជាតិ និងការអភិវឌ្ឍប្រទេសតាមរយៈការសិក្សាស្រាវជ្រាវនិងវិភាគសភាពការណ៍ជាលក្ខណៈយុទ្ធសាស្ត្រ។

## ១- ការវិភាគស្ថានការណ៍សន្តិសុខ

### ក- សកលលោក

ភាពស្មុគស្មាញនិងការប្រែប្រួលឥតឈប់ឈរ នៃស្ថានការណ៍សន្តិសុខសកលលោក បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាពតំបន់ និងសកលលោកទាំងមូលក្នុងរយៈពេលយូរអង្វែងទៅអនាគត។ បរិបទនេះបានបង្ហាញឱ្យឃើញតាមរយៈការប្រកួតប្រជែងកាន់តែស្វិតស្វាញរវាងប្រទេសមហាអំណាច ដោយមានការ

ចូលរួមដោយផ្ទាល់និងប្រយោល ពីប្រទេសមហាអំណាចថ្នាក់កណ្តាលនិងអំណាចក្នុងតំបន់ ដែលអាចឈានទៅរកការលេចឡើងនូវពិភពលោកពហុប៉ូល។ ការវិវត្តទាំងនេះអាចជាកាលានុវត្តភាពសម្រាប់កម្ពុជាផង និងជាហានិភ័យឬក៏ជាការគំរាមកំហែងចំពោះសន្តិសុខនិងផលប្រយោជន៍ជាតិរបស់កម្ពុជាផងដែរ។

នាពេលបច្ចុប្បន្នក៏ដូចជាមួយទសវត្សរ៍ខាងមុខ ការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយនិងការប្រកួតប្រជែងនៃប្រទេសមហាអំណាចនឹងបន្តកើតឡើង លើគ្រប់វិសាលភាពនិងគ្រប់តំបន់ ដែលធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ដល់វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម បច្ចេកវិទ្យាជាដើម។ ក្នុងនោះការរីកចម្រើនលើវិស័យយោធានៃសកលលោកក៏ជាក្តីបារម្ភធំបំផុត រួមទាំងកង្វះការប្តេជ្ញាចិត្តក្នុងកិច្ចសហប្រតិបត្តិការជាក់ស្តែងដែលនឹងជះឥទ្ធិពលដល់សន្តិសុខផងដែរ។ ទោះយ៉ាងណាក៏ដោយ សភាពការណ៍សន្តិសុខសកលលោកនាពេលបច្ចុប្បន្ន និងទៅអនាគតនឹងជួបប្រទះប្រធានបទផ្សេងៗជាច្រើន ក្រៅពីសន្តិសុខប្រពៃណី រួមមានការគំរាមកំហែងរបស់តួអង្គមិនមែនរដ្ឋ (Non-state Actors) ឧក្រិដ្ឋកម្មឆ្លងដែន ភេរវកម្ម សន្តិសុខបច្ចេកវិទ្យាព័ត៌មាន ជំងឺឆ្លងរាតត្បាតជាសកល និងការគំរាមកំហែងដែលអាចបង្កឡើងដោយបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (Artificial Intelligence-AI) ជាដើម។

ទន្ទឹមនឹងនេះ សន្តិសុខបរិស្ថាននិងបម្រែបម្រួលអាកាសធាតុ កំពុងប្រែក្លាយជាកង្វល់មួយរបស់ពិភពលោក ជាពិសេសប្រទេសដែលរងផលប៉ះពាល់ដោយផ្ទាល់ពីបម្រែបម្រួលអាកាសធាតុ។ ពិភពលោកទាំងមូលចាំបាច់ត្រូវទទួលស្គាល់ពីផលប៉ះពាល់យូរអង្វែងដោយការបំពុលបរិស្ថាននិងការកើនកម្តៅផែនដី ដែលជាហេតុនាំឱ្យមានការកើនឡើងកម្ពស់ទឹកសមុទ្រ ភាពរាំងស្ងួត កង្វះទឹកសាប និងគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរដែលកំពុងកើតមានឡើង។ ជារួម ការគំរាមកំហែងលើសន្តិសុខ បរិស្ថាន និងបម្រែបម្រួលអាកាសធាតុអាចបង្កគ្រោះថ្នាក់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងនយោបាយក្នុងប្រទេសក៏ដូចជាក្នុងតំបន់ ហើយអាចឈានទៅរកជម្លោះប្រដាប់អាវុធទៀតផង។ កត្តានេះទាមទារឱ្យស្ថាប័នយោធាត្រូវយកចិត្តទុកដាក់គិតគូរឱ្យបានហ្មត់ចត់និងត្រៀមខ្លួនជាប់ជានិច្ចក្នុងការឆ្លើយតប។

## ខ- តំបន់

រលកនិងឥទ្ធិពលនៃការវិវត្តនិងបម្រែបម្រួលឥតឈប់ឈរ នៃស្ថានការណ៍សន្តិសុខសកលលោក ក៏អាចបង្កជាផលប៉ះពាល់ដល់ស្ថានការណ៍សន្តិសុខតំបន់ផងដែរ។ តួនាទីនិងទំនាក់ទំនងរវាងប្រទេសមហាអំណាចធំៗ ក្នុងការពង្រីកដែនឥទ្ធិពលនិងការក្តោបក្តាប់ភូមិសាស្ត្រនយោបាយ នៅតែជាភាពប្រឈមផ្នែកយុទ្ធសាស្ត្រយ៉ាងសំខាន់សម្រាប់តំបន់អាស៊ីអាគ្នេយ៍ទាំងមូល។ បរិបទមួយនេះ មិនត្រឹមតែបង្កនូវភាពតានតឹងយូរអង្វែងនៅក្នុងតំបន់ប៉ុណ្ណោះទេ ថែមទាំងអាចរីករាលដាលដល់បរិបទផ្សេងទៀតមានជាអាទិ៍ សន្តិសុខលម្ហសមុទ្រ សេដ្ឋកិច្ច បច្ចេកវិទ្យា ទំនាក់ទំនងអន្តរជាតិ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាដើម។ គួបផ្សំនឹងភាពប្រឈមនិងការគំរាមកំហែងសន្តិសុខដែលមានស្រាប់ក្នុងតំបន់ កត្តាទាំងនោះនឹងនាំឱ្យមានភាពស្មុគស្មាញនិងបម្រែបម្រួលដែលមិនអាចប៉ាន់ស្មានទុកបាន។ ក្នុងន័យនេះ ការគំរាមកំហែងក្នុងបរិបទសន្តិសុខមិនមែនប្រពៃណីនិងបរិបទភូមិសាស្ត្រនយោបាយ ក៏ជាប្រធានបទក្តៅដែលទាមទារឱ្យបណ្តាប្រទេសក្នុងតំបន់យកចិត្តទុកដាក់និងរួមសហការគ្នា ដើម្បីត្រៀមទប់ទល់និងឆ្លើយតបក្នុងស្មារតីឈរលើគោលការណ៍ច្បាប់និងសណ្តាប់ធ្នាប់អន្តរជាតិ ជាពិសេសគោលការណ៍ដោះស្រាយជម្លោះដោយសន្តិវិធី។

សមុទ្រចិនខាងត្បូងនាពេលកន្លងមក បានក្លាយជាសមរភូមិភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច និយាយជារួម និងជាតំបន់ជម្លោះប្រទាញប្រទង់រវាងប្រទេសមួយចំនួនក្នុងការកាន់កាប់ដែនអធិបតេយ្យ និយាយដោយឡែក។ ការប្រកួតប្រជែងឥទ្ធិពលរបស់ប្រទេសមហាអំណាចក្នុងសមុទ្រចិនខាងត្បូង និងវិវាទនៃការទាមទារកាន់កាប់ដែនកោះ ប្រភពធនធានធម្មជាតិក្នុងផ្ទៃសមុទ្រ និងការគ្រប់គ្រងលម្ហសមុទ្រនៅតែជាបញ្ហាដ៏ស្មុគស្មាញសម្រាប់តំបន់ទាំងមូល។ បញ្ហានេះ ទាមទារឱ្យអ្នកដែលពាក់ព័ន្ធមានការដោះស្រាយ ដោយប្រកាន់យកគោលការណ៍សន្តិវិធី ការយោគយល់គ្នាទៅវិញទៅមក និងការគោរពផលប្រយោជន៍រួម។ ការអត់ធ្មត់ ការចរចា និងការព្យាយាមរកវិធីដោះស្រាយដោយសន្តិវិធី នៅតែជា

មធ្យោបាយដ៏ប្រសើរបំផុត នៅក្នុងការបន្ធូរបន្ថយភាពតានតឹង និងទប់ស្កាត់អាវុធនុយក្លេអ៊ែរ នៅតំបន់ឧបទ្វីបកូរ៉េ។ គំនិតផ្តួចផ្តើមឥណ្ឌូប៉ាស៊ីហ្វិកអាចទទួលបានការអបអរសាទរ ខណៈដែលបម្រើឲ្យការពង្រឹងសន្តិភាព ស្ថិរភាព និងវិបុលភាព នៅក្នុងតំបន់។ ផ្ទុយទៅវិញ បើសិនជាគំនិតផ្តួចផ្តើមនេះ មានបំណងបំផ្លិចបំផ្លាញផលប្រយោជន៍នៃប្រទេសណាមួយ នោះពុំគួរត្រូវបានស្វាគមន៍ឡើយ។

កត្តាផ្សេងទៀត ដែលនឹងនៅតែជាភាពប្រឈមនិងជាការគំរាមកំហែងដែលប្រទេសក្នុងតំបន់ត្រូវតាមដាននិងយកចិត្តទុកដាក់នោះ មានអំពើភេរវកម្ម សន្តិសុខបច្ចេកវិទ្យាព័ត៌មាន គ្រោះមហន្តរាយធម្មជាតិ ជំងឺឆ្លងរាតត្បាតជាសកលជាដើម។ ទោះបីជាអង្គការភេរវកម្មធំៗ និងបណ្តាញភេរវកម្មនៅតំបន់មជ្ឈឹមបូព៌ាត្រូវបានផ្តួលរំលំជាបន្តបន្ទាប់ ក៏មិនបានសេចក្តីថា ការគំរាមកំហែងពីភេរវកម្មត្រូវបានរលត់សាបសូន្យនោះទេ។ ការដួលរលំនៃអង្គការភេរវកម្មទាំងនោះបន្សល់ទុកនូវសកម្មជនដែលមានលទ្ធភាពបន្តសកម្មភាពភេរវកម្មផ្សេងទៀត នៅថ្ងៃក្រោយ ជាពិសេស ការវិលត្រលប់មកវិញនៃសកម្មជនប្រយុទ្ធចូលមកក្នុងប្រទេសដើមកំណើតរបស់ពួកគេវិញ ក្នុងនោះមានប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ផងដែរ។ ក្នុងន័យនេះហើយ ដែលលទ្ធភាពនៃការគំរាមកំហែងនៅតែមាន ដោយសារសកម្មជនប្រយុទ្ធទាំងនោះ អាចសម្ងំលាក់ខ្លួនដើម្បីប្រមូលផ្តុំកម្លាំងនិងធ្វើផែនការមុននឹងឈានដល់ការវាយប្រហារតាមគោលដៅនានាតាមបណ្តាប្រទេសក្នុងតំបន់។ ក្រៅពីភេរវកម្ម ការគំរាមកំហែងក្នុងយុគសម័យថ្មីដែលគ្មានរូបរាង គ្មានស្រមោលនោះ គឺការវាយប្រហារដោយប្រើបច្ចេកវិទ្យាព័ត៌មាន។ អាស៊ីអាគ្នេយ៍នាពេលនេះ គឺជាមជ្ឈមណ្ឌលនៃសេដ្ឋកិច្ច ពាណិជ្ជកម្ម យោធា បច្ចេកវិទ្យា និងការអភិវឌ្ឍនៃវិស័យដទៃទៀត។ ការវាយប្រហារតាមរយៈបច្ចេកវិទ្យាព័ត៌មានពីសំណាក់បុគ្គលនិងតួអង្គមិនមែនរដ្ឋទៅលើស្ថាប័នសំខាន់ៗ នឹងបង្កជាការគំរាមកំហែងដ៏ធំធេងដល់ចលនាសេដ្ឋកិច្ច លំហូរពាណិជ្ជកម្ម និងវិស័យការពារជាតិនៅតាមបណ្តាប្រទេសធំៗក្នុងតំបន់ ដែលនឹងប៉ះពាល់ដល់សន្តិសុខនិងផលប្រយោជន៍រួមនៃតំបន់ទាំងមូលដោយជៀសមិនផុត។

ការគំរាមកំហែងផ្សេងទៀត រួមមានជំងឺឆ្លងរាតត្បាតជាសកលដែលកើតឡើងដោយសារការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យានិងវេជ្ជសាស្ត្រ ការវិវត្តជាលំដាប់នៃធម្មជាតិនិងគ្រោះមហន្តរាយធម្មជាតិ។ ផលប៉ះពាល់នៃការគំរាមកំហែងទាំងពីរប្រភេទនេះនឹងផ្តល់ផលអវិជ្ជមាន និងភាពប្រឈមដល់វិស័យសុខាភិបាលនិងសុខភាពសាធារណៈ របៀបរបប និងគន្លងនៃការរស់នៅរបស់ប្រជាជន សន្តិសុខមនុស្សជាតិ និងជាពិសេសសន្តិសុខស្បៀងអាហារទៅថ្ងៃអនាគត។ ក្នុងករណីដែលវិបត្តិជំងឺឆ្លងរាតត្បាតជាសកលមិនត្រូវបានទប់ស្កាត់ និងដោះស្រាយប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា វិស័យសេដ្ឋកិច្ចនិងពាណិជ្ជកម្មនៃតំបន់ទាំងមូលនឹងមានផលប៉ះពាល់ក្នុងកម្រិតមួយដែលនឹងទាមទារពេលវេលាច្រើនឆ្នាំ ដើម្បីស្តារឡើងវិញ។

## ២- ការវាយតម្លៃការគំរាមកំហែងមកលើសន្តិសុខជាតិ

### ក- វិទ្ធង្សនា

វិទ្ធង្សនានៅក្នុងប្រទេសកម្ពុជាបានកើតឡើងជាច្រើនរូបភាពខុសៗគ្នា ដូចជាបដិវត្តន៍ពណ៌ ការញុះញង់ឱ្យស្អប់ខ្ពើមជាតិសាសន៍និងសាសនា ការញុះញង់ឱ្យមានការរើសអើងវណ្ណៈក្នុងសង្គម ការញុះញង់ឱ្យមានការប្រឆាំងនឹងរាជរដ្ឋាភិបាល ការបង្កើតរូបភាពអសកម្មក្នុងសង្គម ការបង្កើតព័ត៌មានក្លែងក្លាយ ការធ្វើកុបកម្មនិងបាតុកម្មហិង្សា ការអុជអាលប្រជាជនឱ្យលែងជឿជាក់លើការដោះស្រាយកិច្ចការរបស់រាជរដ្ឋាភិបាលលើបញ្ហាសង្គមនិងបញ្ហាជាតិនានា ដែលជាការកេងចំណេញផ្នែកនយោបាយជាដើម។

ម្យ៉ាងវិញទៀត ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជានៅបន្តមានតាមរយៈការផ្តល់ប្រភពធនធានហិរញ្ញវត្ថុនិងការគាំទ្រផ្នែកនយោបាយ ពីសំណាក់ខាងក្រៅមកក្នុងប្រទេស ក្រោមរូបភាពការងារសង្គមនិងបរិស្ថាន ក្នុងគោលបំណងញុះញង់បំផុសមហាជនឱ្យមានកំហឹង មានការភាន់ច្រឡំមកលើកិច្ចការនិងដំណោះស្រាយរបស់រាជរដ្ឋាភិបាល ដើម្បីបង្កចលាចលក្នុងសង្គម។ ចំណុចស្នូលនៃការ

ជ្រៀតជ្រែកពីខាងក្រៅ គឺខិតខំញែកកម្លាំងប្រដាប់អាវុធឱ្យនៅជាអព្យាក្រឹត្យ។ លើសពីនេះទៀត ការឃោសនាបំផុសដល់ប្រជាជនអំពីសិទ្ធិមនុស្សនិងសិទ្ធិសេរីភាពគ្រប់បែបយ៉ាង បង្កឱ្យមានចលនាបាតុកម្មអហិង្សាក្តី ហិង្សាក្តី ក្នុងគោលបំណងប្តូររបបដឹកនាំប្រទេសដែលធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈ ធ្វើឱ្យប៉ះពាល់ដល់សន្តិភាព គឺជាការគំរាមកំហែងមកលើសន្តិសុខជាតិ ដែលបណ្តាលមកពីការងើបឡើងវិញនៃចលនាបដិវត្តន៍ពណ៌នេះ នៅថ្ងៃអនាគត។

## ខ- សន្តិសុខព្រំដែនគោក

ព្រះរាជាណាចក្រកម្ពុជាតែងតែយកចិត្តទុកដាក់ខ្ពស់ លើបញ្ហាសន្តិសុខព្រំដែននិងប្តេជ្ញាថែរក្សាការពារឱ្យបានគត់មត់តំបន់ព្រំដែន ក្នុងគោលបំណងធានានូវសន្តិសុខ ស្ថិរភាព និងសុវត្ថិភាពដែលជាកត្តាចាំបាច់ក្នុងការជំរុញអភិវឌ្ឍន៍លើគ្រប់វិស័យ ជាពិសេសលើវិស័យសេដ្ឋកិច្ចនិងទេសចរណ៍។ កម្ពុជាមើលឃើញវិបត្តិដែលអាចកើតឡើងជាយថាហេតុជាមួយបណ្តាប្រទេសជាប់ព្រំដែន ដូចជាការឆ្លងដែនខុសច្បាប់និងឧក្រិដ្ឋកម្មឆ្លងដែន ដែលជាការគំរាមកំហែងដល់សន្តិសុខនិងស្ថិរភាពនៃតំបន់ព្រំដែនដែលនាំឱ្យប៉ះពាល់ដល់សន្តិសុខប្រទេសជាតិទាំងមូល។

ម្យ៉ាងវិញទៀត វិវាទនៅតាមតំបន់ព្រំដែនដោយសារភាពមិនច្បាស់លាស់ នៃការកំណត់ខ្សែបន្ទាត់ព្រំដែននៅតំបន់មួយចំនួនដែលមិនទាន់បានបោះបង្គោលនិងការប្រើប្រាស់ផែនទីមិនផ្លូវការជាលក្ខណៈឯកតោភាគី ការផ្លាស់ប្តូររបៀបវារៈនយោបាយ ការកេងប្រវ័ញ្ចផលប្រយោជន៍ ការបំផុសនូវគំនិតជាតិនិយមជ្រុលនៃប្រទេសជាប់ព្រំដែន អាចបង្កទៅជាការរំលោភបំពានចូលដែនដីអធិបតេយ្យភាគីម្ខាងទៀត តាមរូបភាពផ្សេងៗ រហូតមានការចោទប្រកាន់ទៅវិញទៅមក និងគេចវេះចេញពីការដោះស្រាយតាមច្បាប់អន្តរជាតិ ហើយអាចបង្កជាជម្លោះទៀតផង។ ឧក្រិដ្ឋកម្មឆ្លងដែន ដូចជាការជួញដូរខុសច្បាប់គ្រប់រូបភាពនិងការឆ្លងដែនខុសច្បាប់ ដែលអាចនាំមកនូវលំហូរជនអន្តោប្រវេសន៍មួយចំនួន ព្រមទាំងការគ្រប់គ្រងមិនបានល្អនូវវិធានការទប់ស្កាត់ការរាលដាលនៃជំងឺឆ្លងរាតត្បាតក៏អាចជះឥទ្ធិពលដល់សន្តិសុខជាតិ ស្ថិរភាពជាតិ និងសណ្តាប់ធ្នាប់សាធារណៈផងដែរ។

## គ- សន្តិសុខលម្ហសមុទ្រ

ចរាចរណ៍លើផ្ទៃសមុទ្រ ត្រូវបានចាត់ទុកជាផ្លូវដង្ហើមយុទ្ធសាស្ត្រនៃសេដ្ឋកិច្ច ដោយសារការដឹកជញ្ជូនដើម្បីផ្គត់ផ្គង់ពិភពលោកស្ទើរតែទាំងស្រុងប្រព្រឹត្តិទៅលើផ្ទៃសមុទ្រ ហើយក្រៅពីនេះ ធនធានធម្មជាតិជាច្រើនប្រភេទ ក៏ស្ថិតនៅក្នុងសមុទ្រផងដែរ។ ហេតុដូចនេះហើយ ព្រះរាជាណាចក្រកម្ពុជាត្រូវយកចិត្តទុកដាក់គិតគូរឱ្យបានហ្មត់ចត់អំពីសន្តិសុខលម្ហសមុទ្រ ក្នុងគោលបំណងថែរក្សាការពារអធិបតេយ្យភាព និងសន្តិសុខដែនសមុទ្ររបស់ខ្លួន ជាពិសេសការពារផ្លូវយុទ្ធសាស្ត្រសេដ្ឋកិច្ចជាតិ ប្រភពអាហារ និងប្រភពធនធានធម្មជាតិនៅលើផ្ទៃសមុទ្រ។

នៅក្នុងប្រធានបទសន្តិសុខលម្ហសមុទ្រ ភាពមិនច្បាស់លាស់នៃខ្សែបន្ទាត់ព្រំដែនសមុទ្រ អាចបង្កជាផលប៉ះពាល់មួយចំនួនមកលើផលប្រយោជន៍ជាតិ ដូចជា បទល្មើសនេសាទពីសំណាក់អ្នកនេសាទបរទេសក្នុងដែនសមុទ្រកម្ពុជា វិវាទលើសិទ្ធិទាមទារគ្រប់គ្រងបណ្តាកោះ និងជម្រកធនធានធម្មជាតិជាដើម។ ក្រៅពីកត្តាខាងលើ អ្វីដែលជាការគំរាមកំហែងមកលើសន្តិសុខលម្ហសមុទ្រកម្ពុជា ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតនោះ គឺឧក្រិដ្ឋកម្មនិងឧប្បត្តិហេតុលើដែនសមុទ្រ។

ឧក្រិដ្ឋកម្មដែនសមុទ្របង្កផលប៉ះពាល់តាមរយៈរូបភាពដូចជា ការឆ្លងដែនខុសច្បាប់ ការជួញដូរខុសច្បាប់គ្រប់ប្រភេទ និងបទល្មើសប្លន់នាវាពាណិជ្ជកម្ម និងទេសចរណ៍។ល។ ចំណែកឯការលិចនាវានិងការកំពប់ប្រេងពីនាវាដឹកប្រេងជាដើម សុទ្ធសឹងជាករណីដែលនឹងអាចកើតឡើងជាយថាហេតុនាពេលអនាគតក្នុងបរិបទឧប្បត្តិហេតុលើដែនសមុទ្រ ដែលនឹងតម្រូវឱ្យកម្ពុជាត្រូវពង្រឹងសមត្ថភាពនិងត្រៀមខ្លួនជានិច្ចក្នុងការទប់ស្កាត់ បង្ការ និងឆ្លើយតបឱ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា។

## ឃ- សន្តិសុខដែនអាកាស

សន្តិសុខដែនអាកាស គឺជាវិស័យអាទិភាពមួយដ៏សំខាន់សម្រាប់ព្រះរាជាណាចក្រកម្ពុជាក្នុងការការពារអធិបតេយ្យភាព សុខសន្តិភាព ធានាបាននូវការ

លើកកម្ពស់ផលប្រយោជន៍ជាតិ និងពង្រីកសក្តានុពលសេដ្ឋកិច្ចជាតិ។ ក្នុងនោះ ភាពប្រឈមនិងការគំរាមកំហែងដល់ដែនអាកាស គឺកង្វះខាតលើសមត្ថភាពគ្រប់គ្រងដែនអាកាស ទាំងលើផ្នែកធនធានមនុស្សនិងផ្នែកសម្ភារៈបច្ចេកទេស ដូចជា រ៉ាដា និងប្រព័ន្ធគ្រប់គ្រងឃ្លាំមើលដែនអាកាសជាដើម។

ការគំរាមកំហែង តាមរយៈការប្លន់អាកាសយាននិងបទល្មើសផ្សេងៗ ដែលអាចកើតឡើងតាមមធ្យោបាយអាកាសចរណ៍ ពីក្រុមភេរវករឬឧក្រិដ្ឋជននានា ក៏នៅតែបន្តចោទជាបញ្ហាមួយក្នុងបរិបទសន្តិសុខដែនអាកាស ដែលកម្ពុជាចាំបាច់ត្រូវតែយកចិត្តទុកដាក់និងគិតគូរឱ្យបានហ្មត់ចត់។ ជាមួយគ្នានេះដែរ លទ្ធភាពនៃការគំរាមកំហែងពីសំណាក់បរទេស តាមរយៈការប្រើប្រាស់យន្តហោះចំបាំងហោះចូលដែនអាកាសកម្ពុជា យន្តហោះឈ្លបស៊ើបការណ៍ ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យាយន្តហោះគ្មានមនុស្សបើក (Unmanned Aerial Vehicle-UAV) ឬដ្រូន (Drone) និងសព្វាវុធទំនើបៗជាដើម ជាកត្តាដែលបង្ហាញអំពីអាទិភាពនៃការការពារសន្តិសុខដែនអាកាស ដែលទាមទារឱ្យកម្ពុជា ត្រូវអភិវឌ្ឍសមត្ថភាពការពារដែនអាកាសជាចាំបាច់។

## ខ- សន្តិសុខបច្ចេកវិទ្យាព័ត៌មាន

នាពេលបច្ចុប្បន្ននេះ ការវាយប្រហារនិងការគំរាមកំហែងលើសន្តិសុខបច្ចេកវិទ្យាព័ត៌មានកំពុងកើតឡើងស្ទើរតែគ្រប់ពេលវេលានិងគ្រប់ទីកន្លែង នៅក្នុងពិភពលោក ជាពិសេសការរីកចម្រើននៃវិស័យបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មានកាន់តែទំនើប រួមទាំងវត្តមាននៃបច្ចេកវិទ្យា Internet of Things (IoT) និង 5G ដែលផ្តល់ឱកាសដល់ការរីកចម្រើននិងលទ្ធភាពកាន់តែខ្ពស់ដល់ឧក្រិដ្ឋជន ក្នុងការវាយប្រហារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ។ម្យ៉ាងវិញទៀតក៏អាចផ្តល់ឱកាសដល់ក្រុមសង្គមងងឹត ដូចជាក្រុមជួញដូរមនុស្ស ជួញដូរគ្រឿងញៀន និងរត់ពន្ធអាវុធជាដើម អាចលួចចូលតាមដាន ស៊ើបការណ៍ឬទាញយកព័ត៌មានផ្សេងៗពីស្ថាប័នរដ្ឋនិងឯកជនដើម្បីបម្រើគោលបំណងឧក្រិដ្ឋរបស់ខ្លួន។

ការគំរាមកំហែងលើសន្តិសុខបច្ចេកវិទ្យាព័ត៌មាន បង្កផលប៉ះពាល់ដល់សន្តិសុខជាតិតាមរយៈរូបភាពជាសកម្មភាពគំរាមកំហែងឬវាយប្រហារ ប្រឆាំងឬធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ សុវត្ថិភាពប្រជាជន យោធា ស្ថិរភាពនយោបាយ ស្ថិរភាពសង្គម សេដ្ឋកិច្ច ព័ត៌មានសម្ងាត់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ មានដូចជា សុខាភិបាល បណ្តាញទំនាក់ទំនង ប្រភពថាមពល ប្រេងឥន្ធនៈ ប្រព័ន្ធផ្គត់ផ្គង់ទឹក ហេដ្ឋារចនាសម្ព័ន្ធគេហដ្ឋាន ដឹកជញ្ជូន និងអាកាសយានដ្ឋាន។ល។

សន្តិសុខបច្ចេកវិទ្យាព័ត៌មាន គឺជាវិធានការឬវិធីសាស្ត្រទប់ស្កាត់ការពារព័ត៌មាន ទិន្នន័យ កម្មវិធី ប្រព័ន្ធប្រតិបត្តិការ បណ្តាញទូរគមនាគមន៍ ប្រព័ន្ធកុំព្យូទ័រ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗពីការវាយប្រហាររបស់ឧក្រិដ្ឋជនតាមរូបភាពសំខាន់ៗ ដូចជាសង្គ្រាមបច្ចេកវិទ្យា ភេរវកម្មបច្ចេកវិទ្យា ចារកម្មបច្ចេកវិទ្យា និងការក្លែងបន្លំជាដើម។

## ច- អំពើភេរវកម្ម

នាពេលបច្ចុប្បន្ននិងទៅអនាគត ភេរវកម្មនៅតែជាការគំរាមកំហែងចម្បងមកលើសន្តិសុខតំបន់និងសកលលោក។ ក្នុងនោះផងដែរ ព្រះរាជាណាចក្រកម្ពុជាក៏ត្រូវតែបង្កើនការគិតគូរនិងយកចិត្តទុកដាក់អំពីការគំរាមកំហែង នាពេលអនាគត មកលើសន្តិសុខនិងស្ថិរភាពជាតិដែលបង្កឡើងដោយភេរវកម្មតាមគ្រប់រូបភាព មានជាអាទិ៍ ភេរវកម្មក្នុងស្រុកនិងភេរវកម្មឆ្លងដែនជាដើម។

ទោះបីកន្លងមកកម្ពុជាពុំដែលរងគ្រោះដោយភេរវកម្មក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងលើការទប់ស្កាត់ បង្ការ និងឆ្លើយតបនឹងការគំរាមកំហែងដ៏គ្រោះថ្នាក់មួយនេះគឺជាការចាំបាច់បំផុត។

## ឆ- គ្រោះមហន្តរាយធម្មជាតិ

ការគំរាមកំហែងសន្តិសុខមិនមែនប្រពៃណី ដូចជាគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្សនិងធម្មជាតិមានការកើនឡើងជាលំដាប់ ដែលជាផលប៉ះពាល់បណ្តាលមកពីការបំផ្លាញបរិស្ថាននិងបម្រែបម្រួលអាកាសធាតុ។ គ្រោះ

មហន្តរាយធម្មជាតិ ដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រញ្ជួយដី ខ្យល់ព្យុះ និងភ្លើងឆេះព្រៃជាដើម គឺជាការគំរាមកំហែងដ៏ខ្លាំងក្លាដែលប៉ះពាល់និងជះឥទ្ធិពលដល់មនុស្សជាតិទូទាំងសកលលោក ហើយគ្រោះមហន្តរាយធម្មជាតិទាំងនោះនឹងបន្តកើនឡើងក្នុងកម្រិតមួយគួរឱ្យព្រួយបារម្ភ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ថា គ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត គឺជាការគំរាមកំហែងចម្បងមួយសម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកសិកម្ម។ ប្រជាជនកម្ពុជាដែលរស់នៅតាមបណ្ដោយទន្លេមេគង្គនិងទន្លេសាប តែងតែទទួលរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់ស្ទើររាល់ឆ្នាំ។ ម្យ៉ាងវិញទៀត កម្ពុជាក៏ទទួលរងឥទ្ធិពលមួយចំនួនដោយសារគ្រោះមហន្តរាយធម្មជាតិដែលមានប្រភពពីប្រទេសជិតខាងផងដែរ។

ទន្ទឹមនឹងកំណើននៃគ្រោះមហន្តរាយធម្មជាតិទាំងនោះ សមត្ថភាពក្នុងការប្រុងប្រៀបនិងត្រៀមលក្ខណៈជាមុនរបស់កម្លាំងប្រដាប់អាវុធ គឺជាអាទិភាពសំខាន់មួយនៃផែនការយុទ្ធសាស្ត្ររបស់កម្ពុជា។ ការលើកកម្ពស់សមត្ថភាពឆ្លើយតបនិងដោះស្រាយ ពោលគឺការពង្រឹងសមត្ថភាពកងកម្លាំងជំនាញនិងការធ្វើទំនើបកម្មលើសម្ភារៈបរិក្ខារសង្គ្រោះ គឺជាកត្តាចាំបាច់បំផុតក្នុងនាមកងយោធពលខេមរភូមិន្ទជាកងកម្លាំងនាំមុខក្នុងប្រតិបត្តិការសង្គ្រោះ ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

ក្នុងនោះដែរ ការពង្រឹងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងកិច្ចការគ្រប់គ្រងនិងសង្គ្រោះគ្រោះមហន្តរាយ ជាមួយបណ្ដាប្រទេសជាដៃគូនានា ជាពិសេសប្រទេសក្នុងក្របខណ្ឌអាស៊ាននឹងជួយបង្កើនសមត្ថភាពនិងភាពជាដៃគូនៃកងយោធពលខេមរភូមិន្ទ ក្នុងការឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតទៅនឹងការគំរាមកំហែងនានាបង្កឡើងដោយគ្រោះមហន្តរាយធម្មជាតិ។

## ៥- ជំងឺឆ្លងរាតត្បាតជាសកល

ការកើនឡើងនៃការតភ្ជាប់ទំនាក់ទំនងក្នុងតំបន់ សកលលោក និងសកលភាវូបនីយកម្ម បានធ្វើឱ្យជំងឺឆ្លងរាតត្បាតជាសកលក្លាយជាការគំរាមកំហែង

លើសពីបញ្ហាសុខភាពសាធារណៈ និងជះឥទ្ធិពលដល់សន្តិសុខជាតិនិងសកលលោក។ ជាការពិតណាស់ ការរីករាលដាលនៃជំងឺកូវីដ១៩ ជាភស្តុតាងជាក់ស្តែងដែលបង្ហាញឱ្យឃើញថា ជំងឺឆ្លងរាតត្បាតបង្កផលប៉ះពាល់មិនត្រឹមតែលើវិស័យសុខាភិបាលប៉ុណ្ណោះទេ ថែមទាំងលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ អប់រំ សន្តិសុខជាតិ និងវិស័យផ្សេងៗទៀតផងដែរ។ កត្តាទាំងអស់នេះហើយដែលតម្រូវឱ្យប្រទេសក្នុងតំបន់ ក៏ដូចជាសកលលោកទាំងមូលរួមសហការគ្នាជាធ្លុងមួយក្នុងការដោះស្រាយវិបត្តិសុខភាពសាធារណៈនេះ រួមទាំងការស្តារឡើងវិញនូវសេដ្ឋកិច្ចសង្គម ក្នុងអំឡុងពេលនិងក្រោយវិបត្តិនៃជំងឺកូវីដ១៩ផងដែរ តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការនិងយន្តការអន្តរជាតិឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីពន្លឿនដំណោះស្រាយនិងការឆ្លើយតបជាសកលទៅនឹងវិបត្តិកូវីដ១៩ ។

នៅប្រទេសកម្ពុជាកន្លងមក ពេលជំងឺកូវីដ១៩បានផ្ទុះឡើង និងឈានដល់ការឆ្លងរាតត្បាតចូលសហគមន៍ ក្រុមប្រឆាំងរាជរដ្ឋាភិបាលបានបំភ្លៃស្ថានការណ៍ពិត ដើម្បីអូសទាញប្រជាជនឱ្យដាក់បន្ទុកនិងបន្ទោសរាជរដ្ឋាភិបាលកម្ពុជាថាអសមត្ថភាពក្នុងការបង្ការនិងទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ១៩។ ដូច្នេះ ប្រសិនបើគ្មានយន្តការច្បាស់លាស់ក្នុងការបង្ការ ទប់ស្កាត់ គ្រប់គ្រង និងដោះស្រាយដ៏មានប្រសិទ្ធភាពទាន់ពេលវេលារបស់រាជរដ្ឋាភិបាល និងការចូលរួមយ៉ាងសកម្មរបស់កងយោធពលខេមរភូមិន្ទជាមួយរាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះទេ វិបត្តិនៃជំងឺឆ្លងនេះនឹងជះឥទ្ធិពលកាន់តែខ្លាំងដល់សន្តិសុខជាតិជាមិនខាន។

វិបត្តិជំងឺកូវីដ១៩ បានឆ្លុះបញ្ចាំងពីតួនាទីនាំមុខយ៉ាងសំខាន់របស់កងយោធពលខេមរភូមិន្ទ ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងរាតត្បាតជាសកល តាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដូចជាការគ្រប់គ្រងការធ្វើចត្តាឡីស័ក ការរៀបចំមណ្ឌលព្យាបាល ចាត់តាំងក្រុមពេទ្យយោធាព្យាបាល ការដឹកជញ្ជូនប្រជាពលរដ្ឋវិលមកពីប្រទេសជិតខាង ការរៀបចំមន្ទីរពិសោធន៍ធ្វើវិភាគរកមេរោគកូវីដ និងបើកយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋតាមយុទ្ធ

សាស្ត្រផ្កាវីករបស់រាជរដ្ឋាភិបាល ដោយចាប់ពីតំបន់ក្រហម (តំបន់ឆ្លងខ្លាំង) ពង្រីកទៅតាមបណ្តាខេត្ត ចាក់ជូនប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលស្នាក់នៅដោយស្របច្បាប់ទូទាំងប្រទេស ដោយមិនយកប្រាក់ និងមិនគិតពីនិន្នាការនយោបាយ។ លើសពីនេះ កងយោធពលខេមរភូមិន្ទក៏បានផលិតនិងផ្តល់ប័ណ្ណជូនដល់អ្នកដែលបានមកទទួលការចាក់វ៉ាក់សាំង ផងដែរ។ បច្ច័យទាំងអស់នេះហើយ ដែលបង្ហាញថា មកទល់នឹងឆ្នាំ២០២២នេះ កម្ពុជាទទួលបានជោគជ័យនៅក្នុងការប្រយុទ្ធជាមួយជំងឺកូវីដ១៩។

យើងមិនអាចដឹងនិងប្រមើលមើលឃើញអំពីការកើតឡើង នៃជំងឺឆ្លងរាតត្បាតជាសកលផ្សេងៗទៀតដែលអាចប៉ះពាល់ដល់អាយុជីវិត សេដ្ឋកិច្ចសង្គមទៅអនាគត ដែលបង្កឡើងដោយកត្តាមួយចំនួនដូចជាបម្រែបម្រួលបរិស្ថាន បម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍនិងការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យាវេជ្ជសាស្ត្រ និងការចម្លងជំងឺពីសត្វមកមនុស្ស។ល។ កត្តាទាំងអស់នេះហើយដែលតម្រូវឱ្យកម្ពុជាក៏ដូចជាប្រទេសក្នុងតំបន់និងសកលលោក ត្រូវត្រៀមខ្លួនជានិច្ចក្នុងការបង្ការទប់ស្កាត់ និងដោះស្រាយនូវវិបត្តិជំងឺឆ្លងរាតត្បាតជាសកលដទៃទៀតនាពេលអនាគត ដោយក្នុងនោះទាមទារឱ្យមានការគិតគូរអំពីការកំណត់យុទ្ធសាស្ត្រឆ្លើយតបនឹងការគំរាមកំហែងនៃជំងឺឆ្លងរាតត្បាតជាសកល នៅក្នុងយុទ្ធសាស្ត្រការពារជាតិរបស់ខ្លួន។

# ជំពូក៣
# គោលនយោបាយការពារជាតិ

ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ច នូវគោលការណ៍អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ និងរួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាងនិងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។ កម្ពុជាមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាកម្ពុជានៅបរទេសដែរ លើកលែងតែក្នុងក្របខណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។ កម្ពុជាដាច់ខាតមិនឈ្លានពាននិងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប្រទេសដទៃ ប្រកាន់យកគោលការណ៍ប្រើដំណោះស្រាយសន្តិវិធី ដោយអនុលោមតាមច្បាប់ជាតិនិងអន្តរជាតិ និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។ កម្ពុជាប្រឆាំងដាច់ខាត ចំពោះការជ្រៀតជ្រែកពីបរទេសចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាទោះក្រោមរូបភាពណាក៏ដោយ។

កម្ពុជាអនុវត្តរាល់ការសម្រេចចិត្តរបស់ខ្លួន លើវិស័យការពារជាតិនិងសន្តិសុខដោយឈរលើជំហរឯករាជ្យភាព យោងទៅតាមការវិវត្តនិងការប្រែប្រួល នៃស្ថានការណ៍នយោបាយ សន្តិសុខ និងភូមិសាស្ត្រនយោបាយសកលលោក។ ទន្ទឹមនឹងនេះ ដោយផ្អែកលើការវាយតម្លៃអំពីការគំរាមកំហែងនានាមកលើសន្តិសុខជាតិកម្ពុជាកំណត់បាននូវគោលនយោបាយការពារជាតិ ដែលជាត្រីវិស័យចង្អុលបង្ហាញទិសដៅសម្រាប់កងយោធពលខេមរភូមិន្ទ ក្នុងការអនុវត្តតួនាទីនិងភារកិច្ចលើកិច្ចការពារជាតិឱ្យបានគត់មត់រួមមាន៖

## ១- ថែរក្សាសន្តិភាព

ព្រះរាជាណាចក្រកម្ពុជាជានិច្ចកាល ចាត់ទុកសន្តិភាពជាឫសគល់នៃឯកភាពជាតិនិងការអភិវឌ្ឍជាតិលើគ្រប់វិស័យ។ សន្តិភាពពេញលេញដែលកម្ពុជាទទួលបានសព្វថ្ងៃ ឆ្លុះបញ្ចាំងឱ្យឃើញអំពីការតស៊ូ ពលិកម្ម និងគុណបំណាច់ដ៏ធំធេង

របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងបុព្វហេតុនៃការរស់រានឡើងវិញនៃប្រជាជាតិកម្ពុជាពីភ្លើងសង្គ្រាមរ៉ាំរ៉ៃជាងបីទសវត្សរ៍។ ក្នុងន័យនេះ កម្ពុជាយល់ច្បាស់ពីតម្លៃនៃប្រវត្តិសាស្ត្រដែលប្រទេសជាតិបានឆ្លងកាត់ ជាពិសេសការខិតខំលើកកម្ពស់គុណតម្លៃនៃប្រវត្តិសាស្ត្រយោធាដែលជាសក្ខីភាពនៃការតស៊ូ និងការលះបង់ប្តូរផ្តាច់របស់វីរកងទ័ព ដើម្បីបុព្វហេតុសន្តិភាព។ ដើម្បីថែរក្សាសន្តិភាពឱ្យបានគង់វង្ស កម្ពុជានឹងប្រើប្រាស់សិទ្ធិនិងអធិបតេយ្យរបស់ខ្លួនក្នុងការអនុវត្តវិធីសាស្ត្រ មធ្យោបាយដែលមានភាពសមស្រប និងយុត្តិធម៌បំផុតដោយផ្អែកលើច្បាប់ជាតិនិងអន្តរជាតិជាមូលដ្ឋាន។ ក្នុងន័យនេះ កងយោធពលខេមរភូមិន្ទដែលជាកងកម្លាំងប្រដាប់អាវុធចម្បងនិងនាំមុខ មានតួនាទីនិងភារកិច្ចការពាររាជរដ្ឋាភិបាលស្របច្បាប់ កើតចេញពីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ការពាររដ្ឋធម្មនុញ្ញ ការពារសុវត្ថិភាពប្រជាជន ធានាសន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈសង្គម ក្នុងគោលបំណងថែរក្សាឱ្យបាននូវសន្តិភាពដែលជាជម្រកនៃភាពសុខដុមនិងវិបុលភាព របស់ប្រជាជនកម្ពុជា។

## ២- ការពារផលប្រយោជន៍ជាតិ

ឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដី សន្តិសុខ ស្ថិរភាពជាតិ តំបន់ព្រំដែនពោរពេញដោយការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ត្រូវបានចាត់ទុកជាផលប្រយោជន៍សំខាន់របស់ជាតិ និងស្ថិតក្នុងគោលដៅយុទ្ធសាស្ត្រយូរអង្វែងរបស់រាជរដ្ឋាភិបាល ដែលប្តេជ្ញាធ្វើឱ្យកម្ពុជាពោរពេញដោយសន្តិភាព សន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់សង្គម ឯកភាពជាតិ និងការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ សុខភាពសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងការពារជាតិ។ ក្នុងន័យនេះ កម្ពុជានឹងប្រើប្រាស់សិទ្ធិស្វ័យការពារគ្រប់ពេលវេលា និងមធ្យោបាយប្រឆាំងនឹងការគំរាមកំហែងនានា ទាំងនៅផ្ទៃក្នុងនិងពីខាងក្រៅ ដោយអនុលោមជានិច្ចតាមច្បាប់ជាតិនិងអន្តរជាតិ ។

## ៣- បង្កើននិងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ដោយផ្អែកលើស្មារតី "ពង្រឹងសាមគ្គីភាព បង្កើនប្រសិទ្ធភាពការងារខាងក្នុង បង្កើនមិត្តខាងក្រៅ ដោយឈរលើមូលដ្ឋានស្មើភាពនិងការគោរពគ្នាទៅវិញទៅមក" ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់នូវគោលនយោបាយការពារជាតិមួយ ដែលពង្រឹង លើកកម្ពស់សមត្ថភាព និងកិត្យានុភាពនៃកងយោធពលខេមរភូមិន្ទទាំងនៅក្នុងប្រទេសនិងលើឆាកអន្តរជាតិ។ កម្ពុជាគាំទ្រលើរាល់គំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់និងសកលលោក ដោយផ្តោតលើកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី ដើម្បីផលប្រយោជន៍រួមគ្នានិងការគោរពគ្នាទៅវិញទៅមក។

## ៤- គុណតម្លៃនៃប្រវត្តិសាស្ត្រយោធានិងនយោបាយឈ្នះ ឈ្នះ

អាទិភាពមួយក្នុងចំណោមអាទិភាពទាំងឡាយ នៃគោលនយោបាយការពារជាតិរបស់ព្រះរាជាណាចក្រកម្ពុជា គឺការថែរក្សានិងលើកស្ទួយគុណតម្លៃនៃប្រវត្តិសាស្ត្រយោធាដែលឆ្លុះបញ្ចាំងឱ្យឃើញនូវពលិកម្មនិងគុណបំណាច់ដ៏ធំធេង របស់សម្តេចតេជោ **ហ៊ុន សែន** នៅក្នុងការរស់រានមានជីវិតឡើងវិញនៃប្រជាជាតិកម្ពុជា ការស្វែងរកនិងកសាងនូវសន្តិភាព ស្ថិរភាព ការអភិវឌ្ឍសង្គមជាតិនិងការប្តេជ្ញាពុះពារថែរក្សាឱ្យបានគង់វង្សនូវសន្តិភាពដ៏កម្ររកបាននេះឱ្យស្ថិតនៅជាដរាប ដើម្បីជាជម្រកដ៏ស័ក្តិសិទ្ធិសម្រាប់ភាពសុខដុមរមនានិងវិបុលភាពរបស់ប្រជាជនកម្ពុជា។

គុណតម្លៃនៃនយោបាយឈ្នះ ឈ្នះ របស់សម្តេចតេជោបានប្រែក្លាយប្រទេសកម្ពុជាពីសមរភូមិ ពីមហន្តរាយ ពីសោកនាដកម្ម មកជាភាពសុខសាន្ត ឯកភាពជាតិ អធិបតេយ្យ ឯករាជ្យ និងការអភិវឌ្ឍដ៏រុងរឿង។ លើសពីនេះទៀត សន្តិភាព និងឯកភាពជាតិដ៏រឹងប៉ឹងរបស់កម្ពុជា គឺជាការរួមចំណែកយ៉ាងសំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងនិងលើកតម្កើងសន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់ ហើយក៏កំពុងក្លាយជាគំរូដ៏ប្រពៃសម្រាប់ការស្វែងរកនិងការថែរក្សាសន្តិភាព នៅក្នុងផ្នែកផ្សេងៗទៀតនៃពិភពលោកផងដែរ។

ដូច្នេះ តម្រូវការនៃការសិក្សាយល់ដឹងអំពីប្រវត្តិសាស្ត្រយោធានិងនយោបាយឈ្នះ ឈ្នះ នៅក្នុងមជ្ឈដ្ឋានស៊ីវិលនិងយោធាទូទាំងប្រទេស គឺជាការចាំបាច់ ហើយក៏ជាមូលដ្ឋាននៃការឆ្លុះបញ្ចាំងលើភាពវិជ្ជមាននិងអវិជ្ជមានក្នុងអតីតកាល ព្រមទាំងជាថ្នាលបណ្ដុះមនសិការសម្រាប់លើកតម្កើងតម្លៃនៃសន្តិភាព នាពេលបច្ចុប្បន្ននិងតទៅថ្ងៃអនាគត។ ការថែរក្សាតឹកតាងប្រវត្តិសាស្ត្រទាំងឡាយ ជាពិសេសការកសាងវិមានឈ្នះ ឈ្នះ គឺជានិមិត្តរូបនៃការចងចាំនិងការដឹងគុណចំពោះស្ថាបនិកមគ្គុទ្ទេសក៍ឯក និងប្រតិបត្តិករនយោបាយឈ្នះ ឈ្នះ ដែលនាំមកនូវសន្តិភាពនិងឯកភាពជាតិពេញលេញ។ គំនិតផ្ដួចផ្ដើមនិងការកសាងតំបន់ប្រវត្តិសាស្ត្រយោធានៅតាមទីតាំងមួយចំនួននៃតំបន់ជាប់ព្រំដែន គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗនៃគោលនយោបាយការពារព្រំដែនផងដែរ។



**សម្ដេចពិជ័យសេនា ទៀ បាញ់** ចុះត្រួតពិនិត្យការរៀបចំកសាងតំបន់ប្រវត្តិសាស្ត្រយោធាតាមព្រំដែន (រូបភាព: អង្គភាពសេនាតេជោ)

ការចែករំលែកពិសោធន៍អំពីជោគជ័យនៃការអនុវត្តនយោបាយឈ្នះ ឈ្នះ របស់ព្រះរាជាណាចក្រកម្ពុជាក៏ជាការរួមចំណែកយ៉ាងសំខាន់នៅក្នុងការលើកស្ទួយ

សន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់ផងដែរ។ ទស្សនៈនៃការឆ្លុះបញ្ចាំងប្រវត្តិសាស្ត្រយោធាដើម្បីកសាងសន្តិភាពជានិរន្តរ៍ កំពុងក្លាយជាប្រធានបទនៃការពិភាក្សានៅតាមវេទិកានានារបស់តំបន់នាពេលបច្ចុប្បន្ននិងតទៅអនាគត។

**"មានតែអ្នកឈ្នះទេ ដែលត្រូវនិងអាចសរសេរប្រវត្តិសាស្ត្រ"**

*(អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**)*

**"យើងត្រូវធ្វើយ៉ាងណា ដើម្បីឲ្យប្រវត្តិសាស្ត្រសរសេរ និងចារឹកអំពីយើងសម្រាប់មនុស្សជំនាន់ក្រោយ"**

*(ប្រសាសន៍**សម្តេចពិជ័យសេនា ទៀ បាញ់**)*

# ផ្នែកទី២
# យុទ្ធសាស្ត្រការពារជាតិ

# ជំពូក៤
# កិច្ចការពារព្រំដែន

## ១- ព្រំដែនគោក

កម្ពុជាមានសុឆន្ទៈនិងគោលនយោបាយច្បាស់លាស់ ក្នុងការបន្តពង្រឹងនិងអភិវឌ្ឍតំបន់ព្រំដែនជាមួយប្រទេសជិតខាង ឱ្យក្លាយជាព្រំដែនប្រកបដោយសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ។ ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងសហគមន៍ប្រជាពលរដ្ឋនៅជាប់ព្រំដែន គឺជាអាទិភាពចម្បងនៃយុទ្ធសាស្ត្រការពារព្រំដែនរបស់កម្ពុជា។ ជាមួយគ្នានេះដែរ កងយោធពលខេមរភូមិន្ទនឹងបន្តយកចិត្តទុកដាក់លើការបង្កើតនិងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រយោធា នៅតាមតំបន់ព្រំដែន ដើម្បីលើកកម្ពស់ការពង្រឹងយុទ្ធសាស្ត្រការពារព្រំដែននិងដើម្បីផ្សារភ្ជាប់តំបន់ទាំងនោះ ជាមួយនឹងតំបន់សហគមន៍ដែលបាននឹងកំពុងអភិវឌ្ឍ។

ការដោះស្រាយបញ្ហាដែលរមែងកើតឡើងនៅតំបន់ព្រំដែន ត្រូវធ្វើដោយសន្តិវិធីនិងផ្អែកលើយន្តការការទូតទ្វេភាគី ពហុភាគី និងច្បាប់អន្តរជាតិដើម្បីរក្សាឱ្យបាននូវស្ថិរភាពនិងធានាឱ្យមានសន្តិភាពប្រកបដោយចីរភាពនៅទីនោះ។ ការបន្តប្រើប្រាស់យន្តការនៃកិច្ចសហប្រតិបត្តិការគ្រប់កម្រិតដែលមានស្រាប់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការព្រំដែនជាមួយប្រទេសជិតខាង គឺមានភាពចាំបាច់បំផុត។

ស្ថាប័នដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែនទាំងអស់ នឹងបន្តប្រើប្រាស់យន្តការដែលមានស្រាប់ ជាវេទិកាសម្រាប់កំណត់ផែនការសកម្មភាព ទាំងរយៈពេលខ្លីនិងវែង ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសជិតខាង។ ជាមួយគ្នានេះដែរ ការជំរុញឱ្យមានការបោះបង្គោលព្រំដែនបានចប់សព្វគ្រប់ គឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពនៅក្នុងការកាត់បន្ថយអរិភាពនៅតាមតំបន់ព្រំដែន។ ស្ថាប័ននិងកងឯកភាពប្រចាំនៅថ្នាក់មូលដ្ឋានត្រូវទំនាក់ទំនងជាប្រចាំ ក្នុងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ដើម្បីដោះស្រាយឱ្យទាន់ពេលវេលានូវបញ្ហាដែលអាចកើតឡើងជាយថាហេតុ។ ការល្បាតរួមគ្នានៅតាមខ្សែព្រំដែនគោកជាមួយប្រទេសជិតខាងនឹងត្រូវ

អនុវត្តតាមគោលការណ៍ដែលបានកំណត់ ឱ្យបានជាប្រចាំនិងអាចពង្រីកបន្ថែមទៀតដោយផ្អែកតាមលទ្ធភាពនៃធនធាន។

ទោះបីគោលការណ៍គន្លឹះ គឺប្រើប្រាស់មធ្យោបាយការទូតនិងរក្សាទំនាក់ទំនងល្អក្នុងការកសាងមិត្តភាពរឹងមាំជាមួយប្រទេសជិតខាងក៏ដោយ ការពង្រឹងសមត្ថភាពកងទ័ពនៅតាមបណ្តោយព្រំដែននៅតែជាការចាំបាច់។ ការពង្រឹងសមត្ថភាពកងយោធានេះ នឹងផ្តោតលើការរក្សាវត្តមានកងយោធានិងការធ្វើល្បាតជាប្រចាំនៅតាមព្រំដែន ការលើកកម្ពស់ការត្រៀមលក្ខណៈជាប់ជានិច្ច ការផ្គត់ផ្គង់សម្ភារៈមធ្យោបាយសម្រាប់ធានាឱ្យបានទាំងស្រុងដល់កិច្ចប្រតិបត្តិការ ការពង្រឹង និងធ្វើទំនើបកម្មលើប្រព័ន្ធការពារព្រំដែននិងការបង្កើនសមត្ថភាពផ្នែកព័ត៌មាន។

ដើម្បីធានាដល់ភាពរឹងមាំនិងប្រសិទ្ធភាព នៃភារកិច្ចការពារព្រំដែនរបស់កងយោធពលខេមរភូមិន្ទ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានដាក់ចេញនូវគោលការណ៍ដ៏ពិសិដ្ឋ គឺពង្រឹងនិរន្តរភាពនៃទំនាក់ទំនងរវាងសមរភូមិមុខ និងសមរភូមិក្រោយ តាមរយៈសម្ព័ន្ធមេត្រីភាពរវាងកងទ័ព និងស្ថាប័នរដ្ឋនិងឯកជន ដើម្បីលើកតម្លៃនៃពលិកម្មដ៏ធំធេងរបស់កងទ័ព និងបង្កើនការគាំទ្រទាំងស្មារតី និងសម្ភារៈ ពីសំណាក់សមរភូមិក្រោយ។ ជាមួយគ្នានេះដែរ ការអនុវត្តគោលនយោបាយដោះស្រាយដីធ្លី និងផ្ទះសម្បែង ជូនកងទ័ព និងគ្រួសារ ដើម្បីលើកស្ទួយជីវភាព និងលើកទឹកចិត្តចំពោះគុណបំណាច់របស់កងទ័ព ព្រមទាំងពង្រីកការអភិវឌ្ឍសហគមន៍ នៅតាមតំបន់ព្រំដែន នឹងត្រូវបន្តធ្វើជាប់ជានិច្ច។ តបស្នងចំពោះចក្ខុវិស័យប្រកបដោយប្រសិទ្ធភាព និងស័ក្តសិទ្ធភាពនេះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ទទួលបានការប្រសិទ្ធនាមថាជា **"អគ្គភ័ស្តុភារជាន់ខ្ពស់"** សម្រាប់កងយោធពលខេមរភូមិន្ទ។

## ២- ព្រំដែនទឹក

ចំពោះព្រំដែនទឹក ការល្បាតរួមគ្នាជាមួយប្រទេសជិតខាងត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនៃកិច្ចសហប្រតិបត្តិការដែលមានស្រាប់និងអាចពង្រីកបន្ថែមទៀត តាម

ការចាំបាច់ជាក់ស្តែង។ លើសពីនេះ ការលើកកម្ពស់សមត្ថភាពយល់ដឹងនិងគ្រប់គ្រងដែនទឹកកម្ពុជាត្រូវធ្វើឡើងជាចាំបាច់ ដោយមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តមូលដ្ឋានកងទ័ពជើងទឹក ដូចជាការកសាងមូលដ្ឋានសមុទ្ររាមនិងមូលដ្ឋាននៅតាមបណ្តាទីតាំងយុទ្ធសាស្ត្រផ្សេងៗទៀត និងរោងជាងជួសជុលនាវាគ្រប់ប្រភេទដោយខ្លួនឯង ដើម្បីធានាបាននូវនិរន្តរភាពនៃការប្រើប្រាស់និងការថែទាំ។ ការធ្វើទំនើបកម្មយោធាក៏ត្រូវធ្វើជាមួយគ្នាផងដែរ រួមមានការរៀបចំស្ថានីយរ៉ាដា ការបំពាក់នាវាពិឃាដ និងនាវាល្បាត ព្រមទាំងប្រព័ន្ធការពារផ្សេងៗក្នុងគោលបំណងការពារអធិបតេយ្យនិងផលប្រយោជន៍ជាតិ ព្រមទាំងឆ្លើយតបទៅនឹងការគំរាមកំហែងនានាប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា។

## ៣- ព្រំដែនអាកាស

គោលដៅយុទ្ធសាស្ត្រនៃកិច្ចការពារអធិបតេយ្យដែនអាកាសរបស់កម្ពុជា ទាមទារឱ្យមានការអភិវឌ្ឍធនធានមនុស្សនិងយុទ្ធោបករណ៍ ជាពិសេសប្រព័ន្ធការពារអាកាស ដោយបំពាក់ប្រព័ន្ធការពាររួមគ្នាដែលមានសមត្ថភាពក្នុងការប្រឆាំងយន្តហោះចម្បាំង យន្តហោះស៊ើបការណ៍ និងយន្តហោះគ្មានមនុស្សបើកជាដើម ហើយកំណត់ទីតាំងយុទ្ធសាស្ត្រឈរជើងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការពារបង្ការ និងទប់ស្កាត់ពីការគំរាមកំហែងនានា។

ទន្ទឹមនឹងនេះ តម្រូវឱ្យមានកិច្ចសហការនិងទំនាក់ទំនងជាប្រចាំជាមួយនឹងរដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិល ព្រមទាំងស្ថាប័នស៊ីវិលពាក់ព័ន្ធក្នុងការអភិវឌ្ឍសមត្ថភាពក៏ដូចជាកិច្ចសហប្រតិបត្តិការ ដើម្បីការពារដែនអធិបតេយ្យនិងសន្តិសុខជាតិ។

# ជំពូក៥
# កិច្ចការពារសន្តិសុខជាតិ

ក្រៅពីភារកិច្ចស្នូលនៃកិច្ចការការពារបូរណភាពទឹកដី ការពាររដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាលស្របច្បាប់ និងផលប្រយោជន៍ជាតិ កងទ័ពក៏មានភារកិច្ចចម្បងនៅក្នុងការធានានូវសន្តិភាព សន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់សាធារណៈ និងចូលរួមប្រតិបត្តិការមនុស្សធម៌ផងដែរ។ ជាមួយគ្នានេះ កងយោធពលខេមរភូមិន្ទដើរតួនាទីជាអ្នកការទូតយោធាយ៉ាងសំខាន់ជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតក្នុងការរក្សាទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អ។ កម្ពុជាបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន ដែលទាមទារឱ្យកងយោធពលខេមរភូមិន្ទត្រៀមខ្លួនជានិច្ចដើម្បីចូលរួមអនុវត្តច្បាប់នេះ។

## ១- ការប្រយុទ្ធនឹងបដិវត្តន៍ពណ៌

វិទ្ធង្សនាជាការញុះញង់ពីក្រុមជ្រុលនិយមនិងអគតិ ដែលមានបំណងធ្វើឱ្យមានការបះបោរ ផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ដែលកើតចេញពីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌។ ដូច្នេះកងទ័ពមិនអាចមានគោលជំហរអាព្យាក្រឹត្យចំពោះរឿងនេះជាដាច់ខាត ហើយត្រៀមខ្លួនសហការជាមួយនឹងអាជ្ញាធរពាក់ព័ន្ធដើម្បីបង្ការ ទប់ស្កាត់ និងបង្រ្កាបអំពើវិទ្ធង្សនាគ្រប់រូបភាព។

ឆ្លងកាត់បទពិសោធកន្លងមក បដិវត្តន៍ពណ៌ដែលបង្កឡើងដោយក្រុមជ្រុលនិយមមួយចំនួន និងជំរុញដោយកម្លាំងអមិត្តរបស់បរទេសបានប៉ុនប៉ងបំផ្លាញសន្តិភាពនិងឯកភាពជាតិដ៏កម្ររកបាននៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា។ ទីប្រជុំទម្ងន់នៃបដិវត្តន៍ពណ៌នៅកម្ពុជា គឺមហិច្ឆិតាធ្វើឱ្យមានអាព្យាក្រឹត្យបនីយកម្មរបស់កងកម្លាំងប្រដាប់អាវុធ ដើម្បីងាយស្រួលផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។ ដើម្បីទប់ទល់នឹងឧបាយកលនេះ កងកម្លាំងប្រដាប់អាវុធត្រូវតែរឹងប៉ឹងនិងស្មោះត្រង់ដោយឥតលក្ខខណ្ឌ ចំពោះជាតិ សាសនា ព្រះមហាក្សត្រ ការពារឱ្យបាននូវគ្រប់តម្លៃទាំងអស់

នៃរដ្ឋធម្មនុញ្ញ និងរាជរដ្ឋាភិបាលដែលប្រសូត្រចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋ។ និយាយរួមមក គឺកងយោធពលខេមរភូមិន្ទ នឹងចាត់វិធានការជាបន្ទាន់ចំពោះរាល់សកម្មភាពទាំងឡាយដែលតំណាងឱ្យបដិវត្តន៍ពណ៌ ដើម្បីធានាឱ្យបាននូវសន្តិភាព ឯកភាពជាតិ ភាពសុខដុមរមនា និងវិបុលភាពរបស់ប្រជាជាតិកម្ពុជា។

## ២- ការប្រឆាំងភេរវកម្ម

ទោះបីជាព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានសូចនាករណាមួយដែលបង្ហាញថាជាគោលដៅដោយចំពោះនៃការវាយប្រហារភេរវកម្មក៏ពិតមែន ក៏បញ្ហាភេរវកម្មនៅជាការគំរាមកំហែងមកលើសន្តិភាព សន្តិសុខ និងស្ថិរភាពសង្គមនៅឡើយ។

ហេតុដូច្នេះកងកម្លាំងប្រដាប់អាវុធ ត្រូវតែមានយុទ្ធសាស្ត្រសមស្របដើម្បីទប់ស្កាត់និងឆ្លើយតបទៅនឹងសកម្មភាពភេរវកម្មគ្រប់រូបភាព ឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះដែរ ត្រូវគិតគូរអំពីការពង្រឹងសមត្ថភាពជំនាញនិងធនធានដល់កងកម្លាំងប្រឆាំងភេរវកម្មនិងកងឯកភាពពាក់ព័ន្ធទាំងអស់ ព្រមទាំងត្រូវសហការជាមួយស្ថាប័នជាតិនានា។ ទន្ទឹមនឹងនេះ ដើម្បីពង្រឹងសមត្ថភាពកម្លាំងប្រឆាំងភេរវកម្ម កងយោធពលខេមរភូមិន្ទចាំបាច់ទាមទារកិច្ចសហការជាមួយនឹងប្រទេសដៃគូឱ្យបានគ្រប់ជ្រុងជ្រោយ លើការចែករំលែកផ្លាស់ប្តូរព័ត៌មានទាន់ពេលវេលា ការហ្វឹកហ្វឺនបណ្តុះបណ្តាលជំនាញ ធ្វើលំហាត់ និងសមយុទ្ធរួមគ្នានិងជំនួយឧបត្ថម្ភផ្សេងៗ។

តែទោះជាយ៉ាងណាក៏ដោយ គោលនយោបាយសុខដុមនីយកម្មនៅក្នុងសង្គមជាតិ គឺជាវិធានការដ៏មានប្រសិទ្ធភាពបំផុតក្នុងការបញ្ចៀសអំពើភេរវកម្មអន្តរជាតិនៅកម្ពុជា ដោយអនុលោមតាមទស្សនៈ **សម្តេចពិជ័យសេនា** ដែលបានផ្តល់អនុសាសន៍ថា "*ត្រូវព្យាយាមបង្ការកុំឱ្យអំពើភេរវកម្មកើតឡើង ជាជាងខំប្រឹងប្រយុទ្ធប្រឆាំងជាមួយវាដោយផ្ទាល់។ មិនត្រូវបង្កើតភេរវកម្ម ឬទាញយកភេរវកម្មឲ្យមកជិតខ្លួន*"។ ជាមួយគ្នានេះដែរ ការអប់រំបន្សាបមនោគមន៍វិជ្ជា ក៏មិនត្រូវមើលរំលងដែរ។

## ៣- ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន

ការជួញដូរមនុស្ស អាវុធ និងគ្រឿងញៀន ព្រមទាំងសកម្មភាពឆ្លងដែនខុសច្បាប់ដទៃទៀត នៅតែជាកង្វល់សម្រាប់រាជរដ្ឋាភិបាល ដែលទាមទារឱ្យកងយោធពលខេមរភូមិន្ទ ជំរុញនិងពង្រឹងយន្តការអន្តរស្ថាប័ននិងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីបង្កើនសមត្ថភាពទប់ស្កាត់ ចែករំលែក និងផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលាក្នុងគោលដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពខុសច្បាប់នានានៅតាមបន្ទាត់ព្រំដែនឱ្យមានប្រសិទ្ធភាព។

ដើម្បីជំរុញឱ្យការទប់ស្កាត់និងឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនមានប្រសិទ្ធភាពខ្ពស់ កងយោធពលខេមរភូមិន្ទចាំបាច់ត្រូវបង្កើនកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយស្ថាប័នជាតិ រួមមាន នគរបាលជាតិ គយនិងរដ្ឋាករ និងភ្នាក់ងារផ្សេងៗទៀត ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដៃគូ ក្នុងតំបន់និងអន្តរជាតិក្នុងការចែករំលែកព័ត៌មាន បង្ការ ទប់ស្កាត់ និងឆ្លើយតបនឹងឧក្រិដ្ឋកម្មឆ្លងដែន។ ទន្ទឹមនឹងនេះ កងយោធពលខេមរភូមិន្ទក៏ត្រូវលើកកម្ពស់សមត្ថភាពកងកម្លាំងជំនាញ តាមរយៈការបង្កើននិងពង្រឹងការហ្វឹកហ្វឺនបណ្តុះបណ្តាលនៅក្នុងស្រុកនិងក្រៅស្រុក។

## ៤- ជំនួយមនុស្សធម៌និងសង្គ្រោះគ្រោះមហន្តរាយ

កងយោធពលខេមរភូមិន្ទ ត្រូវចូលរួមក្នុងប្រតិបត្តិការជំនួយមនុស្សធម៌និងសង្គ្រោះគ្រោះមហន្តរាយផ្សេងៗ តាមរយៈការឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែង និងក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម)។

កងរាជអាវុធហត្ថ គឺជាកម្លាំងស្នូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ក្តាប់ឱ្យបានគ្រប់ជ្រុងជ្រោយនូវព័ត៌មានគ្រោះមហន្តរាយទូទាំងប្រទេស ប្រើប្រាស់កម្លាំងជំនាញ សម្ភារៈបរិក្ខារ និងមធ្យោបាយសង្គ្រោះឆ្លើយតបឱ្យបានទាន់ពេលវេលាស្រប

ជាមួយនឹងភូមិសាស្ត្រនិងប្រជាសាស្ត្រជាក់ស្តែង។ ក្រៅពីនេះ កងឯកភាពដទៃទៀតនៃកងយោធពលខេមរភូមិន្ទ ត្រូវត្រៀមលក្ខណៈនៅក្នុងការប្រើប្រាស់កម្លាំង មធ្យោបាយ សម្ភារៈ ការងារដឹកនាំបញ្ជា និងកិច្ចសហការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពជួយសង្គ្រោះពេលមានគ្រោះមហន្តរាយកើតឡើងនៅតាមមុខសញ្ញារៀងៗខ្លួន។ ការងារហ្វឹកហ្វឺននិងការធ្វើលំហាត់ជាឯកតោ ភាគីឬជាមួយដៃគូអន្តរជាតិ គឺជាការចាំបាច់ក្នុងការពង្រឹងសមត្ថភាពនិងអន្តរប្រតិបត្តិការ។



កងរាជអាវុធហត្ថក្នុងបេសកកម្មជួយសង្គ្រោះ (រូបភាព: អគ្គនាយកដ្ឋានយោធសេវា)

## ៥- ការឆ្លើយតបនឹងជំងឺឆ្លងរាតត្បាតក្នុងស្រុកនិងជាសកល

ជំងឺឆ្លងរាតត្បាតជាសកលកូវីដ១៩ បានផ្តល់នូវមេរៀននិងពិសោធន៍ជាច្រើនដល់កងយោធពលខេមរភូមិន្ទ ក្នុងការរួមចំណែកជាមួយកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់និងដោះស្រាយបញ្ហាសុខភាពសាធារណៈ។ កងទ័ព នឹងត្រូវបានបន្តចាត់ទុកជាកម្លាំងនាំមុខនៅក្នុងការឆ្លើយតបទៅនឹងវិបត្តិជំងឺឆ្លងរាតត្បាត ជាពិសេសនៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។ កងទ័ពរួមជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត មានភារកិច្ចទំនាក់ទំនងនិងសហការជាមួយ

ប្រទេសជិតខាង នៅក្នុងការអនុវត្តវិធានការថ្នាក់ជាតិឬវិធានការរវាងជាតិណាមួយក្នុងការប្រយុទ្ធជាមួយជំងឺឆ្លងរាតត្បាតឆ្លងកាត់ព្រំដែន។ ក្នុងកាលៈទេសៈដែលប្រទេសជាតិត្រូវបានដាក់ក្រោមច្បាប់ពេលមានអាសន្នកងទ័ពគឺជាកម្លាំងស្នូលនៅក្នុងការអនុវត្តច្បាប់នេះ។


យុទ្ធនាការចាក់វ៉ាក់សាំង (រូបភាព: កងទ័ពជើងគោក)

ដោយសារស្ថានភាពនៃជំងឺឆ្លងរាតត្បាតជាសកល តទៅអនាគតពុំអាចវាយតម្លៃឬប៉ាន់ស្មានទុកជាមុនបាន ការងារត្រៀមបម្រុងរបស់កងយោធពលខេមរភូមិន្ទចាំបាច់ត្រូវធ្វើឡើងជាប្រចាំ ដោយក្នុងនោះស្ថាប័ននិងកងឯកភាពជំនាញពាក់ព័ន្ធចាំបាច់ត្រូវៈ

- ពង្រឹងសមត្ថភាពនិងបង្កើនចំនួនយោធិនសុខាភិបាល

- មានផែនការបង្កើនថវិកាលើការងារសុខាភិបាល ដូចជាបង្កើនសមត្ថភាពយោធិនសុខាភិបាលនិងធ្វើទំនើបកម្មគិលានដ្ឋាននិងមន្ទីរពេទ្យ នៅតាមកងឯកភាពជាដើម

- នៅគ្រប់ស្ថាប័ននិងកងឯកភាព ត្រូវតាមដានជាប់ជាប្រចាំនូវការវិវត្តនៃសភាពការណ៍

- អនុវត្តតាមវិធានការសុខាភិបាលថ្នាក់ជាតិឱ្យបានម៉ត់ចត់។

## ៦- សន្តិសុខបច្ចេកវិទ្យាព័ត៌មាន

នៅក្នុងប្រទេស វិស័យយោធាកំពុងទាញយកអត្ថប្រយោជន៍និងកំពុងប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ លើការគ្រប់គ្រងបញ្ជានិងត្រួតពិនិត្យការងារព័ត៌មានសម្ងាត់និងបណ្តាញទំនាក់ទំនងរបស់កងទ័ព(ថ្នាក់បញ្ជាការនិងថ្នាក់ក្រោម)។ ដើម្បីធ្វើឱ្យកិច្ចការទាំងនេះ ទទួលបាននូវភាពច្បាស់លាស់ រហ័ស សម្ងាត់ សុវត្ថិភាព និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវគិតគូរឱ្យបានហ្មត់ចត់អំពីសន្តិសុខបច្ចេកវិទ្យាព័ត៌មាននេះ។

ទន្ទឹមនឹងការទទួលបានអត្ថប្រយោជន៍ដ៏មហាសាល ហានិភ័យនិងការគំរាមកំហែងផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន បានក្លាយជាប្រធានបទយ៉ាងសំខាន់ដែលកំពុងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ពីបណ្តាប្រទេសនៅក្នុងតំបន់និងពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ។ ដោយឡែក កងយោធពលខេមរភូមិន្ទ ត្រូវមានគោលនយោបាយនិងផែនការយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងទាំងនោះជាចាំបាច់។

នៅក្នុងបរិបទនេះ កងយោធពលខេមរភូមិន្ទនឹងដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

### ក- តម្រូវការច្បាប់សន្តិសុខបច្ចេកវិទ្យាព័ត៌មាន

ការបង្កើតក្របខណ្ឌនីតិប្រតិបត្តិ លើប្រព័ន្ធសន្តិសុខបច្ចេកវិទ្យានិងព័ត៌មាន គឺជាធាតុផ្សំសំខាន់បំផុតក្នុងការផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំនិងគោលការណ៍ស្នូលសម្រាប់ពង្រឹង អភិវឌ្ឍយុទ្ធសាស្ត្រការពារជាតិលើផ្នែកបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន។

គោលបំណងនៃការបង្កើតច្បាប់សន្តិសុខបច្ចេកវិទ្យាព័ត៌មាន គឺដើម្បីផ្ដោតលើការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់បទល្មើសបច្ចេកវិទ្យាឬឧក្រិដ្ឋកម្មបច្ចេកវិទ្យាគ្រប់រូបភាព ដែលជាសកម្មភាពអាចបង្កផលប៉ះពាល់ដល់ស្ថិរភាពនិងសន្តិសុខជាតិ។ ដើម្បីបង្កើតក្របខណ្ឌនីតិប្បញ្ញត្តិឬច្បាប់ផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មានឱ្យមានប្រសិទ្ធភាព គឺត្រូវឈរលើកត្តាគោលសំខាន់ចំនួនបី គឺការកំណត់និយាមរួមការបង្កើតច្បាប់ស្របតាមច្បាប់ជាតិនិងអន្តរជាតិ និងការធ្វើវិសោធនកម្មច្បាប់ស្របតាមការវិវត្តនៃស្ថានភាពជាក់ស្ដែង។

ក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្ត ស្ដីពីសន្តិសុខបច្ចេកវិទ្យាព័ត៌មានលើវិស័យការពារជាតិ គឺជាការងារអាទិភាពដែលតម្រូវឱ្យមានការយកចិត្តទុកដាក់និងដោះស្រាយឱ្យបានទាន់ពេលវេលានិងសមស្របទៅនឹងការវិវត្តយ៉ាងឆាប់រហ័សនៃសកលភាវូបនីយកម្មបច្ចេកវិទ្យា ដើម្បីប្រយុទ្ធប្រឆាំងនិងទប់ស្កាត់បទល្មើសបច្ចេកវិទ្យាដែលបង្កឱ្យមានអស្ថិរភាពនិងអសន្តិសុខជាតិ។

## ខ- រចនាសម្ព័ន្ធនិងក្របខណ្ឌអង្គភាព

គ្រប់ស្ថាប័នត្រូវពង្រឹងរចនាសម្ព័ន្ធចាត់តាំង ដើម្បីឱ្យអង្គភាពមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ធ្វើទំនើបកម្មបច្ចេកវិទ្យាយោធា និងធ្វើការតាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ វាយតម្លៃ ការពារ ទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលានូវបទល្មើសបច្ចេកវិទ្យានានា។ លើសពីនេះ អង្គភាពត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្ដាអង្គភាពជំនាញពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលក្នុងកម្រិតយុទ្ធសាស្ត្រនិងកម្រិតប្រតិបត្តិការដើម្បីចែករំលែកព័ត៌មាន ផ្លាស់ប្ដូរពិសោធន៍និងផែនការយុទ្ធសាស្ត្រសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ឱ្យគ្នាទៅវិញទៅមក។

## គ- ធនធានមនុស្ស

បើទោះបីជាអង្គភាពឬស្ថាប័នបានបំពាក់ឧបករណ៍ សម្ភារៈបរិក្ខារទំនើបៗ រចនាសម្ព័ន្ធអង្គភាពនិងច្បាប់ល្អយ៉ាងណាក៏ដោយ តែអ្វីដែលសំខាន់និង

មិនអាចខ្វះបាននោះ គឺធនធានមនុស្សដែលមានជំនាញឯកទេសច្បាស់លាស់ សមត្ថភាព និងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកប ដោយប្រសិទ្ធភាពនិងលទ្ធផលខ្ពស់។ ដូច្នេះហើយការអភិវឌ្ឍ ការយល់ដឹង និងការ កសាងធនធានមនុស្សក្នុងកងយោធពលខេមរភូមិន្ទលើវិស័យព័ត៌មានវិទ្យានិងផ្នែក សន្តិសុខបច្ចេកវិទ្យាព័ត៌មានជាកត្តាអាទិភាពដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត។

ដើម្បីបណ្តុះបណ្តាលធនធានមនុស្សឱ្យមានគុណភាពខ្ពស់ សម្រាប់ បម្រើការផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យការពារជាតិ អង្គភាពពាក់ព័ន្ធ ចាំបាច់ត្រូវមានផែនការយុទ្ធសាស្ត្រ និងគោលនយោបាយច្បាស់លាស់ ដូចជាការ កសាងមជ្ឈមណ្ឌលហ្វឹកហ្វឺនជំនាញព័ត៌មានវិទ្យា សន្តិសុខបច្ចេកវិទ្យាព័ត៌មាន ការ រៀបចំនីតិវិធីនៃការជ្រើសរើសបុគ្គលិកបម្រើការ ឱ្យមានសុក្រិតភាពនិងតម្លាភាព ព្រមទាំងធ្វើការបំប៉ននិងផ្សព្វផ្សាយចំណេះដឹងឱ្យបានទូលំទូលាយ ដើម្បីលើក កម្ពស់ការយល់ដឹងផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន ដល់យោធិនក្នុងកងយោធ-ពលខេមរភូមិន្ទ។

### ឃ- បច្ចេកទេស

ការពង្រឹងសមត្ថភាពលើផ្នែកបច្ចេកទេស គឺជាកត្តាចម្បងមួយក្នុងការ ឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័ស នៃបច្ចេកវិទ្យានិងកំណើននៃការ គំរាមកំហែងពីក្រុមឧក្រិដ្ឋជន ដែលបាននិងកំពុងធ្វើការអភិវឌ្ឍសមត្ថភាពរបស់ពួក គេដើម្បីវាយប្រហារ ស្របតាមការវិវត្តរបស់បច្ចេកវិទ្យានាពេលបច្ចុប្បន្ននិងពេល អនាគត។ ដើម្បីអភិវឌ្ឍសមត្ថភាពបច្ចេកទេសក្នុងការការពារផ្នែកសន្តិសុខបច្ចេក វិទ្យាព័ត៌មាន ចាំបាច់ត្រូវធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធប្រតិបត្តិការ កម្មវិធី បណ្តាញស្នូលនិងបណ្តាញចែកចាយ ទៅតាមនិន្នាការវិវឌ្ឍនៃបច្ចេកវិទ្យា ដោយ ផ្តោតសំខាន់លើការធ្វើបច្ចុប្បន្នភាពផ្នែករឹងនិងផ្នែកទន់ជាប្រចាំ ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាដែលអាចពង្រីកស្របតាមតម្រូវការនាពេលអនាគត ហេដ្ឋារចនាសម្ព័ន្ធ

បច្ចេកវិទ្យាត្រូវមាននិរន្តរភាព មានសមត្ថភាពក្នុងការទប់ស្កាត់និងការពារពីការគំរាមកំហែងគ្រប់រូបភាព។

## ខ- កិច្ចសហប្រតិបត្តិការ

ការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់បទល្មើសបច្ចេកវិទ្យា ដែលបង្កឱ្យមានអស្ថិរភាពដល់សន្តិសុខជាតិ និងដើម្បីឱ្យកិច្ចសហប្រតិបត្តិការសន្តិសុខបច្ចេកវិទ្យាព័ត៌មានរបស់កងយោធពលខេមរភូមិន្ទ ទទួលបានជោគជ័យនិងមានប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការគ្រប់ជាន់ថ្នាក់ទាំងអស់ ទាំងកម្រិតថ្នាក់ជាតិនិងអន្តរជាតិ ព្រមទាំងវិស័យឯកជនដែលជាភារកិច្ចចម្បងត្រូវសម្រេចឱ្យបានក្នុងការឈានទៅរកការចងសម្ព័ន្ធភាពជាដៃគូអន្តរជាតិនៅលើពិភពលោក។

កិច្ចសហការថ្នាក់ជាតិ ចាំបាច់ត្រូវមានការចូលរួមពីក្រសួងការពារជាតិ អង្គភាពពាក់ព័ន្ធចំណុះកងយោធពលខេមរភូមិន្ទ ក្រសួង ស្ថាប័នរដ្ឋ វិទ្យាស្ថានស្រាវជ្រាវបច្ចេកវិទ្យា សាកលវិទ្យាល័យធំៗ ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុក ព្រមទាំងអង្គភាពជំនាញ។

ចំពោះកិច្ចសហប្រតិបត្តិការក្នុងតំបន់ ទាមទារការចូលរួមចែករំលែកផ្លាស់ប្តូរបទពិសោធនិងយុទ្ធសាស្ត្រការពារជាតិ ក្នុងវិស័យបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មានរវាងរដ្ឋជាសមាជិកអាស៊ានទាំងអស់ ជាលក្ខណៈទ្វេភាគីឬពហុភាគី។ លើសពីនេះ ចាំបាច់ត្រូវតែពង្រីកកិច្ចសហប្រតិបត្តិការទៅដល់ថ្នាក់អន្តរជាតិ ជាមួយដៃគូសម្ព័ន្ធមិត្ត ដែលមានបច្ចេកវិទ្យាទំនើបជឿនលឿននិងបទពិសោធន៍ច្រើនលើវិស័យសន្តិសុខបច្ចេកវិទ្យាព័ត៌មាន។

## ច- ការស្រាវជ្រាវនិងការអភិវឌ្ឍ

ការស្រាវជ្រាវនិងការអភិវឌ្ឍទៅលើបច្ចេកវិទ្យាព័ត៌មាន ជាកត្តាចម្បងដើម្បីឱ្យប្រទេស ឬអង្គភាពអាចទទួលបាននូវភាពជឿនលឿនខាងបច្ចេកវិទ្យាថ្មីប្រកបដោយទំនុកចិត្ត។ ដើម្បីឱ្យគម្រោងស្រាវជ្រាវនិងអភិវឌ្ឍអាចដំណើរការបានដោយជោគជ័យ ចាំបាច់ត្រូវមានការគាំទ្រនិងជំរុញលើកទឹកចិត្តឱ្យក្រសួងឬស្ថាប័ន

ដែលពាក់ព័ន្ធ ធ្វើការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន បង្កើតក្រុមជំនាញជាន់ខ្ពស់ សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗដើម្បីធានានិរន្តរភាព។ ការបង្កើតឱ្យមានវេទិកាដើម្បីសម្របសម្រួល ការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង ពិសោធន៍ និងនិន្នាការវិវឌ្ឍន៍នៃបច្ចេកវិទ្យាដោយមានការចូលរួមពីស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន។

# ជំពូក៦
## កំណែទម្រង់យោធា

កងយោធពលខេមរភូមិន្ទ នឹងបន្តអនុវត្តផែនការកំណែទម្រង់យោធាឱ្យកាន់តែស៊ីជម្រៅថែមទៀត ទោះជាប្រឈមទៅនឹងការលំបាកចម្បងៗមួយចំនួនក៏ដោយ។ កំណែទម្រង់តទៅថ្ងៃអនាគត ផ្តោតលើកិច្ចការសំខាន់ៗដូចខាងក្រោម៖

### ១- កែសម្រួលរចនាសម្ព័ន្ធចាត់តាំងនិងប្រព័ន្ធដឹកនាំបញ្ជា

រចនាសម្ព័ន្ធចាត់តាំងក្នុងក្របខណ្ឌការងារ ត្រូវតែធ្វើការកែសម្រួលឱ្យបានល្អប្រសើរដើម្បីឆ្លើយតបទៅនឹងតម្រូវការភារកិច្ចចាំបាច់ជាក់ស្តែង ក្នុងសភាពការណ៍បច្ចុប្បន្ន ដើម្បីបញ្ចៀសឱ្យបាននូវភាពត្រួតគ្នានៃរចនាសម្ព័ន្ធការងាររវាងក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន និងកងទ័ពទាំងបីប្រភេទ ដើម្បីធានាប្រសិទ្ធភាពនិងគុណភាពការងារក្នុងទិសដៅអនុវត្តយូរអង្វែង។ គ្រប់ឋានានុក្រមទាំងអស់នឹងបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងនិងដឹកនាំបញ្ជា កិច្ចការបទដ្ឋានបច្ចេកទេស និងកិច្ចការរដ្ឋបាលឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង ដើម្បីសម្រួលភាពស្មុគស្មាញនៃឋានា នុក្រមនិងអនុលោមទៅតាមតួនាទីភារកិច្ចរបស់ស្ថាប័ននិងអង្គភាពនីមួយៗ។

### ២- ការងារបុគ្គលិក

ការកំណត់ក្របខណ្ឌតាមស្ថាប័ននិងអង្គភាពនីមួយៗ ត្រូវមានការធ្វើបច្ចុប្បន្នភាពដើម្បីឱ្យស្របទៅនឹងតម្រូវការជាក់ស្តែងទៅតាមកាលៈទេសៈ។ ទន្ទឹមនឹងនេះ ការជ្រើសរើសទ័ពបំពេញឱ្យតាមកងឯកភាព នឹងត្រូវអនុវត្តតាមផែនការនិងលទ្ធភាពរបស់រាជរដ្ឋាភិបាល ដោយត្រូវអនុវត្តប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់បំផុត។

បន្តសម្រិតសម្រាំងជ្រើសរើសពលទាហាន នាយទាហានរង និងនាយទាហានដើម្បីបណ្តុះបណ្តាល បំប៉ន ហ្វឹកហ្វឺនកងទ័ពថ្មី ហ្វឹកហ្វឺនកងទ័ពជំនាញទាំងនៅក្នុងនិងក្រៅប្រទេស សំដៅពង្រឹងសមត្ថភាពជំនាញនិងប្រសិទ្ធភាពនៃការបំពេញកាតព្វកិច្ច។ កសាងយោធិនគ្រប់ថ្នាក់ គ្រប់ជំនាញ សម្រាប់បន្តវេន គឺជាការចាំបាច់ និងអនុវត្តដោយប្រសិទ្ធភាព គុណភាព និងធានានិរន្តរភាពជាប់ជាប្រចាំ។

កងយោធពលខេមរភូមិន្ទត្រូវបន្តធ្វើការអប់រំចិត្តសាស្ត្រ ច្បាប់អន្តរជាតិនៅលើសមរភូមិ ស្មារតីភក្តីរបស់កងទ័ពចំពោះជាតិ សាសនា ព្រះមហាក្សត្រ ជាពិសេសចំពោះរាជរដ្ឋាភិបាល ព្រមទាំងពង្រឹងវិន័យរបស់យោធិនសំដៅរក្សាកិត្យានុភាព វិន័យ និងសេចក្តីថ្លៃថ្នូរបស់កងទ័ព។ លើសពីនេះទៀតត្រូវបន្តជំរុញការអនុវត្តច្បាប់ស្តីពីយោធិនជាប់កិច្ចសន្យា ដើម្បីកសាងប្រភពកម្លាំងដែលប្រើប្រាស់ធនធានតិចតែមាននិរន្តរភាពសម្រាប់បម្រើឱ្យវិស័យការពារជាតិ។ ការអនុវត្តច្បាប់ស្តីពីសោធននិវត្តន៍នឹងត្រូវពង្រឹង ដើម្បីបង្កើនប្រសិទ្ធភាពនៃការដាក់យោធិនឱ្យចូលនិវត្តន៍តាមកាលកំណត់ ។

ការពិនិត្យលទ្ធភាព ក្នុងការអនុវត្តច្បាប់កាតព្វកិច្ចយោធាដែលចូលជាធរមានរួចហើយ គឺជាកត្តាសំខាន់ដើម្បីបង្កើនចំនួនយោធិនបម្រុងក្រោយពេលបានបំពេញកាតព្វកិច្ចយោធារួចហើយ ក៏ដូចជាធ្វើឱ្យមានខឿនការពារជាតិកាន់តែរឹងមាំ ព្រមទាំងបង្កើនការចូលរួមចំណែករបស់ប្រជាពលរដ្ឋ នៅក្នុងកាតព្វកិច្ចការពារជាតិមាតុភូមិ។

ក្រោយពីយោធិនត្រូវបានដាក់ឱ្យចូលនិវត្តន៍ គ្រប់ស្ថាប័ន អង្គភាពនៃកងយោធពលខេមរភូមិន្ទ នឹងត្រូវតែបន្តយកចិត្តទុកដាក់លើកកម្ពស់គុណតម្លៃអតីតយុទ្ធជនឱ្យបានល្អស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយចូលរួមជាមួយក្រសួង ស្ថាប័ន មន្ទីរ អាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធយកចិត្តទុកដាក់តាមដាន លើកទឹកចិត្ត ផ្តល់ឱកាស និងគ្រប់គ្រងអតីតយុទ្ធជនតាមមូលដ្ឋានឱ្យបានសមស្របដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការរស់នៅ ប្រកបដោយភាពសុខដុមរមនា។

## ៣- ការគ្រប់គ្រងធនធានថវិកាការពារជាតិ

ក្រសួងការពារជាតិចាំបាច់ត្រូវទទួលបានធនធានសមស្រប ទៅតាមដំណាក់កាលដើម្បីអភិវឌ្ឍធនធានមនុស្ស ធ្វើទំនើបកម្មបច្ចេកវិទ្យា សម្ភារៈបច្ចេកទេស យុទ្ធោបករណ៍ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ល។ ធនធានទាំងនោះ ត្រូវមានការកំណត់អាទិភាពឱ្យបានច្បាស់លាស់ក្នុងការប្រើប្រាស់ មានជាអាទិ៍ ការលើកកម្ពស់សមត្ថភាពយោធា លទ្ធភាពរបស់កងយោធពលខេមរភូមិន្ទក្នុងកិច្ចការពារព្រំដែនគោក ទឹក អាកាស និងទំនើបនីយកម្មបច្ចេកវិទ្យាជាដើម ដើម្បីឆ្លើយតបនឹងភាពប្រឈមនិងការគំរាមកំហែងផ្នែកសន្តិសុខដែលកើតមានឡើង។ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រទាំងឡាយ ការកសាងផែនការនិងការចាត់ចែងធនធានត្រូវតែឆ្លើយតបគ្នាទៅវិញទៅមក។

## ៤- ឧស្សាហកម្មយោធា

គំនិតផ្តួចផ្តើមបង្កើតឧស្សាហកម្មយោធា គឺជាភាពចាំបាច់បំផុតរបស់ក្រសួងការពារជាតិដើម្បីលើកកម្ពស់ប្រៀបការពារជាតិ ក៏ដូចជាដើរឱ្យទាន់សម័យកាលនៃភាពជឿនលឿននៃបច្ចេកវិទ្យា និងនវានុវត្តន៍យោធា។ គោលដៅចម្បងនៃការបង្កើតឧស្សាហកម្មយោធា គឺដើម្បីជួយទ្រទ្រង់តម្រូវការការពារជាតិចាំបាច់មួយចំនួនតាមរយៈការបង្កើតឱ្យមានភាពធន់ ជាមួយនឹងការពឹងផ្អែកលើសម្ភារៈយោធាក្នុងស្រុកសម្រាប់រយៈពេលយូរអង្វែងទៅមុខ។ ការអភិវឌ្ឍឧស្សាហកម្មយោធា គឺមានសារៈសំខាន់ក្នុងការបំពេញតម្រូវការជាមូលដ្ឋានប្រកបដោយនិរន្តរភាព តាមរយៈការជំរុញសមត្ថភាពផលិតយុទ្ធោបករណ៍ សម្ភារៈសឹកខ្នាតតូច និងមធ្យម ក៏ដូចជាដើម្បីកាត់បន្ថយការពឹងផ្អែកទាំងស្រុងលើការនាំចូលសម្ភារៈទាំងនោះពីបរទេស ជាពិសេសនឹងផ្តល់កាលានុវត្តភាពដល់កងយោធពលខេមរភូមិន្ទ ក្នុងការចូលរួមយ៉ាងពេញលេញក្នុងកិច្ចសហប្រតិបត្តិការឧស្សាហកម្មយោធា ក្នុងកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិនានាលើវិស័យនេះផងដែរ។

ទន្ទឹមនឹងគោលដៅរយៈពេលវែង ក្នុងការលើកកម្ពស់ការពឹងផ្អែកលើខ្លួនឯង ឧស្សាហកម្មយោធានឹងរួមចំណែកដល់ការបង្កើនសមត្ថភាពកងទ័ព តាមរយៈការបំពេញតម្រូវការឱ្យបានគ្រប់គ្រាន់ នូវយុទ្ធោបករណ៍និងសម្ភារៈសឹកដែលជាមូលដ្ឋានចាំបាច់សម្រាប់ការហ្វឹកហ្វឺននិងសមយុទ្ធយោធានានា។

## ៥- វិស័យអប់រំបណ្តុះបណ្តាល

ស្ថាប័នអប់រំហ្វឹកហ្វឺនជាន់ខ្ពស់និងអាជីព ត្រូវយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវអំពីយុទ្ធសាស្ត្រនិងកិច្ចការពារជាតិ។ គ្រឹះស្ថានអប់រំយោធានីមួយៗត្រូវធ្វើទំនើបកម្មកម្មវិធីសិក្សា កសាងបន្ទប់ពិសោធន៍ បណ្ណាល័យ និងធ្វើការអភិវឌ្ឍឯកសារគោល ឱ្យស្របតាមបច្ចេកវិទ្យាយោធានិងការវិវត្តថ្មីៗក្នុងតំបន់ក៏ដូចជាសកលលោក ដើម្បីធ្វើឱ្យប្រព័ន្ធអប់រំយោធាមានកម្រិតនិងគុណភាពស្របតាមនិយាមអន្តរជាតិ។ ទន្ទឹមនឹងនេះ ការបញ្ចូលប្រវត្តិសាស្ត្រយោធានិងនយោបាយឈ្នះ ឈ្នះ ក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានអប់រំហ្វឹកហ្វឺនយោធា គឺជាភាពចាំបាច់និងមានសារៈសំខាន់ ដើម្បីឱ្យយោធិនគ្រប់រូបយល់ឱ្យកាន់តែស៊ីជម្រៅ អំពីប្រវត្តិសាស្ត្រនិងគុណតម្លៃនៃនយោបាយឈ្នះ ឈ្នះ។ ការពង្រីកកម្មវិធីផ្លាស់ប្តូរការសិក្សាជាមួយនឹងបណ្តាប្រទេសជាដៃគូក្នុងលំដាប់ហ្វឹកហ្វឺនយោធិនអាជីព គឺជាគោលដៅសំខាន់នៅក្នុងវិស័យនេះ។

ដំណើរការកែសម្រួលសាលាកងទ័ពជើងទឹក ឱ្យទៅជាវិទ្យាស្ថានកងទ័ពជើងទឹក បានសម្រេចគោលដៅជាស្ថាពរហើយ ដើម្បីលើកកម្រិតសមត្ថភាពនិងចំណេះដឹង ជំនាញកងទ័ពជើងទឹកកម្ពុជាឱ្យកាន់តែប្រសើរឡើង ឆ្លើយតបទៅនឹងតម្រូវការនៃវិស័យការពារជាតិនាពេលបច្ចុប្បន្ននិងតទៅថ្ងៃអនាគត។ ជាមួយគ្នានេះដែរ មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម (NPMEC) នឹងវិវត្តខ្លួនទៅជាមជ្ឈមណ្ឌលឧត្តមានុវត្តន៍ថ្នាក់តំបន់ ដើម្បីជាផ្នែកមួយក្នុងការជំរុញកិត្តិនាមរបស់កម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងលើកិច្ចការងាររក្សាសន្តិភាព អ.ស.ប តាមរយៈការចែករំលែកពិសោធន៍ ឧត្តមានុវត្តន៍និងការចូល

រួមបណ្តុះ បណ្តាលជំនាញដល់កងកម្លាំងរក្សាសន្តិភាពរបស់បណ្តាប្រទេសជាមិត្ត នៅមជ្ឈ មណ្ឌលរបស់កម្ពុជា។

ការឧបត្ថម្ភធនធាន ទាំងថវិកា និងសម្ភារៈ គឺជាការចាំបាច់ណាស់ក្នុងកំណែទម្រង់នេះ គឺសំដៅសម្រេចបានទិសដៅនៃការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងពិសោធន៍ទៅតាមមុខវិជ្ជានិងជំនាញឯកទេស ក្នុងនោះគឺធានាឱ្យបានលើការបំពាក់មធ្យោបាយនិងសម្ភារៈរូបវន្តគ្រប់ប្រភេទដល់វគ្គបណ្តុះបណ្តាល។



ការហ្វឹកហ្វឺនគឺជាកាតព្វកិច្ចចម្បងនៅក្នុងការលើកកម្រិតសមត្ថភាព (រូបភាព: ទីចាត់ការហ្វឹកហ្វឺន)

# ជំពូក៧
# ការចូលរួមក្នុងវិស័យការពារជាតិនិងសន្តិសុខលើឆាកអន្តរជាតិ

## ១- គោលការណ៍នៃកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី

កងយោធពលខេមរភូមិន្ទ តែងប្រកាន់នូវគោលជំហរច្បាស់លាស់និងខ្ជាប់ខ្ជួនក្នុងកិច្ចសហប្រតិបត្តិការយោធាជាមួយបណ្តាប្រទេសជាដៃគូ ក្នុងគោលដៅពង្រឹងសាមគ្គីភាព ជំរុញសមត្ថភាពការពារជាតិ បង្កើនមិត្តខាងក្រៅដោយឈរលើគោលការណ៍ឯករាជ្យ អព្យាក្រឹត្យ មិនប្រកាន់និន្នាការនយោបាយឬមនោគមន៍វិជ្ជា និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមកដោយអនុលោមតាមទិសដៅរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ទំនាក់ទំនងអន្តរជាតិប្រកបដោយភាពរឹងមាំនិងចីរភាព។ ផ្អែកលើរបត់នៃការវិវត្តក្នុងវិស័យនយោបាយ សន្តិសុខ និងសេដ្ឋកិច្ចទាំងក្នុងតំបន់និងសកលលោកនិងជាផ្នែកមួយនៃគោលដៅជាយុទ្ធសាស្ត្រ របស់គោលនយោបាយការពារជាតិឆ្ពោះទៅឆ្នាំ២០៣០ កងយោធពលខេមរភូមិន្ទនឹងបន្តពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងល្អជាមួយបណ្តាប្រទេសជិតខាង ប្រទេសក្នុងតំបន់ និងអន្តរជាតិបន្ថែមទៀតដោយឈរលើគោលការណ៍ជាមូលដ្ឋានដែលបានកំណត់និងបានអនុវត្តខាងលើ។

ដើម្បីធានាភាពរឹងមាំនិងចីរភាពនេះ កងយោធពលខេមរភូមិន្ទនឹងបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យបានស៊ីជម្រៅបន្ថែមទៀត ជាមួយបណ្តាប្រទេសជាដៃគូសន្តិសុខ តាមរយៈយន្តការកិច្ចសហប្រតិបត្តិការការទូតយោធាដោយបង្កើនអនុព័ន្ធយោធាកម្ពុជាប្រចាំនៅបរទេស និងអនុព័ន្ធយោធាបរទេសប្រចាំនៅកម្ពុជា។ កងយោធពលខេមរភូមិន្ទក៏ប្តេជ្ញានឹងបន្តជំរុញកិច្ចសហប្រតិបត្តិការក្នុងរូបភាពជាជំនួយយោធា ការបង្កើនការចុះអនុស្សរណៈយោគយល់ជាមួយបណ្តាប្រទេសជាដៃគូ ការផ្លាស់ប្តូរទស្សនកិច្ចមន្ត្រីយោធា ការធ្វើលំហាត់សមយុទ្ធរួមគ្នា ការផ្លាស់ប្តូរពិសោធន៍ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកដែលជាកិច្ចការសំខាន់ក្នុងការនាំមកនូវផលប្រយោជន៍សម្រាប់កងយោធពលខេមរភូមិន្ទ ដើម្បីអភិវឌ្ឍ

សមត្ថភាពការពារជាតិ និងជាការរួមចំណែកដល់ការការពារសន្តិសុខជាតិនិងអន្តរជាតិ។

គោលនយោបាយការពារជាតិកម្ពុជា គឺបើកចំហនិងស្វាគមន៍បណ្តាប្រទេសជាមិត្តដែលចង់ពង្រឹងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើវិស័យការពារជាតិនិងសន្តិសុខដោយឈរលើគោលការណ៍ស្មើភាព គោរពឯករាជ្យភាពនិងអធិបតេយ្យរបស់កម្ពុជា។ ជាពិសេស កិច្ចសហប្រតិបត្តិការយោធាត្រូវឆ្លើយតបនូវតម្រូវការរបស់កម្ពុជានិងត្រូវប្រកបដោយស្មារតីមិត្តភាពពិតប្រាកដ គោរពផលប្រយោជន៍គ្នាទៅវិញទៅមកដោយឥតលក្ខខណ្ឌ។

## ២- គោលនយោបាយទំនើបកម្មមូលដ្ឋានសមុទ្ររាម

ការអភិវឌ្ឍសមត្ថភាពកងយោធពលខេមរភូមិន្ទ គឺជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចគ្នាទៅនឹងប្រទេសដទៃទៀតនៅលើពិភពលោក។ ទំនើបកម្មសម្រាប់មូលដ្ឋានសមុទ្ររាមដែលបានដំណើរការជាច្រើនឆ្នាំមកហើយ គឺជាផ្នែកដ៏សំខាន់មួយនៃផែនការអភិវឌ្ឍន៍សមត្ថភាពកងទ័ពជើងទឹកកម្ពុជា។ ទំនើបកម្មមូលដ្ឋានសមុទ្ររាមនេះ គឺជាសិទ្ធិនិងអធិបតេយ្យរបស់កម្ពុជា ក្នុងការបម្រើផលប្រយោជន៍ដល់កម្ពុជានិងតំបន់ទាំងមូល។ ទន្ទឹមនឹងនេះ ទំនើបកម្មមូលដ្ឋានសមុទ្ររាមនេះ គឺមិនមែនជាការគំរាមកំហែងដល់សន្តិសុខប្រទេសជិតខាងឬប្រទេសណាមួយនៅក្នុងតំបន់នោះទេ ដោយគោលបំណងនៃទំនើបកម្មមូលដ្ឋានសមុទ្ររាមនេះ គឺដើម្បីគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នូវដែនសមុទ្ររបស់កម្ពុជានិងចូលរួមយ៉ាងពេញលេញ ជាមួយបណ្តាប្រទេសដទៃទៀត នៅក្នុងការពង្រឹងសន្តិភាព ស្ថិរភាព និងសន្តិសុខនៅក្នុងតំបន់។ កម្ពុជាមានគោលជំហរយ៉ាងម៉ឺងម៉ាត់ ដោយមិនអនុញ្ញាតឱ្យមានជាដាច់ខាត នូវការប្រើប្រាស់ផ្តាច់មុខនូវមូលដ្ឋានសមុទ្ររាមដោយបរទេសណាមួយនោះឡើយ។

គោលជំហរដ៏ច្បាស់លាស់នេះ ផ្អែកលើមាត្រា៥៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា៖

"ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត្យ អចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអាព្យាក្រឹត្យភាពរបស់ខ្លួនឡើយ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតិឲ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតិឲ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលជំនួយបរទេស ជាសម្ភារៈយោធា អាវុធ គ្រប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស។"

## ៣- កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌតំបន់

កងយោធពលខេមរភូមិន្ទនឹងបន្តរួមចំណែកឱ្យកាន់តែសកម្ម ក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់ ដែលជាគន្លឹះសំខាន់សម្រាប់ការអភិវឌ្ឍនិងវឌ្ឍនភាពតំបន់ប្រកបដោយចីរភាព តាមរយៈការបន្តចូលរួមឱ្យកាន់តែផុសផុលក្នុងកិច្ចសហប្រតិបត្តិការជាក់ស្តែង ក្នុងក្របខណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ASEAN Defence Ministers' Meeting - ADMM) និងយន្តការពាក់ព័ន្ធ។ កម្ពុជាយល់ច្បាស់ថាការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសមួយ គឺ

ត្រូវពឹងផ្អែកលើស្ថិរភាពនិងសន្តិភាពរបស់តំបន់ទាំងមូល ដូចនេះការពង្រឹងយន្តការនៃកិច្ចសហប្រតិបត្តិការ ADMM គឺជាកត្តាដ៏សំខាន់មួយដែលត្រូវយកចិត្តទុកដាក់ដើម្បីពង្រឹងទំនុកចិត្តក្នុងតំបន់និងសមត្ថភាពឆ្លើយតបរួមគ្នារបស់អាស៊ាន ទៅនឹងការប្រែប្រួលនៃបរិយាកាសសន្តិសុខនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូល។ ជាក់ស្តែង ក្រសួងការពារជាតិបានកំណត់ទិសដៅជាអាទិភាពក្នុងពេលដែលខ្លួនធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ ADMM ដោយដាក់ចេញនូវផែនការជំរុញកិច្ចសហប្រតិបត្តិការយោធាជាក់ស្តែង ក្នុងការឆ្លើយតបរួមគ្នាទៅនឹងជំងឺរាតត្បាតសកលនិងគំនិតផ្តួចផ្តើមដើម្បីលើកកម្ពស់ការចូលរួមរបស់អាស៊ាន ក្នុងការចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ តាមរយៈការលើកទឹកចិត្តឱ្យមានការចូលរួមរបស់ស្ត្រីអាស៊ានកាន់តែច្រើនថែមទៀត។



ការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន
(រូបភាព: អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស)

កងយោធពលខេមរភូមិន្ទនឹងផ្តល់អាទិភាព ដល់ការបង្កើនការចូលរួមនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក (ASEAN Defence Ministers’ Meeting-Plus - ADMM-Plus) តាមរយៈការចូលរួមក្នុងកិច្ចពិភាក្សា លំហាត់រួមគ្នា និងកិច្ចប្រជុំក្រុម

ការងារជំនាញគ្រប់កម្រិត ព្រមទាំងចូលរួមបង្កើតគំនិតផ្តួចផ្តើមថ្មីៗសម្រាប់កិច្ចសហប្រតិបត្តិការសន្តិសុខ និងការពារជាតិសំដៅលើកកម្ពស់ស្មារតីសាមគ្គីភាព កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន និងប្រទេសបូក ដើម្បីបង្កើនការកសាងសមត្ថភាពរួម ភាពជឿជាក់ និងទំនុកចិត្តទៅវិញទៅមកដោយផ្អែកលើគោលការណ៍សាមគ្គីភាពនិងមជ្ឈភាពអាស៊ាន និងការឆ្លើយតបរួមគ្នារបស់អាស៊ានទៅនឹងការប្រែប្រួលនៃស្ថានការណ៍សន្តិសុខ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ កម្ពុជានឹងបន្តចូលរួមធ្វើជាសហប្រធាននៃក្រុមការងារជំនាញ ក្នុងក្របខណ្ឌ ADMM-Plus បន្តទៀត ដើម្បីរួមចំណែកកសាងសមត្ថភាពតំបន់ តាមរយៈការចែករំលែកពិសោធន៍និងឧត្តមានុវត្តន៍។ល។ ទន្ទឹមនឹងនេះដែរ កងយោធពលខេមរភូមិន្ទក៏នឹងបន្តចូលរួមកិច្ចសន្ទនាសន្តិសុខនិងការពារជាតិ ក្នុងក្របខណ្ឌសន្តិសុខពហុភាគីផ្សេងទៀត រួមទាំងវេទិកាតំបន់អាស៊ានផងដែរ ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិ-ការក្នុងការដោះស្រាយបញ្ហាសន្តិសុខក្នុងតំបន់។

កម្ពុជាយល់ឃើញថា កិច្ចសហប្រតិបត្តិការជាក់ស្តែងក្នុងក្របខណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូកនាពេលបច្ចុប្បន្ននេះ មានប្រសិទ្ធភាពគ្រប់គ្រាន់ក្នុងការជំរុញសមត្ថភាពអន្តរប្រតិបត្តិការក្នុងការឆ្លើយតបបញ្ហាប្រឈមរួមក្នុងតំបន់ ដូច្នេះកម្ពុជាគាំទ្រការចូលរួមក្នុងចំនួនមួយសមស្របបែបនេះ ដើម្បីបន្តនិរន្តរភាពនៃយន្តការនេះប្រកបដោយប្រសិទ្ធភាព។ ពាក់ព័ន្ធនឹងបញ្ហាវិវាទក្នុងតំបន់ កម្ពុជាប្រកាន់ខ្ជាប់នូវគោលជំហរដោះស្រាយបញ្ហាដោយភាពអំណត់ឱ្យដល់ទីបំផុត និងដោយមធ្យោបាយសន្តិវិធីដែលពឹងផ្អែកលើច្បាប់អន្តរជាតិ។ ក្នុងនាមជារដ្ឋភាគីនៃសន្ធិសញ្ញាមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ (TPNW) អនុសញ្ញាអាវុធគីមី (CWC) សន្ធិសញ្ញាអាវុធជីវសាស្ត្រ (BWC) សន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ) និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធផ្សេងទៀត កម្ពុជាគោរពយ៉ាងម៉ឺងម៉ាត់ទៅនឹងគោលការណ៍ទាំងនេះ ដែលមានសារប្រយោជន៍ចំពោះការរក្សាសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់។ ចំពោះការបង្កើតសម្ព័ន្ធភាពនិងភាពជាដៃគូរវាងប្រទេសមហាអំណាចនៅក្នុងតំបន់នាពេលថ្មីៗ ក្រោមហេតុផលដើម្បីផល

ប្រយោជន៍រួមរបស់តំបន់ កម្ពុជាមើលឃើញភាពចម្រូងចម្រាស់ខ្លះដែលហាក់ដូចជាកំពុងនាំឆ្ពោះទៅរកការប្រឈមមុខគ្នានិងការរត់ប្រណាំងសព្វាវុធ។



រដ្ឋមន្ត្រីការពារជាតិកម្ពុជា និងវៀតណាម នៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការយោធាទ្វេភាគី (រូបភាព: អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស)

ជាក់ស្តែង ការវិវត្តន៍នៃសភាពការណ៍សន្តិសុខថ្មីៗ គឺជាការព្រួយបារម្ភយ៉ាងធំធេង សម្រាប់តំបន់និងពិភពលោកទាំងមូល ជាពិសេសអរិភាពទាំងឡាយដែលកំពុងកើតមាននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងនៅអឺរ៉ុប។ ថ្វីត្បិតកម្ពុជាជាប្រទេសតូច តែក៏មានការពិសោធន៍ច្រើន ទាំងនៅក្នុងសង្គ្រាមរាប់ទសវត្ស ទាំងនៅក្នុងការរំលត់សង្គ្រាមរ៉ាំរ៉ៃនិងកសាងសន្តិភាពដ៏រឹងមាំ។ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលជាស្ថាបនិកនៃនយោបាយឈ្នះ ឈ្នះ និងជាមគ្គុទ្ទេសក៍ដ៏ចំណាននៅក្នុងការកសាងនិងការពារសន្តិភាពនៅកម្ពុជា បានគូសបញ្ជាក់ថា "យើងប្រាកដជាមិនអាចយកសង្គ្រាមទៅបញ្ចប់សង្គ្រាមបានទេ មានច្រកតែមួយគត់គឺការចរចាររកដំណោះស្រាយដោយសន្តិវិធី"។ គូបដិបក្ខទាំងឡាយដែលព្យាយាមជ្រើសរើសយកសង្គ្រាម មុខជាមិនមានអ្នកឈ្នះនោះឡើយ។ កម្ពុជាចូលរួមយ៉ាងពេញទំហឹង

ជាមួយបណ្តាប្រទេសក្នុងតំបន់ដទៃទៀត ដែលស្នេហាសន្តិភាព ជម្រុញឲ្យមានការដោះស្រាយវាល់ជម្លោះ ដោយការអត់ធ្មត់ជាអតិបរមា ការប្រើប្រាស់មធ្យោបាយការទូតនិងការសន្ទនា ព្រមទាំងការប្រឹងប្រែងកាត់បន្ថយភាពតានតឹងដើម្បីទប់ស្កាត់ការរីករាលដាលនៃជម្លោះ ដោយផ្អែកលើច្បាប់អន្តរជាតិ និងស្មារតីយោគយល់គ្នាទៅវិញទៅមក"

## ៤- បេសកកម្មរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ (អ.ស.ប)

ដើម្បីឆ្លើយតបតាមបេសកកម្មនីមួយៗបានទាន់ពេលវេលា កងយោធពលខេមរភូមិន្ទ យកចិត្តទុកដាក់លើការធ្វើនវានុវត្តន៍ ប្រែក្លាយជាអង្គភាពវ៉ៃឆ្លាត (Smart Pledge) និងបុគ្គលពហុជំនាញសម្រាប់វិធានប្រតិបត្តិការនិយាម (SOP) របស់ អ.ស.ប ក្នុងនោះ រៀបចំជាស្រេច ទាំងកម្លាំង មធ្យោបាយ គ្រឿងបំពាក់ តាមរចនាសម្ព័ន្ធរបស់ អ.ស.ប ដោយដាក់បញ្ចូលក្នុងប្រព័ន្ធត្រៀមជាស្រេច (UNPCRS - United Nations Peacekeeping Capability Readiness System) ដែលអាចចល័តបានក្នុងរយៈពេល៩០ថ្ងៃ ក្រោយពេលមានការស្នើសុំជាផ្លូវការពី អ.ស.ប ។ លើសពីនេះ ក៏មានយន្តការហ្វឹកហ្វឺនបណ្តុះបណ្តាលជាមួយបណ្តាប្រទេសដៃគូនានា ដើម្បីពង្រឹង និងពង្រីកសមត្ថភាពភាសាបរទេស ជំនាញបច្ចេកទេសគ្រឿងចក្រធុនធ្ងន់ វិស្វកម្ម មីន គ្រឿងផ្ទុះ ព័ត៌មានវិទ្យា វេជ្ជសាស្ត្រ ស្របតាមនិយាមនិងបទបញ្ញត្តិនានារបស់ អ.ស.ប ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសយ៉ាងឱឡារិកក្នុងមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៧៣ ទី៧៤ ទី៧៥ និងទី៧៦ ថាកម្ពុជាបន្តការប្តេជ្ញាចិត្តចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆ័ត្ររបស់ អ.ស.ប ឲ្យកាន់តែទូលំទូលាយថែមទៀត តាមលទ្ធភាពជាក់ស្តែង។ សេចក្តីថ្លែងការរបស់ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិ នៃបណ្តាប្រទេសបរិច្ចាគកងកម្លាំង រៀបចំឡើងដោយ អ.ស.ប នាសម័យប្រជុំលើកទី១នៅទីបញ្ជាការ អ.ស.ប ទីក្រុងញូវយ៉ក លើកទី២នៅចក្រភព

អង់គ្លេស និងលើកទី៣នៅសាធារណរដ្ឋកូរ៉េ បានបញ្ជាក់ថា កម្ពុជាប្ដេជ្ញា និងលើកទឹកចិត្តបញ្ជូនកងកម្លាំងជានារី ឱ្យបានលើសពី២០ភាគរយ តាមការស្នើសុំរបស់ អ.ស.ប។



យុទ្ធនារីកម្ពុជាក្នុងបេសកមកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ នៅអាហ្វ្រិកកណ្ដាល នៅលីបង់ និងនៅស៊ូដង់ខាងត្បូង (រូបភាព: NPMEC)

សម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ កម្ពុជានឹង៖

- ធ្វើជាម្ចាស់ផ្ទះគម្រោងត្រីភាគី រៀបចំដោយ អ.ស.ប កម្ពុជា និងជប៉ុន ហ្វឹកហ្វឺនជំនាញវិស្វកម្មធុនធ្ងន់ ដល់កងកម្លាំងរក្សាសន្តិភាពក្នុងសហគមន៍អាស៊ាន និងតំបន់
- ធ្វើជាម្ចាស់ផ្ទះគម្រោងត្រីភាគី និងបណ្តុះបណ្តាលយេនឌ័រ រៀបចំដោយ អ.សប កម្ពុជា និងកាណាដា ផ្តោតលើការលើកកម្ពស់យោធិនជានារី នៃកងយោធពលខេមរភូមិន្ទ សម្រាប់បំពេញបេសកកម្មរក្សាសន្តិភាពរបស់ អ.ស.ប
- រៀបចំសាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិឲ្យក្លាយជាសាលារក្សាសន្តិភាពថ្នាក់អាស៊ាន និងតំបន់
- ពង្រឹង ពង្រីក លើកកំពស់សមត្ថភាព និងធ្វើទំនើបកម្ម តាមរយៈការហ្វឹកហ្វឺនបណ្តុះបណ្តាល ព្រមទាំងបំពាក់នូវរាល់មធ្យោបាយ សម្ភារៈទំនើប ដល់គ្រប់អង្គភាពនៃកងយោធពលខេមរភូមិន្ទ សម្រាប់រ៉ាប់រងភារកិច្ចបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក្រោយឆ្នាំ២០២៥ ។
- កងយោធពលខេមរភូមិន្ទបន្តអនុវត្តនូវកាតព្វកិច្ច ចូលរួមប្រតិបត្តិការបោសសំអាតមីន តាមផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ "កម្ពុជាមួយគ្មានមីនឆ្នាំ២០២៥" (លិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០២២ ក្នុងឱកាសប្រារព្ធខួបលើកទី២៣ នៃទិវាជាតិយល់ដឹងអំពីមីន ២៤ កុម្ភៈ ២០២២)។

# ផ្នែកទី៣
# ការអនុវត្ត
# ផែនការយុទ្ធសាស្ត្រ

សៀវភៅសការពារជាតិ គឺជាឯកសារឆ្លុះបញ្ចាំងអំពីទស្សនវិស័យសម្រាប់កិច្ចការពារជាតិរបស់ព្រះរាជាណាចក្រកម្ពុជា និងជាត្រីវិស័យសម្រាប់កងយោធពលខេមរភូមិន្ទក្នុងការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួន ស្របតាមគោលនយោបាយការពារជាតិដែលមានបីសំខាន់ គឺថែរក្សាសន្តិភាព ការពារផលប្រយោជន៍ជាតិ និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ភាពរឹងមាំនៃគោលនយោបាយការពារជាតិ និងយុទ្ធសាស្ត្រការពារជាតិ នឹងនាំមកនូវសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ និងជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍជាតិលើគ្រប់វិស័យ ពង្រឹងខឿនសេដ្ឋកិច្ចជាតិនិងវិបុលភាពនៅក្នុងសង្គមជាតិទាំងមូល។

ដើម្បីឱ្យគោលនយោបាយការពារជាតិនិងយុទ្ធសាស្ត្រការពារជាតិ ដែលបានចែងក្នុងសៀវភៅសការពារជាតិឆ្នាំ២០២២ អនុវត្តទៅបានប្រកបដោយភាពជោគជ័យនិងមានប្រសិទ្ធភាពខ្ពស់ ទាមទារឱ្យមានការប្តេជ្ញាចិត្តនិងការគាំទ្រជ្រោមជ្រែងពីបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះដែរ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពនិងផ្តល់ការគាំទ្រដល់សេចក្តីត្រូវការចាំបាច់ទាំងឡាយផ្អែកតាមហេតុផលសមស្របនិងតម្លាភាព។

ថ្វីដ្បិតតែសៀវភៅសការពារជាតិឆ្នាំ២០២២ បានត្រូវចងក្រងឡើងដោយការគិតគូរហ្មត់ចត់និងយកចិត្តទុកដាក់យ៉ាងណាក៏ដោយ ក៏នៅតែទាមទារឱ្យមានការធ្វើវិវេចនានៅក្នុងរយៈពេលពីបី ទៅប្រាំឆ្នាំឬចងក្រងសៀវភៅសការពារជាតិថ្មីក្នុងគោលបំណងធ្វើបច្ចុប្បន្នភាព ការកែសម្រួលទៅតាមភាពចាំបាច់ជាក់ស្តែង និងការកំណត់យុទ្ធសាស្ត្រថ្មី សម្រាប់ឆ្លើយតបនឹងការគំរាមកំហែងមកលើសន្តិសុខជាតិដែលនឹងអាចកើតមាននាពេលអនាគតឱ្យស្របទៅនឹងការវិវត្ត និងបម្រែបម្រួលនៃសភាពការណ៍នយោបាយ សន្តិសុខ និងភូមិសាស្ត្រនយោបាយក្នុងប្រទេស តំបន់ និងសកលលោក។

ហេតុដូចនេះ ការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវនិងឆន្ទៈខ្ពស់ពីគ្រប់មជ្ឈដ្ឋានទាំងអស់នៃកងកម្លាំងប្រដាប់អាវុធ គឺជាតម្រូវការចាំបាច់។ វិធានការយុទ្ធសាស្ត្រសំខាន់ៗដែលកងទ័ពត្រូវយកចិត្តទុកដាក់ មានដូចជា ការពារសន្តិភាព ស្ថិរភាព និងឯកភាពជាតិឱ្យបានស្ថិតស្ថេរគង់វង្ស ផ្សារភ្ជាប់រវាងយោធានិងប្រជា

ពលរដ្ឋដើម្បីពង្រឹងខឿនការពារជាតិ បន្តកំណែទម្រង់យោធាឱ្យមានសមត្ថភាពទាន់សម័យ និងការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ជាមួយគ្នានេះដែរ ការត្រួតពិនិត្យនិងតាមដាន គឺជាកត្តាគន្លឹះសម្រាប់ឱ្យការអនុវត្តគោលនយោបាយការពារជាតិនេះបានជោគជ័យ។ កងយោធពលខេមរភូមិន្ទត្រូវមានយន្តការត្រួតពិនិត្យនិងតាមដានជាប្រចាំ លើការអនុវត្តគោលនយោបាយព្រមទាំងធ្វើការវាយតម្លៃអំពីវឌ្ឍនភាពនិងភាពប្រឈម។ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ត្រូវឱ្យតម្លៃខ្ពស់ចំពោះគោលនយោបាយស្ដីពីកិច្ចការពារជាតិ ហើយចាត់ទុកគោលនយោបាយយុទ្ធសាស្ត្រនេះជាបន្ទាត់និងប្រទីបបំភ្លឺ សម្រាប់ជោគជ័យនៃការអនុវត្តតួនាទីនិងភារកិច្ចរៀងៗខ្លួន។



ផ្នែកមួយនៃការកសាងគោលនយោបាយការពារជាតិ (រូបភាព: ក្រុមការងារសៀវភៅសការពារជាតិ)

ការរៀបចំផែនការយុទ្ធសាស្ត្រ ក៏ត្រូវឱ្យមានការឯកភាពគ្នារវាងស្ថាប័ននិងអង្គភាពទាំងអស់ ជាពិសេសត្រូវមានភាពស៊ីចង្វាក់គ្នាក្នុងការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រការពារជាតិ តាមឋានានុក្រម ពីថ្នាក់ក្រសួងការពារជាតិរហូតដល់

ថ្នាក់ក្រោមដើម្បីធានាបាននូវប្រសិទ្ធភាពនិងភាពជោគជ័យក្នុងការអនុវត្ត។ ក្នុងនោះដែរ គ្រប់ស្ថាប័ននិងអង្គភាពត្រូវកំណត់គោលដៅយុទ្ធសាស្ត្រ វាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយ និងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អនាគត ដើម្បីចូលរួមអនុវត្តឱ្យបានជោគជ័យនិងមានប្រសិទ្ធភាពខ្ពស់។

# ជំពូក៨
## ការគ្រប់គ្រងអាទិភាពនៃកិច្ចការពារជាតិ

ការធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយ គឺជាកត្តាចាំបាច់សម្រាប់កងយោធពលខេមរភូមិន្ទ ក្នុងការអនុវត្តគោលនយោបាយការពារជាតិនិងយុទ្ធសាស្ត្រការពារជាតិ ជាពិសេសលើការអភិវឌ្ឍអាជីពភាវូបនីយកម្មនិងទំនើបកម្មយោធា។ ជោគជ័យនៃកំណែទម្រង់យោធា ពឹងផ្អែកលើដំណើរការអនុវត្តជាប់លាប់និងការចូលរួមគាំទ្រពីសំណាក់ភាគីពាក់ព័ន្ធ។ ក្នុងន័យនេះ ការអនុវត្តប្រកបដោយការគ្រប់គ្រងនិងដោយអនុលោមទៅតាមអាទិភាពនៃការងារ នឹងធ្វើឱ្យការចាត់ចែងធនធានការពារជាតិបានចំគោលដៅ មានប្រសិទ្ធភាព និងមានតម្លាភាព។ អាទិភាពមួយចំនួន ដែលត្រូវយកចិត្តទុកដាក់រហូតដល់ឆ្នាំ២០៣០ មានដូចជា៖

### កិច្ចការពារព្រំដែន :

ដោយហេតុថា កម្ពុជានៅតែចាត់ទុកបញ្ហាព្រំដែនជាអាទិភាពមួយ ការពង្រឹងសមត្ថភាពកម្លាំងការពារព្រំដែន គឺជាការចាំបាច់បំផុត មានដូចជា វត្តមានជាប្រចាំ ការហ្វឹកហ្វឺន សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ។ អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានរំលេចនូវចក្ខុវិស័យដ៏ទូលំទូលាយនិងប្រកបដោយសក្តានុពល គឺ " **កសាងតំបន់ព្រំដែន ជាព្រំដែនសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍។ ប្រែក្លាយអតីតសមរភូមិជាតំបន់ទីផ្សារ អភិវឌ្ឍន៍ ផលិតកម្ម និងទេសចរណ៍** " ។

### សន្តិសុខផ្ទៃក្នុង :

ផ្តោតការយកចិត្តទុកដាក់លើការរក្សាសន្តិសុខ សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឱ្យបានល្អប្រសើរ។ ការបំផ្លាញចោលទាំងស្រុងនៅគ្រប់ពេលវេលា រាល់សកម្មភាពរបស់បដិវត្តន៍ពណ៌ គឺជាកាតព្វកិច្ចចម្បងរបស់កម្លាំងប្រដាប់អាវុធ។ ទប់ស្កាត់ឱ្យបានជាដាច់ខាត រាល់អសន្តិសុខទាំងឡាយដែលមានប្រភពមកពីអំពើភេរវកម្មនិងឧក្រិដ្ឋកម្មឆ្លងដែន ដើម្បីធានាឱ្យបាននូវសុខដុមនីយ

កម្មរបស់សង្គមជាតិ។ ត្រៀមលក្ខណៈជាប្រចាំដើម្បីជួយប្រជាពលរដ្ឋក្នុងពេលមានគ្រោះអាសន្ន។

### កំណែទម្រង់យោធា :

ទោះជាការគំរាមកំហែងនៃជំងឺឆ្លងរាតត្បាត នឹងកើតមានជាបន្តទៀតក៏ដោយ កំណែទម្រង់យោធានៅតែជាអាទិភាពចម្បងដដែល។ គោលដៅសំខាន់ គឺធ្វើឱ្យកងយោធពលខេមរភូមិន្ទ មានទ្រង់ទ្រាយសមស្របនិងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចការពារជាតិ ការពារសន្តិភាព និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក្រៅពីការកែសម្រួលរចនាសម្ព័ន្ធនិងការគ្រប់គ្រងបុគ្គលិកត្រូវបង្កលក្ខណៈឱ្យបានច្រើនថែមទៀត ដល់ការធ្វើអាជីពភាវូបនីយកម្មនិងទំនើបកម្មយោធាតាមលទ្ធភាពដែលអាចជំរុញបាន។

### កិច្ចសហប្រតិបត្តិការអន្តរជាតិ :

គោលដៅសំខាន់ គឺពង្រីកកិច្ចសហប្រតិបត្តិការយោធាជាមួយដៃគូទាំងឡាយ ដោយឈរលើគោលជំហរគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍ជាតិនិងផលប្រយោជន៍រួមនៅក្នុងតំបន់ផងដែរ។ កម្ពុជាមានការប្តេជ្ញាខ្ពស់នៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការយោធានៅគ្រប់រូបភាពទាំងអស់ រួមមានទ្វេភាគី ពហុភាគី ក្របខណ្ឌតំបន់ក្នុងយន្តការអន្តរជាតិក្នុងពេលធ្វើជាម្ចាស់ផ្ទះជាដើម។ល។ រក្សាសិទ្ធិនៅក្នុងការអភិវឌ្ឍសមត្ថភាពកងទ័ពតាមរយៈកិច្ចសហប្រតិបត្តិការជាមួយដៃគូបរទេស ស្ថិតក្នុងឯករាជ្យភាព អធិបតេយ្យជាតិ និងការសម្រេចចិត្តប្រកបដោយតម្លាភាព និងភាពស្មោះត្រង់។ ការពង្រីកសមត្ថភាពនៅក្នុងកិច្ចប្រតិបត្តិការរក្សាសន្តិភាព គឺជាអាទិភាពចម្បងបំផុតដែលបេសកកម្មក្រៅប្រទេសនេះ កំពុងតែលើកស្ទួយយ៉ាងត្រដែតត្រដឹមនូវមុខមាត់និងកិត្យានុភាពរបស់កម្ពុជា។

ការគិតគូរបែងចែកធនធាន ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការយោធាអន្តរជាតិ គឺជាការចាំបាច់ដើម្បីជំរុញការងារនេះឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងបរិបទសកលភាវូបនីយកម្ម។

# ជំពូក៩
# បច្ចេកវិទ្យានិងនវានុវត្តន៍យោធា

បច្ចេកវិទ្យាយោធាជាផ្នែកមួយដ៏សំខាន់ក្នុងកិច្ចការពារជាតិ យុទ្ធសាស្ត្ររារាំងនិងបង្ការសង្គ្រាម។ ជាក់ស្តែង បច្ចេកវិទ្យាក្នុងការបង្កើតបញ្ញាសិប្បនិម្មិតនិងជីវបច្ចេកវិទ្យាបានបង្ហាញនូវសក្តានុពលយ៉ាងខ្លាំង នៅក្នុងចំណោមបណ្តាប្រទេសមហាអំណាចនិងប្រទេសមានសេដ្ឋកិច្ចខ្ពស់ សម្រាប់ការអភិវឌ្ឍប្រកបដោយសមត្ថភាពក្នុងការស៊ើបការណ៍ រក្សាការសម្ងាត់ ទំនាក់ទំនង ចែករំលែកព័ត៌មាន និងវិភាគព័ត៌មានប្រកបដោយការសម្ងាត់ សុក្រឹតភាព និងទាន់ពេលវេលា។ ការប្រើប្រាស់ធនធានយោធាត្រូវប្រកបដោយភាពឆ្លាតវៃ ហើយការដាក់បញ្ចូលបច្ចេកវិទ្យាទាំងនេះនៅក្នុងការអភិវឌ្ឍសមត្ថភាព នឹងបង្កើនប្រសិទ្ធភាពប្រយុទ្ធនៃកងយោធពលខេមរភូមិន្ទ សម្រាប់ឆ្លើយតបទៅនឹងការគំរាមកំហែងផ្នែកសន្តិសុខ ទាំងជាប្រពៃណីនិងមិនមែនជាប្រពៃណី។ កងយោធពលខេមរភូមិន្ទត្រូវពិនិត្យមើលលើការផ្សារភ្ជាប់រវាងបច្ចេកវិទ្យាដែលមានស្រាប់និងការបង្កើតថ្មី ឱ្យសមស្របតាមយុទ្ធសាស្ត្រការពារជាតិ ពិសេសក្នុងបរិបទសម័យទំនើប។

ការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍គ្រប់វិស័យរមែងមានការប្រកួតប្រជែងខ្លាំង។ ដូច្នេះ កងយោធពលខេមរភូមិន្ទត្រូវត្រៀមខ្លួនចាប់យកឱកាសនេះដើម្បីទទួលបាននូវផលប្រយោជន៍ បង្កើនប្រសិទ្ធភាព ចីរភាព និងភាពបត់បែន។ ការប្រើប្រាស់នូវបច្ចេកវិទ្យានេះទៀតសោតត្រូវប្រកបដោយសមធម៌និងសមស្របទៅនឹងបច្ចេកវិទ្យាជំនាន់ថ្មីដែលកំពុងមានការវិវត្តឥតឈប់ឈរ។

ដើម្បីសម្រេចបាននូវគោលដៅខាងលើនេះ សម្រាប់រយៈពេលរហូតដល់ឆ្នាំ ២០៣០ ការបង្កើនសមត្ថភាពផ្នែកបច្ចេកវិទ្យានិងនវានុវត្តន៍របស់កងយោធពលខេមរភូមិន្ទ ទាមទារឱ្យមានវិធានសំខាន់ៗចំនួន៤ ដូចខាងក្រោម៖

### ក- អភិវឌ្ឍន៍ធនធានមនុស្ស :

វិនិយោគបន្ថែមលើការអភិវឌ្ឍធនធានមនុស្ស សម្រាប់ជំនាញផ្សេងៗ ដូចជា ផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា ការវិភាគព្យាករណ៍យុទ្ធសាស្ត្រ ការស្រាវជ្រាវ និងការអភិវឌ្ឍដើម្បីបង្កើនសមត្ថភាពខាងវិស័យការពារជាតិ។ កងយោធពលខេមរភូមិន្ទ ត្រូវខិតខំលើកកម្ពស់គំនិតផ្តួចផ្តើមនានាដើម្បីបង្កើនគុណភាពផ្នែកអប់រំនិងបណ្តុះបណ្តាល។

### ខ- អភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យា :

ផ្តោតការយកចិត្តទុកដាក់ លើការស្រាវជ្រាវនិងអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាទំនើបថ្មីៗ ដែលជាប្រយោជន៍ដល់ការអភិវឌ្ឍសមត្ថភាពរបស់កងយោធពលខេមរភូមិន្ទនៅក្នុងការបំពេញបេសកកម្ម ទាំងនៅក្នុងប្រទេសនិងនៅក្រៅប្រទេស។

### គ- អភិវឌ្ឍន៍លើវិស័យឧស្សាហកម្មយោធា :

ត្រូវវិនិយោគធនធានយោធា ក្នុងការអភិវឌ្ឍលើវិស័យឧស្សាហកម្មយោធាដែលជាកត្តាចាំបាច់ក្នុងការធ្វើទំនើបកម្មយោធា ធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព ឯករាជ្យភាព វឌ្ឍនភាព និងអាចកាត់បន្ថយការចំណាយលើការទិញពីបរទេស។

### ឃ- បង្កើនកិច្ចសហប្រតិបត្តិការនិងការចូលរួមជាមួយនឹងស្ថាប័នឯកជន :

កងយោធពលខេមរភូមិន្ទត្រូវយកចិត្តទុកដាក់ បង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួងស្ថាប័នរដ្ឋនិងឯកជននានា ដើម្បីអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងគោលបំណងបង្កើនសមត្ថភាពក្នុងទំនាក់ទំនង ផ្លាស់ប្តូរ ចែករំលែកព័ត៌មាន និងបទពិសោធឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។

# ជំពូក១០
## ថវិកាការពារជាតិ

ថវិកាការពារជាតិជាសមាសធាតុសំខាន់បំផុត នៅក្នុងការជំរុញនិងគាំទ្រវាល់ការអនុវត្តយុទ្ធសាស្ត្រការពារជាតិដែលបានកំណត់និងដាក់ចេញ។ ជាមួយគ្នានេះត្រូវមានការធានាផងដែរនូវការប្រើប្រាស់កញ្ចប់ថវិកាការពារជាតិ ប្រកបដោយតម្លាភាពនិងគណនេយ្យភាពនៅក្នុងកំណែទម្រង់ និងធ្វើទំនើបកម្មយោធាទាំងផ្នែកយុទ្ធោបករណ៍និងសម្ភារៈយោធាផ្សេងៗ ការហ្វឹកហ្វឺន ការសមយុទ្ធ និងការអភិវឌ្ឍធនធានយោធិនឱ្យមានសមត្ថភាព ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្ររយៈពេលមធ្យមនិងរយៈពេលវែង។

ផ្អែកតាមការកំណត់អាទិភាព ក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រការពារជាតិរហូតដល់ឆ្នាំ២០៣០ និងដើម្បីធ្វើឱ្យមាននិរន្តរភាពនៃការអភិវឌ្ឍវិស័យការពារជាតិ ក្រសួងការពារជាតិត្រូវការកញ្ចប់ថវិកាការពារជាតិប្រមាណ២.៥ភាគរយនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) សម្រាប់រយៈពេល៥ឆ្នាំខាងមុខនិងស្នើសុំបង្កើនឱ្យបានដល់២.៧ភាគរយនៃផ.ស.ស គិតចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០។ ចំណាត់ការនេះ នឹងផ្តល់លទ្ធភាពឱ្យមានការជឿនលឿននៅក្នុងការធ្វើកំណែទម្រង់យោធានិងទំនើបកម្មយោធា នៅពេលដែលមានកំណើនសេដ្ឋកិច្ចជាតិ។ ទស្សនៈនេះ មានចាប់តាំងពីឆ្នាំ២០០៦ (២.៧% នៃ ផ.ស.ស) ប៉ុន្តែយោងតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ វិស័យការពារជាតិបានទទួលបានទំហំថវិកាជាមធ្យមត្រឹមតែ១.៧៨% នៃផ.ស.ស តាំងពីឆ្នាំ២០១១ ដល់ឆ្នាំ២០២០។ តែទោះជាយ៉ាងណាក៏ដោយ វិស័យការពារជាតិរមែងទទួលបានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល ជាពិសេសពីសំណាក់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដោយការផ្តល់អាទិភាពចំពោះការគាំទ្រដល់ការអនុវត្តតួនាទីនិងភារកិច្ច របស់កងយោធពលខេមរភូមិន្ទ។

ចំពោះការទទួលនិងបែងចែកថវិកាការពារជាតិប្រចាំឆ្នាំ ត្រូវគិតគូទៅតាមអាទិភាពចាំបាច់របស់កងយោធពលខេមរភូមិន្ទ ជាពិសេសអនុលោមទៅតាមគោលនយោបាយការពារជាតិ៣ និងយុទ្ធសាស្ត្រការពារជាតិ៤ ពោលគឺកិច្ចការងារការពារព្រំដែន សន្តិសុខផ្ទៃក្នុង កំណែទម្រង់យោធា និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការបែងចែកថវិកាការពារជាតិទៅតាមអាទិភាពនេះ ចាំបាច់ត្រូវមានការចូលរួមដោយជំនាញពាក់ព័ន្ធ ជាពិសេសការកសាងផែនការដើម្បីតម្រូវទៅតាមធនធានដែលមានជាក់ស្តែង។ ការអនុវត្តនេះអាចប្រព្រឹត្តិទៅជាដំណាក់កាល ហើយការផ្លាស់ប្តូរឬភាពបត់បែននៃផែនការនឹងត្រូវធ្វើតាមរយៈវិវេចនាយុទ្ធសាស្ត្រ។

ការពិនិត្យតាមដាន និងវាយតម្លៃលើការប្រើប្រាស់ថវិកាការពារជាតិនេះទៀតសោត គឺការចាំបាច់ដើម្បីធានាដល់ការអនុវត្តសកម្មភាពនិងសូចនាករនានា ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ។ គ្រប់អង្គភាពពាក់ព័ន្ធត្រូវរៀបចំផែនការសកម្មភាពលម្អិតនិងកំណត់សូចនាករនៃលទ្ធផលឱ្យបានច្បាស់លាស់ សម្រាប់តាមដាន អនុវត្ត និងធ្វើបច្ចុប្បន្នភាពដើម្បីបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលការងារ។ យន្តការនេះមានសារៈសំខាន់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ ជាពិសេសសម្រាប់ថ្នាក់ដឹកនាំក្នុងការសម្រេចចិត្តនិងទទួលខុសត្រូវលើការប្រើប្រាស់ថវិកាជាតិ។

## ទីប្រឹក្សាជាន់ខ្ពស់

នាយឧ. ណឹម សុវត្ថិ

# សមាសភាពក្រុមការងារសៀវភៅសភាពការណ៍ជាតិ

## ប្រធាន

ឧឯក. សួន សំណាង

## អនុប្រធាន

ឧឯក. សំឆន សុភ័ក្រ្តា
ឧឯក. ផាត វិបុលសុភ័ក្រ្ត
ឧឯក. ខៀវ សាផាត
ឧទោ. ស៊ិន សុខា (អចិន្ត្រៃយ៍)

## សមាជិក

ឧឯក. វ៉ា មុនី
ឧឯក. សូ សំអន
ឧឯក. ណឹម សុវត្ថិ
ឧឯក. ចាប សំរាំង (ចូលនិវត្តន៍)
ឧឯក. អឿ សាវ៉ែន (ចូលនិវត្តន៍)
ឧទោ. ហ៊ឺ តារា
ឧទោ. តាំង ចាន់ពន្លឺ
ឧទោ. សុគន្ធ វិសាល
ឧទោ. កុសល សុវណ្ណវិសាល
ឧទោ. ស សំបូរធន
ឧទោ. កៅ សុខន
ឧទោ. ប៉ែន សុក្រឹត្យវិទ្យា
ឧទោ. សំ សោភា
ឧទោ. ពីរ វ៉ាន់ឌី
ឧនាវីទោ. មឿង វ៉ាន់នឿន
ឧត្រី. មៀច ហ៊ាន
ឧត្រី. ង៉ោ សុភាព
ឧត្រី. កឹង ភីរ៉ា
ឧត្រី. ផន ឫទ្ធីសក្តិ
ឧត្រី. ផាន់ ដារ៉ាវិទ្ធ
ឧត្រី. ខៀវ សេរីរដ្ឋា
ឧត្រី. ផា ច័ន្ទរ៉ា
ឧត្រី. ផន យិនយូរ៉ា
ឧត្រី. ធឿន បញ្ញាវិទ្ធ
វឯក. សៀ ទីន
វឯក. អ៊ុង ផល្គុន

វឯក. ស្រ៊ុន ប៊ុណ្ណាតូ
វឯក. អ៊ីន ប៊ុនថន
វឯក. ប៉ែន ចាន់សយ
វទោ. សួន រិទ្ធ
វទោ. សោម ប្រុស
វទោ. យិន ពិសិដ្ឋ
វឯក. ខន ម៉ៅ
វឯក. ជាវ សុវណ្ណតារា
វឯក. ផូវ មករា
វទោ. ម៉ិល គុណពិសិដ្ឋ
វទោ. ឈន បូរី
អទោ. ផន ដារីដ

# <u>សទ្ទានុក្រម</u>

## <u>Glossary</u>

| ល.រ | ពាក្យខ្មែរ | English |
|---|---|---|
| ១ | សៀវភៅសការពារជាតិ | Defence White Paper (DWP) |
| ២ | កាលានុវត្តភាព | Opportunities |
| ៤ | គោលនយោបាយការពារជាតិ | Defence Policy |
| ៥ | ជំងឺរាតត្បាតជាសកល | Pandemic |
| ៦ | ជំងឺរាតត្បាតក្នុងស្រុក | Epidemic |
| ៧ | ដែនឥទ្ធិពល | Sphere of Influence |
| ៩ | ទំនើបនីយកម្ម | Modernisation |
| ១០ | ប្រទេសមហាអំណាច | Superpower |
| ១១ | ភេរវកម្មឆ្លងដែន | Transnational terrorism |
| ១២ | យុទ្ធសាស្ត្រការពារជាតិ | Defence Strategy |
| ១៣ | យុទ្ធោបករណ៍ | Military Equipment |

| | | |
|---|---|---|
| ១៤ | យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | (UXO) Unexploded Ordnance |
| ១៥ | កិច្ចប្រជុំឧត្តមមន្ត្រីការពារជាតិអាស៊ាន | ASEAN Defence Senior Officials' Meeting (ADSOM) |
| ១៦ | កិច្ចប្រជុំឧត្តមមន្ត្រីការពារជាតិ អាស៊ានបូក | ASEAN Defence Senior Officials' Meeting-Plus (ADSOM-Plus) |
| ១៧ | ក្រុមការងារជំនាញនៃក្របខណ្ឌកិច្ចប្រជុំ ឧត្តមមន្ត្រីការពារជាតិអាស៊ានបូក | ADSOM-Plus Expert Working Group (ADSOM-Plus EWG) |
| ១៨ | វិវេចនាយុទ្ធសាស្ត្រការពារជាតិ | Defence Strategic Review (DSR) |
| ១៩ | វិទ្ធង្សនា | Subversion |
| ២០ | សុខដុមនីយកម្ម | Harmonisation |
| ២១ | ប្រឆាំងភេរវកម្ម | Counter-Terrorism (CT) |
| ២៣ | ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | Physical Infrastructure |
| ២៤ | ឧក្រិដ្ឋកម្មឆ្លងដែន | Transnational crime |
| ២៥ | កងយោធពលខេមរភូមិន្ទ | Royal Cambodian Armed Forces (RCAF) |
| ២៦ | រាជរដ្ឋាភិបាលកម្ពុជា | Royal Government of Cambodia (RGC) |

| | | |
|---|---|---|
| ២៧ | បញ្ញាសិប្បនិម្មិត | Artificial Intelligence (AI) |
| ២៨ | សន្តិសុខបច្ចេកវិទ្យាពត៌មាន | Cyber Security |
| ២៩ | សមុទ្រចិនខាងត្បូង | South China Sea (SCS) |
| ៣០ | អាស៊ីអាគ្នេយ៍ | Southeast Asia |
| ៣១ | រដ្ឋជាសមាជិកអាស៊ាន | ASEAN Member State (AMS) |
| ៣២ | ឧបទ្វីបកូរ៉េ | Korean Peninsula |
| ៣៣ | គំនិតផ្តួចផ្តើមឥណ្ឌូ-ប៉ាស៊ីហ្វិក | Indo-Pacific Initiative (IPI) |
| ៣៤ | មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីននិងកាកសំណល់សង្គ្រាម | National Centre for Peacekeeping Forces, Mines, and ERW Clearance (NPMEC) |
| ៣៥ | តួអង្គមិនមែនរដ្ឋ | Non-state Actor |
| ៣៦ | ការគំរាមកំហែងមិនប្រពៃណី | Non-traditional Threat |
| ៣៧ | អង្គការសហប្រជាជាតិ | United Nations (UN) |
| ៣៨ | បេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ | United Nations Peacekeeping Operations (UNPKO) |

| | | |
|---|---|---|
| ៣៩ | តុលាការអន្តរជាតិ | International Court of Justice (ICJ) |
| ៤០ | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា (អ៊ុនតាក់) | United Nations Transitional Authority in Cambodia (UNTAC) |
| ៤១ | បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម | National Counter-Terrorism Special Force (NCTSF) |
| ៤២ | គណៈកម្មការជាតិសន្តិសុខលំហសមុទ្រ | National Committee for Maritime Security (NCMS) |
| ៤៣ | គំនិតផ្តួចផ្តើមឈូងសមុទ្រថៃ | Gulf of Thailand Initiative (GOTI) |
| ៤៤ | ក្រុមការងារជំនាញនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន | ASEAN Defence Ministers' Meeting Expert Working Group (ADMM EWG) |
| ៤៥ | ជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ | Humanitarian Assistance and Disaster Relief (HADR) |
| ៤៦ ! | បដិវត្តន៍ពណ៌ | Colour Revolution |
| ៤៧ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | National Committee for Disaster Management (NCDM) |
| ៤៨ | ក្រសួងការពារជាតិ | Ministry of National Defence (MoND) |
| ៤៩ | អគ្គបញ្ជាការដ្ឋាន | High Command Headquarters (HCHQ) |

| | | |
|---|---|---|
| | នៃកងយោធពលខេមរភូមិន្ទ | |
| ៥០ | គំនិតផ្តួចផ្តើមអនុវត្តច្បាប់សមុទ្រ<br>អាស៊ីអាគ្នេយ៍ | Southeast Asia Maritime Law Enforcement Initiative (SEAMLEI) |
| ៥១ | អនុស្សរណៈយោគយល់គ្នា | Memorandum of Understanding (MOU) |
| ៥២ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | State Secretariat of Civil Aviation (SSCA) |
| ៥៣ | នាយទាហានរង | Non-commissioned Officer (NCO) |